សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ដំណើរឆ្ពោះទៅរកការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក. លី ញូគជិន**

សាស្ត្រាចារ្យណែនាំ

លោក **ឃឹម គីរី**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី២៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

ឆ្លៀតក្នុងឱកាសក៏មានតម្លៃនេះ នាងខ្ញុំសូមអនុញ្ញាតសម្ដែងនូវសេចក្ដីគោរពដឹងគុណ និង អរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកដែលបានរាយនាមដូចខាងក្រោម៖

ជីដូន **ច្រឹង ចន្ធូ** លោកឪពុក **លី ហេន** និងអ្នកម្ដាយ **ស្រេង ណារ៉ុន** ជាទីគោរពស្រលាញ់បំផុត ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា បង្ហាត់បង្រៀន ប្រៀនប្រដៅ អប់រំឱ្យនាងខ្ញុំក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អក្នុងសង្គម។ អ្នកទាំងបីបានផ្ដល់នូវកម្លាំងចិត្ត និងការគាំទ្រយ៉ាងវិសេសវិសាល ដែលជំរុញឱ្យនាងខ្ញុំទទួលបានការសិក្សារហូតឈានមកដល់ថ្ងៃសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះ។ ការចំណាយកម្លាំងកាយ ពេលវេលា និងញើសឈាមរបស់អ្នកទាំងបី បានបង្រៀននាងខ្ញុំឱ្យក្លាយជាមនុស្សចេះតស៊ូ ព្យាយាម ពុះពាររាល់ឧបសគ្គទាំងពួងដែលកើតមានរហូតមក។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាគ្រឹះស្ថានដែលបានផ្ដល់ឱកាសសិក្សា ទំនាក់ទំនងជាមួយសង្គមបញ្ញាវន្ត និងបណ្ដុំចំណេះដឹងជាច្រើន។ ជាងនេះទៅទៀត សាកលវិទ្យាល័យ ជាថ្នាលបណ្ដុះបណ្ដាលដ៏ប្រសើរ តាមរយៈការបង្ហាត់បង្រៀនពីលោក លោកស្រីសាស្ត្រាចារ្យដែលមានបទពិសោធន៍ និងវិជ្ជាជីវៈ ក្នុងការផ្ទេរចំណេះដឹងពិតប្រាកដដល់រូបនាងខ្ញុំ។

**មូលនិធិហាប់ស្វៀល** ដែលបានផ្ដល់នូវអាហារូបករណ៍រយៈពេលបួនឆ្នាំដល់នាងខ្ញុំ សម្រាប់ការស្នាក់នៅ ផ្គត់ផ្គង់ម្ហូបអាហារ និងការសិក្សាបន្ថែមអំពីភាពជាអ្នកដឹកនាំ។ ការរស់នៅទីនេះ ផ្ដល់ ឱ្យនាងខ្ញុំទទួលបានភាពកក់ក្ដៅដូចគ្រួសារតែមួយ ភាពជាបងប្អូនរស់នៅក្នុងសហគមន៍ ការអភិវឌ្ឍខ្លួនឯង និងសមត្ថភាពក្លាយជាអ្នកដឹកនាំនាពេលខាងមុខ។

**លោក-លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនយ៉ាងអស់ពីសមត្ថភាព និងពីទឹកចិត្តដ៏មុតមាំដល់រូបនាងខ្ញុំតាំងពីឆ្នាំសិក្សាមូលដ្ឋានមកម្ល៉េះ។ មិនត្រឹមតែបង្ហាត់បង្រៀនប៉ុណ្ណោះទេ ពួកគាត់បានអប់រំ ចង្អុលបង្ហាញ ណែនាំ លើកទឹកចិត្ត គាំទ្រ រាល់សកម្មភាពសិក្សាទាំងឡាយ ជាពិសេសតែងតែផ្ដល់ឱកាសគាំទ្រ និងត្រេកអរលើភាពជោគជ័យរបស់នាងខ្ញុំ។ ទាំងអស់នេះហើយ បានដាស់តឿនស្មារតីនាងខ្ញុំឱ្យភ្ញាក់រលឹក និងខិតខំប្រឹងប្រែងរៀនសូត្របន្តទៅទៀត ដើម្បីភាពជោគជ័យក្នុងពេលអនាគត។

ជាពិសេស នាងខ្ញុំសូមថ្លែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុត ដល់លោកសាស្ត្រាចារ្យ **ឃឹម គីរី** ជាគ្រូដឹកនាំសារណា ដែលបានគាំទ្រ ចំណាយពេលវេលាដ៏មានតម្លៃ ខិតខំណែនាំបង្ហាត់បង្រៀន ពន្យល់បង្ហាញ ពិនិត្យលើសារណាមួយនេះ ឱ្យសម្រេចបានជាផ្លែផ្កា។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ដល់លោកអ្នកមានគុណទាំងអស់ ជួបប្រទះតែសេច-ក្ដីសុខ សេចក្ដីចម្រើន សុភមង្គល និងជោគជ័យរាល់ភារកិច្ចជានិរន្តរ៍តរៀងទៅ។

# អារម្ភកថា

កន្លងមក វិស័យកម្មសិទ្ធិបញ្ញាត្រូវបានអ្នកសិក្សាស្រាវជ្រាវមានចំណាប់អារម្មណ៍ខ្លាំង ដោយសារវិស័យនេះពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មនាពេលបច្ចុប្បន្ន ហើយរហូតមានការលើកយកមកសរសេរជាសារណាបញ្ចប់ឆ្នាំសិក្សា ប៉ុន្តែភាគច្រើននៃសារណាបញ្ចប់ការសិក្សាផ្តោតលើប្រភេទកម្មសិទ្ធិបញ្ញាជាក់លាក់ក្នុងប្រទេសកម្ពុជា ដូចជា ការចុះបញ្ជីម៉ាក ពាណិជ្ជនាមជាដើម។ គួរបញ្ជាក់ផងដែរថា វិស័យកម្មសិទ្ធិបញ្ញា មានភាពទូលំទូលាយជាសកល មិនត្រឹមតែការចុះបញ្ជីនៅថ្នាក់ជាតិនោះទេ ប៉ុន្តែគេក៏អាចចុះបញ្ជីឱ្យមានការពារកម្មសិទ្ធិបញ្ញានៅថ្នាក់តំបន់ ឬអន្តរជាតិក៏បានដែរ។

ដោយមើលឃើញថា សហភាពអឺរ៉ុបមានប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងតំបន់របស់គេ ញ៉ាំងឱ្យនាងខ្ញុំគិតពិចារណាជាច្រើនលើកច្រើនសារ ថាតើគួរសិក្សាស្រាវជ្រាវអំពីការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅក្នុងសហគមន៍អាស៊ានដែរឬទេ ពីព្រោះអាស៊ានក៏ជាសហគមន៍មួយនៅក្នុងទ្វីបអាស៊ីផងដែរ។ បន្ទាប់ពីការប្រឹក្សាយោបល់ និងពិចារណាបានច្បាស់លាស់រួច ទើបនាងខ្ញុំសម្រេចចិត្តថានឹងសរសេរសារណានេះឡើងក្រោមប្រធានបទ **«ដំណើរឈានទៅរកការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន»**។

ម្យ៉ាងទៀត សារណានេះបានសរសេរអំពីសញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា ដើម្បីជាចំណេះ-ដឹងមូលដ្ឋាន សម្រាប់ការសិក្សាលើចំណុចបន្តបន្ទាប់ទៀត ដែលបានលើកឡើងអំពីការចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងសហភាពអឺរ៉ុប និងអំពីវិស័យកម្មសិទ្ធិបញ្ញាក្នុងសហគមន៍អាស៊ាន។

ប្រធានបទមួយនេះ អាចនឹងថ្មីសម្រាប់ការសិក្សាស្រាវជ្រាវ ហេតុនេះនាងខ្ញុំបានខិតខំយ៉ាងអស់ពីលទ្ធភាពក្នុងការស្រាវជ្រាវ និងសរសេរសារណានេះឡើងយ៉ាងហ្មត់ចត់បំផុត។ ប៉ុន្តែទោះជាយ៉ាងណា នាងខ្ញុំសូមអធ្យាស្រ័យទុកជាមុន ប្រសិនបើមានកំហុសខុសឆ្គងណាមួយ ដែលបានកើតឡើងទាក់ទងនឹងការផ្តល់នូវព័ត៌មានមិនបានពេញលេញ ហើយរង់ចាំទទួលនូវគ្រប់មតិរិះគន់ ដើម្បីស្ថាបនាទាំងឡាយ។

នាងខ្ញុំសង្ឃឹមថា សារណាមួយនេះ នឹងផ្តល់ឱ្យអ្នកសិក្សាទាំងឡាយ នូវចំណេះដឹង ថ្មីៗ និងការសិក្សាស្រាវជ្រាវបន្ថែមទៀតជុំវិញវិស័យកម្មសិទ្ធិបញ្ញា ចំពោះចំណុចខ្វះចន្លោះនៃសារណានេះ ជាពិសេសចំពោះនីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា។ នាងខ្ញុំសង្ឃឹមទៀតផងដែរថា សារណានេះនឹងរួមចំណែកលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា និងជាប្រយោជន៍ដល់អ្នកសិក្សាគ្រប់រូប។

# មាតិកា

ទំព័រ

អក្សរកាត់ .......... v
សេចក្ដីផ្ដើម .......... ១
ជំពូកទី១៖ សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា .......... ៣
១.១. កម្មសិទ្ធិលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈ .......... ៣
១.១.១. សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល .......... ៣
១.១.១.១. សិទ្ធិអ្នកនិពន្ធ .......... ៣
១.១.១.១.១. សញ្ញាណទូទៅ .......... ៣
១.១.១.១.២. ប្រភេទស្នាដៃដែលទទួលបានការការពារ និងរយៈពេលនៃការការពារ .......... ៣
១.១.១.១.៣. សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ .......... ៤
១.១.១.២. សិទ្ធិប្រហាក់ប្រហែល .......... ៦
១.១.១.២.១. សញ្ញាណទូទៅ .......... ៦
១.១.១.២.២. ការការពារស្នាដៃសិទ្ធិប្រហាក់ប្រហែល និងរយៈពេលនៃការការពារ .......... ៧
១.២. កម្មសិទ្ធិឧស្សាហកម្ម .......... ៧
១.២.១. ម៉ាក និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ .......... ៧
១.២.១.១. សញ្ញាណទូទៅ .......... ៧
១.២.១.២. ប្រភេទម៉ាក .......... ៨
១.២.១.៣. លក្ខខណ្ឌទទួលបានការការពារម៉ាកពាណិជ្ជកម្ម និងរយៈពេលនៃការការពារ .......... ៩
១.២.២. ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម .......... ៩
១.២.២.១. ប្រកាសនីយបត្រតក្កកម្ម .......... ៩
១.២.២.១.១. សញ្ញាណទូទៅ .......... ៩
១.២.២.១.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ .......... ១០
១.២.២.១.៣. សិទ្ធិលើប្រកាសនីយបត្រតក្កកម្ម .......... ១១
១.២.២.២. វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ .......... ១១
១.២.២.២.១. សញ្ញាណទូទៅ .......... ១១
១.២.២.២.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ .......... ១១
១.២.២.២.៣. សិទ្ធិលើវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ .......... ១២

១.២.២.៣. គំនូរឧស្សាហកម្ម ........ ១២
១.២.២.៣.១. សញ្ញាណទូទៅ ........ ១២
១.២.២.៣.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ ........ ១២
១.២.៣. ការសម្ងាត់ពាណិជ្ជកម្ម ........ ១៣
១.២.៣.១. សញ្ញាណទូទៅ ........ ១៣
១.២.៣.២. លក្ខខណ្ឌនៃការការពារ ........ ១៣
១.២.៤. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ ១៤
១.២.៤.១. សញ្ញាណទូទៅ ........ ១៤
១.២.៤.២. លក្ខខណ្ឌនៃការទទួលបានការការពារ ........ ១៤
១.២.៤.៣. សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ ១៤
១.២.៥. សិទ្ធិអ្នកបង្កាត់ពូជដំណាំ ........ ១៥
១.២.៥.១. សញ្ញាណទូទៅ ........ ១៥
១.២.៥.២. លក្ខខណ្ឌទទួលបានការការពារ ........ ១៥
១.២.៥.៣. សិទ្ធិអ្នកបង្កាត់ពូជដំណាំថ្មី ........ ១៦
ជំពូកទី២៖ ការប្រៀបធៀបយុទ្ធសាស្ត្រនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប និងតំបន់អាស៊ាន ........ ១៧
២.១. សហភាពអឺរ៉ុប ........ ១៧
២.១.១. ប្រវត្តិនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញា ........ ១៧
២.១.២. ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកចុះបញ្ជី ........ ១៧
២.១.២.១. ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (European Union Intellectual Property Office, “EUIPO”) ........ ១៧
២.១.២.១.១. អំពីការិយាល័យ ........ ១៧
២.១.២.១.២. ដំណើរការនៃការចុះបញ្ជីនៃប្រភេទកម្មសិទ្ធិបញ្ញានីមួយៗ ........ ១៨
២.១.២.២. ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (European Patent Office, “EPO”) ........ ២១
២.១.២.២.១. អំពីការិយាល័យ ........ ២១
២.១.២.២.២. ដំណើរការនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ........ ២១
២.២. ប្រៀបធៀបយុទ្ធសាស្ត្រនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប និងតំបន់អាស៊ាន ........ ២២
២.២.១. មូលហេតុនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួម ........ ២២

២.២.១.១. ឆន្ទៈរបស់សមាជិកក្នុងតំបន់.......................................................................... ២២
២.២.១.២. សេដ្ឋកិច្ចតំបន់............................................................................................ ២៣
២.២.២. ដំណាក់កាលនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួម ................................. ២៤
២.២.២.១. ការអនុម័តបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ................................................... ២៤
២.២.២.២. ការបង្កើតស្ថាប័នទទួលបន្ទុកចុះបញ្ជី........................................................... ២៤
២.២.៣. លក្ខខណ្ឌតម្រូវនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា ..................................................... ២៥
២.២.៣.១. លក្ខខណ្ឌនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា ......................................................... ២៥
២.២.៣.២. ម្ចាស់សិទ្ធិ ឬអ្នកតំណាង ............................................................................ ២៦
២.២.៤. សក្តានុពលនៃស្ថាប័នទទួលបន្ទុកចុះបញ្ជី........................................................... ២៦
២.២.៤.១. ការទទួលពាក្យស្នើសុំ.................................................................................. ២៦
២.២.៤.២. សមត្ថិផលរបស់ស្ថាប័ន................................................................................ ២៧
២.២.៥. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីកម្មសិទ្ធិបញ្ញា............................................ ២៩
២.២.៥.១. សន្ធិសញ្ញាក្នុងតំបន់ស្តីពីការចុះបញ្ជីកម្មសិទ្ធិបញ្ញា .......................................... ២៩
២.២.៥.២. កិច្ចសហប្រតិបត្តិការផ្សេងៗ ........................................................................ ៣០
ជំពូកទី៣៖ ជំហាននៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន
.................................................................................................................................. ៣១
៣.១. ប្រវត្តិ.................................................................................................................. ៣១
៣.២. បទដ្ឋានពាក់ព័ន្ធនឹងការឈានដល់ការបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់... ៣១
៣.២.១. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន...................... ៣១
៣.២.២. សេចក្តីថ្លែងការណ៍ ............................................................................................ ៣៣
៣.២.៣. កិច្ចប្រជុំអំពីកម្មសិទ្ធិបញ្ញា..................................................................................... ៣៣
៣.២.៤. ការចូលជាសមាជិកនៃបទដ្ឋានអន្តរជាតិទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញារបស់
សមាជិកអាស៊ាន ............................................................................................................ ៣៤
៣.៣. មធ្យោបាយស្វែងរកប្រភេទកម្មសិទ្ធិបញ្ញា ............................................................. ៣៧
៣.៣.១. ម៉ាក ................................................................................................................ ៣៧
៣.៣.២. ប្រកាសនីយបត្រតក្កកម្ម .................................................................................... ៤០
៣.៣.៣. គំនូរឧស្សាហកម្ម ................................................................................................ ៤១
៣.៣.៤. ម៉ាកសម្គាល់ភូមិសាស្ត្រធំនិញ ................................................................................ ៤១
៣.៤. យន្តការអភិវឌ្ឍន៍ និងការពង្រឹងបន្ថែម...................................................................... ៤២

៣.៤.១. ផែនការសកម្មភាព ........................................................................................ ៤២

៣.៤.២. វគ្គបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញា ............................................................ ៤៤

៣.៥. ការអនុវត្តកម្មសិទ្ធិបញ្ញាក្នុងតំបន់ ........................................................................ ៤៥

៣.៥.១. ការអនុវត្តផែនការសកម្មភាព ........................................................................ ៤៥

៣.៥.២. ការអនុវត្តកន្លងមក (ករណីសិក្សា) ................................................................ ៤៦

៣.៦. ផលវិជ្ជមាន និងបញ្ហាប្រឈមរបស់កម្ពុជា ទៅនឹងប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន ........................................................................................ ៤៧

៣.៦.១. ផលវិជ្ជមាន ........................................................................................ ៤៧

៣.៦.២. បញ្ហាប្រឈម ........................................................................................ ៤៨

៣.៧. ផលវិជ្ជមាន និងបញ្ហាប្រឈមនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញា........ ៤៨

៣.៧.១. ផលវិជ្ជមាន ........................................................................................ ៤៨

៣.៧.២. បញ្ហាប្រឈម ........................................................................................ ៤៩

សេចក្តីសន្និដ្ឋាន ........................................................................................ ៥១

អនុសាសន៍ ........................................................................................ ៥៣

ឯកសារយោង

ឧបសម្ព័ន្ធ

# អក្សរកាត់

ASEAN = Association of Southeast Asian Nations
(សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍)

AEC Blueprint = ASEAN Economic Community
(ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន)

ASPEC = ASEAN Patent Examination Co-orperation
(កិច្ចសហប្រតិបត្តិការត្រួតពិនិត្យបច្ចេកទេសលម្អិតអាស៊ាន)

AWGIPC = ASEAN Working Group on Intellectual Property Cooperation
(ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន)

Berne Convention = Berne Convention for the Protection of Literary and Artistic Works
(អនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ)

ECAP = EU-ASEAN Project on the Protection of Intellectual Property Rights
(គម្រោងសហភាពអឺរ៉ុប-អាស៊ាន ស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា)

EPC = European Patent Convention
(អនុសញ្ញាស្តីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប)

EPO = European Patent Office
(ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប)

EUIPO = European Union Intellectual Property Office
(ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប)

OHIM = Office for Harmonization in the Internal Market
(ការិយាល័យសម្រាប់ការធ្វើសុខដុមនីយកម្មទីផ្សារផ្ទៃក្នុង)

Paris Convention = Paris Convention for the Protection of Industrial Property
(អនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម)

PCT = Patent Cooperation Treaty (សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម)

WIPO = World Intellectual Property Organization
(អង្គការកម្មសិទ្ធិបញ្ញាពិភពលោក)

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្នុងពេលបច្ចុប្បន្ន សង្គមកាន់តែមានភាពជឿនលឿន ជាពិសេសបច្ចេកវិទ្យាកាន់តែមានភាពរីកចម្រើនឥតឈប់ឈរ។ ការបង្កើតនូវឧបករណ៍ និងផលិតផលថ្មីៗ សម្រាប់បម្រើដល់តម្រូវការសាធារណជនក៏កាន់តែមានច្រើនឡើងៗ ហើយផ្សាភ្ជាប់នឹងការធ្វើពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេសនូវរាល់ផលិតផល និងឧបករណ៍ទាំងអស់នោះ ដែលបានដាក់ឈ្មោះសម្រាប់សម្គាល់ផលិតផល និងឈ្មោះក្រុមហ៊ុនជាដើម។ ការធ្វើពាណិជ្ជកម្មមិនថាក្នុងស្រុក ឬក្រៅស្រុក ផលិតផលនោះអាចនឹងត្រូវបានគេលួចចម្លងរូបរាង ឬប្រើប្រាស់ឈ្មោះ ដើម្បីផលិតឡើងវិញ និងលក់ចែក-ចាយបន្ត ដែលជាហេតុនាំឱ្យខូចផលប្រយោជន៍សេដ្ឋកិច្ចរបស់ម្ចាស់សិទ្ធិ ឬម្ចាស់ស្នាដៃដើម។ ហេតុនេះហើយ បានជាម្ចាស់នៃស្នាដៃទាំងនោះ ត្រូវធ្វើយ៉ាងណាដើម្បីការពារកេរ្តិ៍ឈ្មោះមុខជំនួញរបស់ខ្លួនទាំងនៅក្នុងប្រទេសខ្លួន និងនៅបរទេស។

គំនិតនៃការទាមទារឱ្យមានការការពារចំពោះការបង្កើតថ្មីលើផលិតផល ឬសម្ភារណាមួយទើបបង្កើតបាននូវវិស័យថ្មីមួយ ត្រូវបានគេស្គាល់ថាជា កម្មសិទ្ធិបញ្ញា។

កម្មសិទ្ធិបញ្ញា សំដៅលើការបង្កើតទាំងឡាយណាដែលកើតចេញពីគំនិតបញ្ញារបស់មនុស្សដូចជាការច្នៃប្រឌិត ការបង្កើតថ្មី ស្នាដៃអក្សរសាស្ត្រ និងសិល្បៈ គំនូរឧស្សាហកម្ម និងរូបភាពផ្សេងៗទៀត ដែលត្រូវបានប្រើក្នុងពាណិជ្ជកម្ម។ កម្មសិទ្ធិបញ្ញានេះទៀតសោត មានច្បាប់ជាច្រើនដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការការពារចំពោះស្នាដៃទាំងនោះ ដូចជាច្បាប់ស្តីពីប្រកាស-នីយបត្រតក្កកម្ម ច្បាប់ស្តីពីម៉ាក ដែលអាចឱ្យគេសម្គាល់ ឬទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចដែលកើតចេញពីការច្នៃប្រឌិត ឬបង្កើតថ្មីរបស់ពួកគេ។[1] កម្មសិទ្ធិបញ្ញា ត្រូវបានបែងចែកជាមែកធាងធំៗពី គឺ កម្មសិទ្ធិឧស្សាហកម្ម និងកម្មសិទ្ធិអ្នកនិពន្ធ។ ប្រភេទនៃកម្មសិទ្ធិបញ្ញាទាំងពីរនេះ ត្រូវបានបញ្ញត្តិក្នុងលិខិតតុបករណ៍អន្តរជាតិដែលគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

តាមពិតទៅ បើត្រឡប់ទៅអតីតកាលវិញ វិស័យកម្មសិទ្ធិបញ្ញានេះ បានកើតឡើងមុននឹងការកកើតនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក អនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សា-ហកម្មទៅទៀត ប៉ុន្តែពេលនោះ មិនបានចែងអំពីនីតិវិធីការពារកម្មសិទ្ធិបញ្ញាបានវិសេសវិសាលទេ។ ក្រោយមកចាប់ពីមានអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងបទដ្ឋានអន្តរ-ជាតិផ្សេងៗទាក់ទងនឹងកម្មសិទ្ធិបញ្ញា វិស័យកម្មសិទ្ធិបញ្ញាបានចាប់ផ្តើមមានការការពារតាមរយៈការចុះបញ្ជីនៅថ្នាក់ជាតិ ថ្នាក់តំបន់ ឬអន្តរជាតិ។

ដោយឡែក នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ពុំទាន់មានការចុះបញ្ជីកម្មសិទ្ធិបញ្ញារួមនៅឡើយនោះទេ ម្ល៉ោះហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវដាក់ពាក្យទៅតាមប្រទេសដែលគេចង់ការពារ

---

[1] WIPO, What is Intellectual Property? [តើអ្វីជាកម្មសិទ្ធិបញ្ញា], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.wipo.int/about-ip/en/ ។

ដែលការដាក់ពាក្យតាមប្រទេសនីមួយៗនេះ ត្រូវគោរពតាមច្បាប់ជាតិនៃប្រទេសនោះ។ ការចុះបញ្ជីទៅតាមប្រទេសនីមួយៗបែបនេះ គឺត្រូវការចំណាយពេលវេលាយូរ ថវិកាច្រើន និងនីតិវិធីវែងឆ្ងាយខុសៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ។

អាស៊ាន ជាអង្គការអន្តររដ្ឋាភិបាលមួយ ដែលមានរដ្ឋជាសមាជិកសុទ្ធសឹងជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយបានចងជាចង្កោមស្រាប់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏នៅតែមានបញ្ហាក្នុងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមថ្នាក់តំបន់ដែរ និងកាន់តែមិនអាចទៅរួចប្រសិនបើធ្វើការប្រៀបធៀបជាមួយនឹងសហភាពអឺរ៉ុបដែលមានភាពជឿនលឿនខ្លាំង ហើយអាចបង្កើតបានប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់។ បញ្ហាដែលនឹងចោទឡើងនោះគឺ អាស៊ានក៏ជាបណ្តុំនៃប្រទេសដែលមានសមាជិកក្នុងតំបន់ ហើយសហភាពអឺរ៉ុបមានលក្ខណៈដូចនេះដែរ ប៉ុន្តែអាស៊ាននៅពុំទាន់អាចធ្វើបានដូចសហភាពអឺរ៉ុប ហើយថាតើអាស៊ានអាចនឹងឈានទៅដល់ ការបង្កើតនូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់បានឬយ៉ាងណា ពីព្រោះថារហូតមកដល់ពេលនេះ អាស៊ានមិនទាន់បានធ្វើសមាហរណកម្មបានពេញលេញនៅឡើយទេ បើទោះបីជាមានការប្រកាសថា អាស៊ានបានធ្វើសមាហរណកម្មនៅក្នុង ឆ្នាំ២០១៥ រួចមកហើយនោះក៏ដោយ។

តាមរយៈការសិក្សាស្វែងយល់ពីអាស៊ានកន្លងមក ទើបញ៉ាំងឱ្យមានគំនិតក្នុងការសរសេរសារណានេះឡើងក្រោមប្រធានបទ **«ដំណើរឈានទៅរកការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន»** ដើម្បីស្រាវជ្រាវបន្ថែមអំពីលទ្ធភាព ក៏ដូចជាសមត្ថភាពរបស់អង្គការអន្តររដ្ឋាភិបាលមួយនេះ ចំពោះវិស័យកម្មសិទ្ធិបញ្ញា។ គោលបំណង ដែលលើកយកប្រធានបទនេះឡើងគឺ (១)ដើម្បីពង្រីកចំណេះដឹងបន្ថែមអំពីកម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ាន ពីព្រោះប្រទេសកម្ពុជាក៏ជាសមាជិកមួយក្នុងចំណោមសមាជិកប្រាំបួនផ្សេងទៀត (២)ស្វែងយល់បន្ថែមពីការអនុវត្តផែនការសកម្មភាពរបស់អាស៊ាន និង (៣)ធ្វើការសិក្សាពីសក្តានុពលរបស់អាស៊ានក្នុងការបង្កើតនូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់ ដោយសម្លឹងឃើញថា វិស័យកម្មសិទ្ធិបញ្ញា ជាមូលដ្ឋានដ៏សំខាន់នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ក្នុងសារណានេះនឹងលើកឡើងអំពី (១)សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា ដែលនឹងធ្វើការសិក្សាសង្ខេបអំពីប្រភេទកម្មសិទ្ធិបញ្ញា ជួយដល់អ្នកអានឱ្យមានចំណេះដឹងជាមុនអំពីកម្មសិទ្ធិបញ្ញា (២)ការប្រៀបធៀបយុទ្ធសាស្ត្រនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប និងតំបន់អាស៊ាន ដើម្បីសិក្សាអំពីសហភាពអឺរ៉ុប អំពីដំណើរការនៃបង្កើតឱ្យបាននូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងតំបន់ ដែលអាចធ្វើឱ្យអាស៊ានយកគំរូតាម និង(៣)ជំហាននៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន ដែលលើកឡើងអំពីយន្តការរបស់អាស៊ានចំពោះដំណើរការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់។

# ជំពូកទី១

# សញ្ញាណទូទៅនៃ
# កម្មសិទ្ធិបញ្ញា

# ជំពូកទី១៖ សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា

## ១.១. កម្មសិទ្ធិលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈ

### ១.១.១. សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

#### ១.១.១.១. សិទ្ធិអ្នកនិពន្ធ

##### ១.១.១.១.១. សញ្ញាណទូទៅ

អ្នកនិពន្ធ គឺជាអ្នកបង្កើតបានស្នាដៃ ដែលស្នាដៃនោះជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី ហើយកើតចេញពីការច្នៃប្រឌិត គំនិតប្រាជ្ញា ឬមនោសញ្ចេតនា។[2] ឧទាហរណ៍៖ សៀវភៅអានគ្រប់ប្រភេទ កម្មវិធីកុំព្យូទ័រ ផ្ទាំងគំនូរ ជាអាទិ៍។

ចំណែកសិទ្ធិអ្នកនិពន្ធ គឺសំដៅលើសិទ្ធិរបស់ម្ចាស់ស្នាដៃ ដែលទទួលបានកិច្ចការពារស្រប ច្បាប់។ សិទ្ធិនេះផ្តល់អោយបាន កាលណាស្នាដៃនោះជាស្នាដៃដើមរបស់អ្នកនិពន្ធ មានន័យថាជា ស្នាដៃដែលកើតចេញពីគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធ។[3] ប្រសិនបើគ្រាន់តែជាគំនិតក្នុងការបង្កើត នូវស្នាដៃណាមួយ គំនិតនោះមិនត្រូវបានច្បាប់ការពារឡើយ បើសិនគំនិតនោះមិនបានលេចចេញ នូវស្នាដៃរូបិយនោះទេ។[4]

សិទ្ធិអ្នកនិពន្ធ មានសារប្រយោជន៍ចំពោះអ្នកនិពន្ធ ដែលស្នាដៃត្រូវបានច្បាប់ការពារចៀស វាងបានពីការរំលោភសិទ្ធិ ហើយវាក៏ជាកត្តាជំរុញឱ្យមានការបង្កើតនូវស្នាដៃថ្មីៗបន្តទៀតផងដែរ។

សិទ្ធិកម្មសិទ្ធិលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈ អាចស្វែងរកបានក្នុងប្រភពអន្តរជាតិតាម-រយៈអនុសញ្ញាទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម (Paris Convention for the Protection of Industrial Property) ឆ្នាំ១៨៨៣ និងអនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរ-សាស្ត្រ និងសិល្បៈ (Berne Convention for the Literary and Arts) ឆ្នាំ១៨៨៦ គ្រប់គ្រងដោយអង្គការ កម្មសិទ្ធិបញ្ញាពិភពលោក[5] (ហៅកាត់ថា WIPO)។ ចំណែកក្នុងប្រភពជាតិមានបញ្ញត្តិក្នុងច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

##### ១.១.១.១.២. ប្រភេទស្នាដៃដែលទទួលបានការការពារ និងរយៈពេលនៃការការពារ

ការការពារស្នាដៃរបស់អ្នកនិពន្ធ មានលក្ខណៈពិសេសមួយត្រង់ថា ស្នាដៃរបស់អ្នកនិពន្ធ ត្រូវបានការពារដោយស្វ័យប្រវត្តិតាមរយៈសិទ្ធិអ្នកនិពន្ធ ដូច្នេះការចុះបញ្ជីដើម្បីការពារស្នាដៃរបស់

---

[2] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា ២(ក) និង (ខ), ពីពេលនេះតទៅហៅថា ច្បាប់សិទ្ធិអ្នកនិពន្ធ។

[3] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៤។

[4] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ១០។

[5] WIPO គឺជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកការពារកម្មសិទ្ធិបញ្ញាតាមរយៈប្រព័ន្ធអន្តរជាតិ ក្នុងការ លើកកម្ពស់ ស្ថេរភាពការច្នៃប្រឌិត និងការបង្កើតថ្មី ដែលជួយអភិវឌ្ឍន៍សេដ្ឋកិច្ចអន្តរជាតិ។

ខ្លួនអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ហើយអ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។[6] ក្នុងករណីដែលម្ចាស់សិទ្ធិចង់ចុះបញ្ជីការពារស្នាដៃរបស់ខ្លួន នោះការចុះបញ្ជីអាចធ្វើទៅបាននៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈផងដែរ ដោយតម្រូវឱ្យដាក់ឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ កាលបរិច្ឆេទនៃស្នាដៃដែលបានផ្សព្វផ្សាយ[7] ជាលើកដំបូង កាលបរិច្ឆេទបង្កើតឡើង ព្រមទាំងចុះពីសិទ្ធិអ្នកនិពន្ធ។[8]

ទោះជាយ៉ាងណាក៏ដោយ ការកំណត់អំពីប្រភេទស្នាដៃជាភាពចាំបាច់មួយ ពីព្រោះស្នាដៃទាំងអស់មិនប្រាកដថាអាចនឹងទទួលបានការការពារនោះទេ។ ស្នាដៃ ដែលទទួលបានកិច្ចការពារស្របច្បាប់មានបួនប្រភេទធំៗគឺ ស្នាដៃអ្នកនិពន្ធ[9] ស្នាដៃអ្នកសម្តែង[10] ហ្វូណូក្រាម[11] និងការផ្សាយតាមទូរផ្សាយ[12]។[13]

សិទ្ធអ្នកនិពន្ធ ត្រូវបានការពារដោយច្បាប់គិតចាប់ពីថ្ងៃដែលបង្កើតស្នាដៃនោះមកម្ល៉េះពោលសិទ្ធិនេះត្រូវបានការពារពេញមួយជីវិតរបស់អ្នកនិពន្ធ និងការពាររយៈពេល៥០ឆ្នាំបន្តទៀតក្រោយមរណភាពរបស់អ្នកនិពន្ធ។[14]

រាល់ការរំលោភបំពានទាំងឡាយចំពោះសិទ្ធិផ្តាច់មុខនៃម្ចាស់សិទ្ធិអ្នកនិពន្ធត្រូវបានចាត់ទុកថាជាអំពើល្មើស ឬការបំពានលើសិទ្ធិអ្នកនិពន្ធ។[15]

### ១.១.១.១.៣. សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌

នៅពេលដែលអ្នកនិពន្ធបង្កើតបានស្នាដៃណាមួយ នោះអ្នកនិពន្ធនឹងទទួលបានសិទ្ធិពីរដាច់ដោយឡែកពីគ្នា គឺសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។

---

[6] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣៨។

[7] ការផ្សព្វផ្សាយ អាចប្រព្រឹត្តតាមរយៈការចុះផ្សាយ បោះពុម្ពផ្សាយ ការផ្សាយតាមព្រឹត្តិបត្រ ជាអាទិ៍។

[8] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣៩។

[9] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣, «ស្នាដៃអ្នកនិពន្ធ សំដៅលើស្នាដៃដែលកើតចេញពីជនមានសញ្ជាតិខ្មែរ ស្នាដៃដែលបានបោះពុម្ពផ្សាយលើកដំបូងក្នុងប្រទេសកម្ពុជា ឬក្នុងអំឡុងពេល៣០ថ្ងៃក្រោយការបោះពុម្ពផ្សាយលើកដំបូងនៅបរទេស ស្នាដៃសោតទស្សន៍ ស្នាដៃស្ថាបត្យកម្ម ដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងស្នាដៃដែលប្រទេសកម្ពុជាមានកាតព្វកិច្ចការពារក្រោមសន្ធិសញ្ញាអន្តរជាតិ។»

[10] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣, «ស្នាដៃអ្នកសម្តែង សំដៅលើស្នាដៃរបស់អ្នកសម្តែងដែលមានសញ្ជាតិខ្មែរ ឬពុំមានសញ្ជាតិខ្មែរ ប៉ុន្តែការសម្តែងនោះប្រព្រឹត្តទៅលើទឹកដីប្រទេសកម្ពុជា ឬបានថតបញ្ចូលជាហ្វូណូក្រាម ដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់សិទ្ធិអ្នកនិពន្ធ ឬបានផ្សព្វផ្សាយតាមទូរផ្សាយដែលស្ថិតក្រោមកិច្ចការពារនៃច្បាប់នេះ។»

[11] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣, «ហ្វូណូក្រាម សំដៅលើហ្វូណូក្រាមរបស់ផលិតករមានសញ្ជាតិខ្មែរ បានថតបញ្ចូលសូរសម្លេង ឬថតផ្សាយជាលើកដំបូង នៅក្នុងប្រទេសកម្ពុជា។»

[12] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា៣, «ការផ្សាយតាមទូរផ្សាយ សំដៅដល់ការផ្សាយនៃអង្គភាពទូរផ្សាយដែលចេញពីឧបករណ៍ផ្សាយ ឬមានទីស្នាក់ការនៅក្នុងប្រទេសកម្ពុជា។»

[13] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣។

[14] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៣០។

[15] ឯកសារបណ្តុះបណ្តាល, ការពន្យល់ និងឧទាហរណ៍៖ *កម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច*។

**សិទ្ធិបេតិកភណ្ឌ** គឺជាសិទ្ធប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យ ដែលជាស្នាដៃរបស់ខ្លួនតាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត។[16] សិទ្ធិ-បេតិកភណ្ឌអាចត្រូវបានគេស្គាល់ម្យ៉ាងទៀតថាជា **សិទ្ធិសេដ្ឋកិច្ច** ព្រោះសិទ្ធិនេះអាចទូទាត់ជាសាច់ប្រាក់បានតាមរយៈការអនុវត្តសិទ្ធិអ្នកនិពន្ធ[17] រួមមានសិទ្ធិក្នុងការផលិតស្នាដៃឡើងវិញ ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃ សោតទស្សន៍ ឬស្នាដៃថតបញ្ចូលជាហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង ការចែកចាយជាសាធារណៈតាមការលក់ ពិពណ៌ ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួនការច្របាច់បញ្ចូលស្នាដៃផ្សេងៗ ដើម្បីបានជាស្នាដៃថ្មីមួយ។ ដូច្នេះហើយ សិទ្ធិបេតិកភណ្ឌអាចត្រូវបានផ្ទេរទៅតតិយជនដើម្បីធ្វើអាជីវកម្មទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយកិច្ចសន្យានានា។ កិច្ចសន្យាពីរប្រភេទ ដែលត្រូវបានយកមកប្រើជាញឹកញាប់នោះគឺ កិច្ចសន្យាអនុប្បទាន[18] និងកិច្ចសន្យាអាជ្ញាប័ណ្ណ[19]។

**សិទ្ធិសីលធម៌** គឺជាសិទ្ធិអចិន្ត្រៃយ៍ ដែលមិនអាចលក់ដូរបាន មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាល។ សិទ្ធិសីលធម៌ អនុញ្ញាតអោយអ្នកនិពន្ធ ឬអ្នកបង្កើតស្នាដៃអនុវត្តន៍សកម្មភាពក្នុងការថែរក្សា និងការពារចំពោះស្នាដៃទាំងឡាយដែលភ្ជាប់នឹងស្នាដៃរបស់គេ។[20]

សិទ្ធិសីលធម៌ រួមមានសិទ្ធិផ្តាច់មុខក្នុងការសម្រេចពី របៀប និងពេលវេលានៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ ព្រមទាំងបែបបទគ្រប់គ្រងការផ្សព្វផ្សាយសិទ្ធិកំណត់ឱ្យគេទទួលស្គាល់ឈ្មោះ ឋានៈ និងស្នាដៃរបស់ខ្លួនសម្រាប់ទាក់ទងជាមួយសាធារណជន និងសិទ្ធិជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកាត់ចោលខ្លឹមសារ ឬការកែប្រែខ្លឹមសារជាហេតុធ្វើឱ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់អ្នកនិពន្ធ។[21] ប្រសិនបើអ្នកនិពន្ធទទួលមរណភាពនោះ ទាយាទ ឬតតិយជនអាចទទួលសិទ្ធិនេះបានតាមមតកសាសន៍ ហើយបើគ្មានអ្នកទទួលមរតកទេ រដ្ឋដែលតំណាងដោយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងក្លាយជាអ្នកគ្រប់គ្រងសិទ្ធិនោះ។[22]

---

[16] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ២១។

[17] នី វិចិត្រ, *នីតិកម្មសិទ្ធិបញ្ញាកម្ពុជា*, (២០១៣), ៦២។

[18] ដដែល, កិច្ចសន្យាអនុប្បទាន ជាកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិលើវត្ថុអរូបិយ(សិទ្ធិ) រវាងអនុប្បទាយី(ម្ចាស់សិទ្ធិ) និងអនុប្បទានិក (អ្នកទទួលសិទ្ធិ)។

[19] ដដែល, កិច្ចសន្យាអាជ្ញាប័ណ្ណ ជាកិច្ចសន្យាដែលម្ចាស់ម៉ាក(អ្នកផ្តល់អាជ្ញាប័ណ្ណ)យល់ព្រមប្រគល់សិទ្ធិធ្វើអាជីវកម្មមួយផ្នែក ឬទាំងមូលនៃម៉ាកឱ្យទៅតតីយជន(អ្នកទទួលអាជ្ញាប័ណ្ណ) ដោយទទួលបានមកវិញនូវតម្លៃតបស្នងសមមូលទៅនឹងការអនុវត្តសិទ្ធិរបស់តតីយជនលើម៉ាក។

[20] World Intellectual Property Organization (WIPO), Understanding Copyright and Related Rights [ការស្វែងយល់អំពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល], (២០១៦), http://www.wipo.int/edocs/pubdocs/en/wipo_pub_909_2016.pdf (ថតចម្លងថ្ងៃទី ០១ មិថុនា ២០១៨)។

[21] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ២០។

[22] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ១៩។

### ១.១.១.២. សិទ្ធិប្រហាក់ប្រហែល

#### ១.១.១.២.១. សញ្ញាណទូទៅ

សិទ្ធិប្រហាក់ប្រហែល មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងសិទ្ធិអ្នកនិពន្ធ ពីព្រោះថា សិទ្ធិប្រហាក់ប្រហែលនឹងពុំកើតមានទេ ប្រសិនបើគ្មានស្នាដៃអ្នកនិពន្ធណាមួយកើតឡើងនោះ។ សិទ្ធិប្រហាក់ប្រហែល ជាស្នាដៃបន្ទាប់បន្សំនៃស្នាដៃអ្នកនិពន្ធ។ ដូច្នេះ សិទ្ធិប្រហាក់ប្រហែល ជាសិទ្ធិត្រូវបានការពារអមនឹងសិទ្ធិអ្នកនិពន្ធ។ ឧទាហរណ៍៖ ក្នុងបទចម្រៀងមួយបទ មានការផ្សំនូវផ្នែកជាច្រើនដូចជា អ្នកនិពន្ធបទភ្លេង ឬបទចម្រៀង ដែលត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ រីឯអ្នកលេងភ្លេង អ្នកសម្តែង អ្នកចម្រៀងនានាដែលមិនមែនជាអ្នកនិពន្ធ នោះត្រូវបានការពារដោយសិទ្ធិប្រហាក់ប្រហែល។[23]

សិទ្ធិប្រហាក់ប្រហែល មានគោលដៅការពារលើសិទ្ធិ និងផលប្រយោជន៍របស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានចូលរួមចំណែកបង្កើតស្នាដៃ ឬការអនុវត្តសិទ្ធិរបស់អ្នកនិពន្ធ ហើយសិទ្ធិប្រហាក់ប្រហែល សំដៅដល់សិទ្ធិអ្នកសម្តែង[24] សិទ្ធិផលិតករហ្វូណូក្រាម[25] សិទ្ធិផលិត-ករវីដេអូ[26] និងសិទ្ធិអង្គភាពទូរផ្សាយ[27] ដែលជាប្រធាននៃសិទ្ធិប្រហាក់ប្រហែល។[28]

---

[23] ដូច ១៧, ទំព័រ៨៥។

[24] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៤១, «អ្នកសម្តែង មានសិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ ឬអនុញ្ញាត ក្នុងការផ្សាយតាមទូរផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈនូវការសម្តែងរបស់ខ្លួន ក្នុងការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួន ដែលមិនទាន់បានថតបញ្ចូលហ្វូណូក្រាម ក្នុងការផលិតឡើងវិញនូវការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាម ក្នុងការចែកចាយជាសាធារណៈតាមការលក់ ឬការផ្ទេរកម្មសិទ្ធិនូវហ្វូណូក្រាមច្បាប់ដើម ដែលអ្នកសម្តែងពុំទាន់បានអនុញ្ញាតឱ្យធ្វើការចែកចាយ និងក្នុងការដាក់ជួល ឬការឱ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬហ្វូណូក្រាមច្បាប់ចម្លងស្តីពីការសម្តែង។»

[25] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៤៤-៤៥, «ផលិតករហ្វូណូក្រាមមានសិទ្ធិផ្តាច់មុខក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ខ្លួន មានសិទ្ធិចែកចាយជាសាធារណៈតាមការលក់ ឬផ្ទេរកម្មសិទ្ធិនូវច្បាប់ដើម ឬច្បាប់ចម្លង និងសិទ្ធិនាំចូលនូវច្បាប់ចម្លងនៃហ្វូណូក្រាមរបស់ខ្លួនក្នុងទិសដៅធ្វើការផ្សព្វផ្សាយជាសាធារណៈ។ រាល់ការផលិតឡើងវិញ ការលក់ ការប្តូរ ការជួល ឬការផ្សព្វផ្សាយជាសាធារណៈនោះ ត្រូវមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម។»

[26] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៤៦, «ផលិតករវីដេអូ ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានការផ្តួចផ្តើមគំនិត និងការទទួលខុសត្រូវក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពជាឈុតៗ ដែលមាន ឬគ្មានសម្លេងដើម្បីផលិតវីដេអូ។ ចំពោះការផលិតឡើងវិញនូវវីដេអូដើម្បីផ្សព្វផ្សាយជាសាធារណៈ លក់ ដូរ ឬជួល ចាំបាច់ត្រូវតែមានការអនុញ្ញាតពីផលិតករវីដេអូ។»

[27] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៤៧, «អង្គភាពទូរផ្សាយមានស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ និងស្ថានីយទូរទស្សន៍ខ្សែកាប មានសិទ្ធិផ្តាច់មុខក្នុងការធ្វើ ឬអនុញ្ញាត ការថតកម្មវិធីផ្សាយ ការផ្សព្វផ្សាយជាសាធារណៈ ការចាក់ផ្សាយឡើងវិញ ការផលិតឡើងវិញ ការចែកចាយ ឬការដាក់ជួល ជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីផ្សាយរបស់ស្ថានីយសាមី។»

[28] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ២(ណ)។

#### ១.១.១.២.២. ការការពារស្នាដៃសិទ្ធិប្រហាក់ប្រហែល និងរយៈពេលនៃការការពារ

សិទ្ធិប្រហាក់ប្រហែល ការពារលើស្នាដៃទាំងឡាយណាដែលបានកើតចេញពីស្នាដៃរបស់អ្នកនិពន្ធ។

រយៈពេលនៃការការពារសិទ្ធិប្រហាក់ប្រហែល មានរយៈពេល៥០ឆ្នាំ ទាំងអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពផ្សាយ។ សម្រាប់អ្នកសម្តែងមានរយៈពេលការពារ៥០ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម ឬក្នុងករណីដែលពុំបានថតការសម្តែងបញ្ចូលក្នុងហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលការសម្តែងបានប្រព្រឹត្តទៅ។ រយៈ-ពេលការពារផលិតករហ្វូណូក្រាមគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិនដែលបានបោះផ្សាយហ្វូណូក្រាម ឬក្នុងករណីពុំបានផ្សាយហ្វូណូក្រាម គឺគិតចាប់ពីដំណាច់ឆ្នាំប្រក្រតីទិន ដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាម។ ចំណែកការការពារកម្មវិធីផ្សព្វផ្សាយរបស់អង្គភាពទូរផ្សាយគិតចាប់ពីពេលដែលកម្មវិធីបានផ្សាយ។[29]

## ១.២. កម្មសិទ្ធិឧស្សាហកម្ម

### ១.២.១. ម៉ាក និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

#### ១.២.១.១. សញ្ញាណទូទៅ

ម៉ាក ត្រូវបានប្រើប្រាស់គ្របដណ្តប់ទាំងលើ ទំនិញ និងសេវា។ ម៉ាកត្រូវបានឱ្យនិយមន័យថាជាសញ្ញាដែលអាចមើលឃើញ ហើយអាចសម្គាល់ភាពខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ នៅពេលដែលយកម៉ាកប្រើប្រាស់លើទំនិញ នោះហៅថា ពាណិជ្ជសញ្ញា ចំណែកម៉ាកដែលប្រើលើសេវា ហៅថាសេវាសញ្ញា។[30] ឧទាហរណ៍៖ ម៉ាក «Dell» ជាពាណិជ្ជសញ្ញាដែលត្រូវបានប្រើលើផលិតផលអេឡិចត្រូនិក និង ម៉ាក «DHL» ជាសេវាសញ្ញាដែលត្រូវបានប្រើសម្រាប់ផ្តល់សេវាដឹកជញ្ជូន។

សារប្រយោជន៍នៃម៉ាកសម្រាប់សហគ្រាសក្នុងការប្រកួតប្រជែងគឺ ការទាក់ទាញអតិថិជនដែលស្គាល់ម៉ាកពាណិជ្ជកម្មរបស់សហគ្រាស ការពង្រឹងយុត្តិសាស្ត្រផ្សព្វផ្សាយទីផ្សារ ការកំណត់អំពីរូបភាពពាណិជ្ជកម្មរបស់ខ្លួន កេរ្តិ៍ឈ្មោះសហគ្រាស ការបង្កើនទំនុកចិត្តពីអ្នកប្រើប្រាស់ ការកំណត់អំពីគុណភាពនៃទំនិញ ឬសេវា ការផ្តល់ការលើកទឹកចិត្តដល់សហគ្រាស ដើម្បីពង្រីកការវិនិយោគ និងពង្រឹងគុណភាពនៃទំនិញ ឬសេវានៃម៉ាកនោះដែលអាចនឹងធ្វើឱ្យម៉ាកនោះកាន់តែមានតម្លៃ និងល្បីល្បាញ។[31]

---

[29] ច្បាប់សិទ្ធិអ្នកនិពន្ធ, មាត្រា ៥៣។

[30] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា ២(ក), ពីពេលនេះតទៅហៅថា ច្បាប់ម៉ាក។

[31] ដូច ១៧, ទំព័រ១៨២-១៨៣។

បទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យម៉ាក រួមមានអនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៨៨៣ សន្ធិសញ្ញាច្បាប់ស្តីពីម៉ាក ឆ្នាំ១៩៩៤ កិច្ចព្រមព្រៀងទីក្រុងនីស ស្តីពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវាសម្រាប់គោលបំណងចុះបញ្ជីម៉ាក (Nice Agreement) ឆ្នាំ១៩៥៧ កិច្ចព្រមព្រៀងទីក្រុង ម៉ាឌ្រីត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ឆ្នាំ១៨៩១ ពិធីសារទីក្រុងម៉ាឌ្រីតទាក់ទងនឹងកិច្ចព្រម- ព្រៀងទីក្រុងម៉ាឌ្រីត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ឆ្នាំ១៩៨៩ និងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPs) ឆ្នាំ១៩៩៤ របស់អង្គការពាណិជ្ជកម្មពិភពលោក (ហៅកាត់ថា WTO)។ រីឯក្នុងក្របខ័ណ្ឌជាតិវិញ ម៉ាកត្រូវបានបញ្ញត្តិក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២។[32]

រាល់អំពើនៃការប្រកួតប្រជែងទាំងឡាយណា ដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងត្រង់ក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ [33] ដូចជាការបង្កើតឱ្យមានការភាន់ច្រឡំតាមមធ្យោបាយណាមួយជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង។ លើសពីនេះ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ជាការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ សហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង និងការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំ អំពីប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្រប សម្រាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។[34]

### ១.២.១.២. ប្រភេទម៉ាក

ម៉ាកត្រូវបានបែងចែកជាបីប្រភេទគឺ ម៉ាកធម្មតា ម៉ាកសមូហភាព (Collective Mark) និងពាណិជ្ជនាម។[35]

**ម៉ាកធម្មតា** សំដៅលើម៉ាកសម្គាល់លើទំនិញ ឬសេវារបស់សហគ្រាសនីមួយៗ ដែលត្រូវបានគេស្គាល់ថា ជាពាណិជ្ជសញ្ញា បើសិនម៉ាកនោះប្រើប្រាស់លើទំនិញ ឬជាសេវាសញ្ញាបើសិនម៉ាកនោះត្រូវបានប្រើប្រាស់សម្រាប់សេវា។ ម៉ាកទាំងនេះគឺមានលក្ខណៈធម្មតា ដែលមានឈ្មោះ អក្សរ លេខ រូបភាព និមិត្តសញ្ញា ឡូហ្គោ ពាក្យ បង្គុំនៃពណ៌ ឬបង្គុំនៃសញ្ញា។

ឧទាហរណ៍៖ ម៉ាកជាឈ្មោះ "Nestle", ម៉ាកជាអក្សរ McDonald's, ម៉ាកជាលេខ 76

**ម៉ាកសមូហភាព** គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសម្គាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណ-

---

[32] កាន់ សុទ្ធប៉ូលីន, *នីតិកម្មសិទ្ធិបញ្ញា*, បោះពុម្ពលើកទី២, (២០១៤), ៩១ - ៩២។

[33] ច្បាប់ម៉ាក, មាត្រា ២២។

[34] ច្បាប់ម៉ាក, មាត្រា ២៣។

[35] ច្បាប់ម៉ាក, មាត្រា ២។

ភាពនៃទំនិញ ឬសេវាកម្មរបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី។[36]

ឧទាហរណ៍៖ ម្រេចកំពត

**ពាណិជ្ជនាម** គឺជាឈ្មោះ ឬសញ្ញាសម្គាល់ សម្រាប់បញ្ជាក់ និងសម្គាល់លក្ខណៈខុសៗនៃសហគ្រាសនីមួយៗ។

ឧទាហរណ៍៖ ក្រុមហ៊ុន Google

### ១.២.១.៣. លក្ខខណ្ឌទទួលបានការការពារម៉ាក និងរយៈពេលនៃការការពារ

ម៉ាកមិនត្រូវបានការពារដោយស្វ័យប្រវត្តិនោះទេ ហេតុនេះម៉ាកដែលទទួលបានការការពារលុះណាតែ ម៉ាកនោះបានចុះបញ្ជីទើបម៉ាកនោះ អាចត្រូវបានប្រើសិទ្ធិផ្តាច់មុខបាន។[37] ម្យ៉ាងវិញទៀត មិនមែនរាល់ម៉ាកទាំងអស់សុទ្ធតែអាចចុះបញ្ជីបាននោះទេ ដូច្នេះការចុះបញ្ជីម៉ាកដើម្បីទទួលបានការការពារត្រូវគោរពទៅតាមលក្ខខណ្ឌច្បាប់កំណត់ ពោលលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការចុះបញ្ជីម៉ាក។[38] យោងមាត្រា ២(១) នៃច្បាប់ស្តីពីម៉ាក អាចត្រូវបានចាត់ទុកជាម៉ាក និងអាចការពារបានលុះណាតែម៉ាកជាសញ្ញាអាចមើលឃើញ ហើយខុសពីទំនិញដទៃ ឬសេវា ដូច្នេះ ក្លិន សំឡេង រសជាតិ មិនអាចចាត់ទុកជាម៉ាកដែលទទួលបានការការពារក្នុងក្របខ័ណ្ឌនៃច្បាប់របស់ប្រទេសកម្ពុជាឡើយ។

ម៉ាកទទួលបានការពារក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីពេលដាក់ពាក្យសុំចុះបញ្ជី ហើយអាចស្នើសុំបន្តសុពលភាពបានជារៀងរហូត ហើយដែលការសុំបន្តសុពលភាពម្តងៗមានរយៈពេល ១០ឆ្នាំដូចៗគ្នា ប៉ុន្តែក្នុងករណីមានភាពយឺតយ៉ាវណាមួយនោះ ការសុំចុះបញ្ជីសាជាថ្មីត្រូវបានអនុញ្ញាតឱ្យមានការយឺតយ៉ាវត្រឹមតែរយៈពេល ៦ខែ។[39]

## ១.២.២. ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

### ១.២.២.១. ប្រកាសនីយបត្រតក្កកម្ម

#### ១.២.២.១.១. សញ្ញាណទូទៅ

ប្រកាសនីយបត្រតក្កកម្ម គឺជាវិញ្ញាបនបត្រដែលរដ្ឋផ្តល់ឱ្យតក្កករដើម្បីការពារតក្កកម្ម។ តក្កករ គឺជាអ្នកបង្កើតតក្កកម្ម ដែលតក្កកម្មនោះអាចយកទៅអនុវត្តន៍បានដើម្បីដោះស្រាយបញ្ហា

---

[36] ច្បាប់ម៉ាក, មាត្រា ២(ខ)។

[37] ច្បាប់ម៉ាក, មាត្រា ៣។

[38] ដូច ១៧, ទំព័រ១៩១។

[39] ច្បាប់ម៉ាក, មាត្រា ១២។

ជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិទ្យា។ តក្កកម្ម អាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[40]

ការការពារលើតក្កកម្មនេះ គឺដើម្បីលើកទឹកចិត្តចំពោះការច្នៃប្រឌិត និងការស្រាវជ្រាវ ក៏ដូចជាអភិវឌ្ឍវិទ្យាសាស្ត្របច្ចេកវិទ្យា។ បន្ថែមពីនេះ ជំរុញនិងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស និងការវិនិយោគ ជាការលើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាមកប្រទេសកម្ពុជា ដើម្បីជួយដល់សកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងនឹងអំពើរំលោភសិទ្ធិនានា។

ក្របខ័ណ្ឌអន្តរជាតិនៃប្រកាសនីយបត្រតក្កកម្មត្រូវបានចែងក្នុង សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (Patent Cooperation Treaty (PCT)) ឆ្នាំ១៩៧០ និងសន្ធិសញ្ញាច្បាប់ប្រកាសនីយបត្រតក្កកម្ម (Patent Law Treaty (PLT)) ឆ្នាំ២០០០។ សម្រាប់ក្របខ័ណ្ឌជាតិមានចែងក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០៣។

### ១.២.២.១.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ

ប្រកាសនីយបត្រតក្កកម្ម ទាមទារឱ្យមានការចុះបញ្ជីដើម្បីទទួលបានការការពារ។ ក្នុងការចុះបញ្ជីមានចំណុចសំខាន់បីយ៉ាងដែលជាលក្ខខណ្ឌចម្បងរួមមាន៖ ថ្មី មានជំហានរកឃើញថ្មី និងអាចយកទៅអនុវត្តន៍បាននៅក្នុងវិស័យឧស្សាហកម្ម។[41] ភាពថ្មីនៃតក្កកម្ម មិនសំដៅដល់ការកែច្នៃ ឬបង្កើតថ្មីឡើងវិញនូវតក្កម្មដែលមានពីមុននោះទេ ប៉ុន្តែភាពថ្មីក្នុងន័យនេះ សំដៅទៅលើតក្កកម្មមួយដែលមិនធ្លាប់មានអ្នកណារកឃើញពីមុន ឬដឹងពីមុន មានន័យថាជាតក្កកម្មដែលថ្មីស្រឡាងហើយពុំធ្លាប់មានពីមុននៅលើពិភពលោក។[42] ជំហានរកឃើញថ្មី សំដៅដល់ការយល់ដឹងរបស់មនុស្សចំពោះតក្កកម្ម។ ប្រសិនបើតក្កកម្មនោះ មិនអាចឱ្យបុគ្គលក្នុងកម្រិតជំនាញធម្មតាយល់ដឹងបាន ដូច្នេះ តក្កកម្មនោះមានជំហានរកឃើញថ្មី។[43] រីឯតក្កកម្ម ដែលអាចអនុវត្តបាននៅក្នុងវិស័យឧស្សា-ហកម្ម សំដៅលើតក្កកម្មដែលអាចត្រូវបានផលិត ឬត្រូវបានប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃ វិស័យឧស្សាហកម្ម។[44]

ប្រកាសនីយបត្រតក្កកម្ម មានរយៈពេលនៃការការពារ ២០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ហើយមិនអាចស្នើសុំបន្តសុពលភាពនៃការពារជា

[40] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សហកម្ម, លេខ នស/រកម/០១០៣/០០៥, ២២ មករា ២០០៣, មាត្រា ៣, ពីពេលនេះតទៅហៅថា ច្បាប់ប្រកាសនីយបត្រតក្កកម្ម។

[41] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៥។

[42] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៦។

[43] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៧។

[44] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៨។

ថ្មីឡើងវិញបានឡើយ។[45] ក្នុងអំឡុងពេលការពារ តក្កករ ឬអ្នកតំណាងស្របច្បាប់ត្រូវបង់កម្រៃប្រចាំឆ្នាំ ដើម្បីទទួលបានការការពារ ប្រសិនបើពុំមានការបង់កម្រៃទេ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកថាបានដកយកទៅវិញ ឬត្រូវអស់សុពលភាព ដែលមានន័យថានឹងលែងមានការការពារតទៅទៀត។[46] ក្រោយពីផុតរយៈពេល២០ឆ្នាំនៃការការពារ តក្កកម្មនោះនឹងត្រូវបានក្លាយជាសម្បត្តិសាធារណៈដែលជនគ្រប់រូបអាចប្រើប្រាស់បាន។

**១.២.២.១.៣. សិទ្ធិលើប្រកាសនីយបត្រតក្កកម្ម**

ម្ចាស់ប្រកាសនីយបត្រតក្កកម្ម មានសិទ្ធិផ្តាច់មុខក្នុងការធ្វើអាជីវកម្មដើម្បីផលប្រយោជន៍សេដ្ឋកិច្ច ដូចជាការផលិត ការផលិតឡើងវិញ ការចែកចាយ ការនាំចេញនាំចូល និង/ឬផ្ទេរសិទ្ធិទៅឱ្យតតិយជន។ ជនទាំងឡាយអាចប្រើប្រាស់តក្កកម្មនោះបាន លុះណាតែមានការអនុញ្ញាតពីម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម បើពុំដូច្នោះទេ នោះវាជាអំពើរំលោភសិទ្ធិប្រកាសនីយបត្រតក្កកម្ម។[47]

**១.២.២.២. វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍**

**១.២.២.២.១. សញ្ញាណទូទៅ**

វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មដែរ ប៉ុន្តែអ្វីដែលម៉ូដែលមានអត្ថប្រយោជន៍ និងប្រកាសនីយបត្រតក្កកម្មមានលក្ខណៈខុសគ្នានោះគឺ លក្ខខណ្ឌ រយៈពេលនៃការការពារ និងសិទ្ធិអំណាចរបស់រដ្ឋដែលអាចរឹបអូសតក្កកម្មពីតក្កករបាន។

វិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារម៉ូដែល-មានអត្ថប្រយោជន៍។ ម៉ូដែលមានអត្ថប្រយោជន៍ គឺជាតក្កកម្មណាមួយដែលថ្មី និងអាចយកទៅអនុវត្តន៍បានក្នុងវិស័យឧស្សាហកម្ម និងអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬដែលអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[48] ម៉ូដែលមានអត្ថប្រយោជន៍ អាចហៅថាប្រកាសនីយបត្រក្កកម្មខ្នាតតូច។[49]

**១.២.២.២.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ**

ម៉ូដែលមានអត្ថប្រយោជន៍ មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្ម ប៉ុន្តែដោយសារម៉ូដែលមានអត្ថប្រយោជន៍មានលក្ខណៈតូចជាងប្រកាសនីយបត្រតក្កកម្មនោះលក្ខខណ្ឌដែលត្រូវចុះបញ្ជីទទួលបានការពារសម្រាប់ម៉ូដែលមានអត្ថប្រយោជន៍មានតែពីរចំណុចទេ គឺ ថ្មី និង

[45] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៥៥។
[46] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៥៦។
[47] ដូច ១៧, ទំព័រ១៣០-១៣១។
[48] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៦៩។
[49] ដូច ១៥, ទំព័រ៥៤។

អាចយកអនុវត្តន៍បានក្នុងវិស័យឧស្សាហកម្ម។[50] ចំណែករយៈពេលនៃការការពារមានត្រឹមតែ ៧ ឆ្នាំប៉ុណ្ណោះ និងពុំអាចបន្តសុពលភាពនៃការការពារជាថ្មីឡើងវិញបាននោះទេ។[51]

##### ១.២.២.២.៣. សិទ្ធិលើវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

រាល់ការអនុវត្តសិទ្ធិរបស់ម្ចាស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ត្រូវបានអនុវត្តន៍ដូចគ្នាទៅនឹងម្ចាស់ប្រកាសនីយបត្រតក្កកម្មដូចគ្នាផងដែរ។[52]

### ១.២.២.៣. គំនូរឧស្សាហកម្ម

#### ១.២.២.៣.១. សញ្ញាណទូទៅ

គំនូរឧស្សាហកម្ម គឺជាការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់ បីវិមាត្រ ឬសម្ភារណាមួយទោះបីជាមាន ឬពុំមានការផ្គុំរួមជាមួយបន្ទាត់ ឬពណ៌ក៏ដោយ ឱ្យតែការផ្គុំទម្រង់ ឬសម្ភារទាំងនោះរំលេចឡើងជារូបរាងពិសេសរបស់ផលិតផល ឧស្សាហកម្ម ឬសិប្បកម្ម និងដែលអាចធ្វើជាគំរូផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងអាចសម្គាល់បានដោយចក្ខុ។[53]

ឧទាហរណ៍៖ រូបរាងដបទឹកបរិសុទ្ធ រូបរាងកែវទឹក ជាអាទិ៍

#### ១.២.២.៣.២. លក្ខខណ្ឌទទួលបានការការពារ និងរយៈពេលនៃការការពារ

គំនូរឧស្សាហកម្ម ទទួលបានការការពារលុះណាតែមានការចុះបញ្ជី ដោយគោរពទៅតាមលក្ខខណ្ឌតែមួយគត់គឺ ថ្មី។[54] គំនូរឧស្សាហកម្មត្រូវចាត់ទុកថាថ្មី ប្រសិនបើគំនូរឧស្សាហកម្មនោះមិនទាន់បានបញ្ចេញឱ្យដឹងដល់សាធារណជននៅទីកន្លែងណាមួយនៅលើពិភពលោក មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ តាមរយៈការផ្សព្វផ្សាយដោយប្រើរូបភាពជាក់ស្តែង ឬតាមរយៈការប្រើប្រាស់ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត។[55]

គំនូរឧស្សាហកម្ម អាចត្រូវបានការពារក្នុងរយៈពេល ៥ឆ្នាំបន្ទាប់ពីបានចុះបញ្ជីរួចរាល់ ហើយអាចចុះបញ្ជីការពារបន្តបាន២ដងជាប់ៗគ្នា ដែលការចុះបញ្ជីម្តងមានសុពលភាពការពារ ៥ឆ្នាំដូចៗគ្នា។[56]

[50] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៦៩។
[51] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៧៣។
[52] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៧០។
[53] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៨៩។
[54] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៩១។
[55] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ៩២។
[56] ច្បាប់ប្រកាសនីយបត្រតក្កកម្ម, មាត្រា ១០៩ ថ្មី។

### ១.២.៣. ការសម្ងាត់ពាណិជ្ជកម្ម

#### ១.២.៣.១. សញ្ញាណទូទៅ

ការសម្ងាត់ពាណិជ្ជកម្ម អាចចាត់ទុកថាជាព័ត៌មាន ដែលមានតម្លៃទាក់ទងនឹងពាណិជ្ជកម្ម ដែលមិនត្រូវបានស្គាល់ ឬដឹងជាក់ច្បាស់អំពីព័ត៌មាននោះ និងត្រូវបានរក្សាការសម្ងាត់ជានិច្ច។[57]

ឧទាហរណ៍៖ រូបមន្តនៃការផលិតកូកាកូឡា ជាការសម្ងាត់ពាណិជ្ជកម្ម ដែលរហូតមកដល់ពេលនេះមិនទាន់មានការដឹងលឺជាសាធារណៈទេ ដោយសាររូបមន្តនេះមិនត្រូវបានចុះបញ្ជីការពារទេ ដូច្នេះ រូបមន្តនៃការផលិតនេះត្រូវបានរក្សាការពារសម្ងាត់ជានិច្ច បើទោះបីមានការបកស្រាយពីអ្នកណាក៏ដោយថាព័ត៌មាននោះបែបនេះ ឬបែបនោះ។ ប្រសិនបើម្ចាស់ព័ត៌មាន នៅតែអះអាងថា រូបមន្ត ឬវិធីសាស្ត្រធ្វើពាណិជ្ជកម្មមិនមែនជារបស់ខ្លួន នោះព័ត៌មាននៅតែជាការសម្ងាត់។

សារប្រយោជន៍ការសម្ងាត់ពាណិជ្ជកម្ម គឺការមិនកំណត់រយៈពេលនៃការការពារដរាបណាការសម្ងាត់នោះ ត្រូវបានដឹងលឺជាសាធារណៈ មិនមានការកំណត់តម្លៃក្នុងការចុះបញ្ជី បើទោះបីជាវាប្រហែលជាមានតម្លៃថ្លៃចំពោះការរក្សាព័ត៌មានសម្ងាត់ មានអានុភាព ឬប្រសិទ្ធភាពភ្លាមៗ ការការពារព័ត៌មានសម្ងាត់មិនតម្រូវឱ្យមាន ការអនុលោមតាមបែបបទទម្រង់ជាក់លាក់ ដូចជាការបង្ហាញព័ត៌មានទៅសមត្ថកិច្ចរដ្ឋាភិបាលជាដើម។[58]

ចំពោះក្របខ័ណ្ឌគតិយុត្តនៃការសម្ងាត់ពាណិជ្ជកម្មគឺនៅ ពុំទាន់ឃើញមានច្បាប់ពិសេសនៅឡើយទេ ប៉ុន្តែស្ថិតក្នុងសេចក្តីព្រាងច្បាប់ស្តីការការពារ ការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម។ យ៉ាងណាមិញមានច្បាប់មួយចំនួនដែលចែងទាក់ទងនឹងចំណុចនេះដូចជា ក្រមព្រហ្មទណ្ឌ(២០១០) ក្រមរដ្ឋប្បវេណី(២០០៧) ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(២០០៥) ច្បាប់ស្តីពីសវនកម្ម(២០០០) និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ(១៩៩៩) ។[59]

#### ១.២.៣.២. លក្ខខណ្ឌនៃការការពារ

ដើម្បីចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម ព័ត៌មាននោះត្រូវតែជាការសម្ងាត់ និងមានតម្លៃសេដ្ឋកិច្ច។ ព័ត៌មានដែលទទួលបានការការពារត្រូវតែជាកម្មវត្ថុនៃវិធានការនៅក្នុងកាលៈទេសៈមួយ

---

[57] Darwin Hem & Long Keopichchenda, "IP Protection in Cambodia (update 2017)" [ការការពារកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា (បច្ចុប្បន្នភាពឆ្នាំ២០១៧)], BNG Legal, (មេសា ២០១៧), ទំព័រ ៤, http://bnglegal.com/cn/wp-content/uploads/2017/04/170403-IP-Protection-in-Cambodia-Update-2017.pdf (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨) ។

[58] WIPO, Patent or Trade Secrets? [ប្រកាសនីយបត្រតក្កកម្ម ឬការសម្ងាត់ពាណិជ្ជកម្ម?], ចូលមើលចុងក្រោយ ១៥ មិថុនា ២០១៨, http://www.wipo.int/sme/en/ip_business/trade_secrets/patent_trade.htm ។

[59] ដដែល។

ដើម្បីរក្សាព័ត៌មានជាសម្ងាត់។[60] ក្នុងពេលបង្កើតកិច្ចសន្យា ដើម្បីទាញយកផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ហើយធ្វើយ៉ាងណានៅតែអាចរក្សាការសម្ងាត់នៃព័ត៌មាននោះបាន ទើបមិនបាត់បង់លក្ខណៈនៃការសម្ងាត់របស់វា។ ការសម្ងាត់ពាណិជ្ជកម្មពុំមានរយៈពេលកំណត់នៃការការពារនោះទេ ប្រសិនបើព័ត៌មាននោះត្រូវបានចុះបញ្ជីដើម្បីការពារ នោះវាលែងជាការសម្ងាត់ពាណិជ្ជកម្មទៀតហើយ ដោយសារព័ត៌មានទាំងឡាយត្រូវបានបង្ហាញនៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីការពារ។

### ១.២.៤. ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ

#### ១.២.៤.១. សញ្ញាណទូទៅ

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬរូបភាពផ្សេងៗទៀតមានលក្ខណៈញែកដាច់ ដែលជាឈ្មោះឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្រ្តមួយ ហើយឈ្មោះ សញ្ញាសម្គាល់ និង/ឬរូបភាពនោះ សម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិ-សាស្រ្តនោះ ដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញ ដែលកើតចេញពីតំបន់ភូមិសាស្រ្តនោះ។[61] ទំនិញសម្គាល់ភូមិសាស្រ្ត សំដៅដល់ទំនិញពាក់ម៉ាកសម្គាល់ភូមិសាស្រ្ត ដែលបានចុះបញ្ជីរួច។[62]

#### ១.២.៤.២. លក្ខខណ្ឌនៃការទទួលបានការការពារ

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ អាចអនុវត្តន៍លើការចុះបញ្ជី និងកិច្ចការពារចំពោះទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀត ដែលផលិតក្នុងតំបន់ភូមិ-សាស្រ្ត ឬកែច្នៃស្របតាមបទប្បញ្ញត្តិនៃច្បាប់។[63]

ការការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញស្ថិតក្រោមការការពារនៃក្របខ័ណ្ឌជាតិនៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ តាមរយៈការចុះបញ្ជី។ សម្រាប់រយៈពេលនៃការការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ មានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជីជារៀងរហូតទៅ។[64]

#### ១.២.៤.៣. សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ

ក្រោយពីបានចុះបញ្ជី សមាជិកសមាគមសម្គាល់ភូមិសាស្រ្តទំនិញដែលជាផលិតករ និង/ឬប្រតិបត្តិករដែលអនុវត្តន៍ស្របតាមសៀវភៅបន្ទុក មានសិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញនោះ ហើយសិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញមិនអាចផ្ទេរបានឡើយ។ ដូច្នេះម្ចាស់ម៉ាក

---

[60] ដូច១៧, ទំព័រ២៤៥។

[61] ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ, លេខ នស/រកម/០១១៤/០០៦, ២០ មករា ២០១៤, មាត្រា ៤, ពីពេលនេះតទៅហៅថា ច្បាប់ម៉ាកភូមិសាស្រ្តទំនិញ។

[62] ច្បាប់ម៉ាកភូមិសាស្រ្តទំនិញ, មាត្រា ៤។

[63] ច្បាប់ម៉ាកភូមិសាស្រ្តទំនិញ, មាត្រា ៣។

[64] ច្បាប់ម៉ាកភូមិសាស្រ្តទំនិញ, មាត្រា ២៤។

សម្គាល់ភូមិសាស្ត្រទំនិញមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះអំពើរំលោភបំពានលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ លុះណាតែមានការអនុញ្ញាតពីម្ចាស់សិទ្ធិចំពោះការប្រើប្រាស់នោះ។[65] ការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សំដៅដល់ការស្នើលក់ ការផលិត ការដាក់លក់ ការនាំចេញ និងការនាំចូលទំនិញសម្គាល់ភូមិសាស្ត្រ។[66]

### **១.២.៥. សិទ្ធិអ្នកបង្កាត់ពូជដំណាំ**

#### **១.២.៥.១. សញ្ញាណទូទៅ**

អ្នកបង្កាត់ពូជដំណាំ មានសិទ្ធិការពារពូជដំណាំដែលមានស្រាប់ និងពូជថ្មីនៃដំណាំតាមរយៈសិទ្ធិដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

ពូជដំណាំ សំដៅដល់រាល់មេជីវិតបន្តពូជ(អូវ៉ុលពេញវ័យ) ដែលមានបំណែកអំព្រីយ៉ុង សារធាតុចិញ្ចឹម និងសំបកការពារគ្រាប់ពូជ ឬសរីរាង្គដាំដុះមួយ ដែលត្រូវបានយកទៅប្រើប្រាស់ក្នុងការសាប ការបណ្តុះ ឬការដាំសម្រាប់ផលិតកម្មដំណាំ ទោះបីជាការបន្តពូជនោះធ្វើឡើងដោយភេទក្តី ឬអភេទក្តី ដោយរួមបញ្ចូលនូវរាល់ចំណាត់ថ្នាក់នៃគ្រាប់ពូជដំណាំ ឬសរីរាង្គបន្តពូជ (ក្នុងនោះមានពូជដំណាំស្បៀង ដំណាំឧស្សាហកម្ម ដំណាំប្រេង ដំណាំចំណីសត្វ ឬផ្កា និងដំណាំលម្អជាអាទិ៍) និងរួមបញ្ចូលនូវកូនបណ្តុះ ឬសំណាប មើម ឫសបំណែករុក្ខជាតិ សរីរាង្គផ្សាររុក្ខជាតិ ដែលបង្កាត់ដោយលក្ខណៈមីក្រូ និងរាល់បណ្តាសរីរាង្គបង្កាត់ដោយលក្ខណៈសរីរាង្គ។[67]

#### **១.២.៥.២. លក្ខខណ្ឌទទួលបានការការពារ**

ការការពារពូជដំណាំចាំបាច់ត្រូវមានការចុះបញ្ជី ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ។[68] ពូជថ្មីនៃដំណាំទទួលបានសិទ្ធិការពារត្រូវមានលក្ខខណ្ឌចម្បងបួនគឺ ភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព។[69]

- **ភាពថ្មី** សំដៅដល់ពូជដំណាំ ដែលពុំទាន់បានដាក់លក់ ឬចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី ១ឆ្នាំ និងមិនលើសពី៦ឆ្នាំចំពោះដំណាំវល្លិ៍ និងដំណាំឈើ ហើយមិនលើសពី៤ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងៗទៀត គិតដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ។[70]
- **ភាពខុសប្លែក** សំដៅដល់ពូជដំណាំដែលខុសគ្នាដាច់ពីពូជផ្សេងទៀត។[71]

---

[65] ច្បាប់ម៉ាកភូមិសាស្ត្រទំនិញ, មាត្រា ២២។

[66] ច្បាប់ម៉ាកភូមិសាស្ត្រទំនិញ, មាត្រា ៨។

[67] ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, លេខ នស/រកម/០៥០៨/០១៥, ១៣ ឧសភា ២០០៨, ឧបសម្ព័ន្ធ, ពីពេលនេះតទៅហៅថា ច្បាប់គ្រប់គ្រងពូជដំណាំ។

[68] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ១១។

[69] ច្បប់គ្រប់គ្រងពូជដំណាំ, មាត្រា ៦។

[70] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ៧។

[71] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ៨។

- **ឯកសណ្ឋានភាព** សំដៅលើពូជដំណាំ ដែលអាចរក្សាឯកសណ្ឋានភាពគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះ ត្រូវបានផលិតតាមរយៈភេទ ឬអភេទក្តី។[72]
- **ស្ថេរភាពនៃពូជដំណាំ** ត្រូវមានចរិតលក្ខណៈចាំបាច់ដែលគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ។[73]

#### ១.២.៥.៣. សិទ្ធិអ្នកបង្កាត់ពូជដំណាំថ្មី

ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមានសិទ្ធិលក់ ឬផ្ទេរសិទ្ធិរបស់ខ្លួនបាន។[74] សិទ្ធិការពារពូជថ្មីនៃដំណាំ មិនការពារទៅលើការប្រើប្រាស់ក្នុងគោលបំណងពិសោធន៍ ឬការដាំសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងគ្មានបំណងធ្វើពាណិជ្ជកម្ម ឬការប្រើប្រាស់ក្នុងគោលបំណងបង្កាត់ពូជដំណាំថ្មីផ្សេងទៀត[75] លើកលែងពូជដែលបានបង្កើតថ្មី ដោយយកលក្ខណៈពិសេសសំខាន់ៗចេញពីពូជបានការពារ ឬពូជដែលពុំមានភាពខុសគ្នាដាច់ស្រឡះពីពូជបានការពារ ឬពូជដែលផលិតកម្មរបស់វាត្រូវការប្រើប្រាស់ឡើងវិញនូវពូជដែលបានការពារ។[76]

[72] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ៩។

[73] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ១០។

[74] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ១៤។

[75] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ១៦។

[76] ច្បាប់គ្រប់គ្រងពូជដំណាំ, មាត្រា ១៥។

# ជំពូកទី២

# ការរៀបផៀបយុទ្ធសាស្ត្រ
# នៃការបង្កើតប្រព័ន្ធ
# ចុះបញ្ជីកម្មសិទ្ធិបញ្ញា
# សហភាពអឺរ៉ុប និងតំបន់
# អាស៊ាន

# ជំពូកទី២៖ ការប្រៀបធៀបយុទ្ធសាស្ត្រនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប និងតំបន់អាស៊ាន

## ២.១. សហភាពអឺរ៉ុប

### ២.១.១. ប្រវត្តិនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញា

សហភាពអឺរ៉ុប ត្រូវបានបង្កើតដោយមូលហេតុសេដ្ឋកិច្ចក្នុងតំបន់ សម្រាប់ប្រទេសដែលជាសមាជិករបស់ខ្លួនជាជាងមូលហេតុស្ថេរភាពនយោបាយ ដូចទៅនឹងការបង្កើតសមាគមប្រជាជាតិ-អាស៊ីអាគ្នេយ៍(អាស៊ាន)។ ទោះជាយ៉ាងណា ការរីកចម្រើនក្នុងសហភាពអឺរ៉ុប ក៏ជាចំណែកមួយដែលកើតចេញពីភាពរីកដុះដាលនៃការធ្វើពាណិជ្ជកម្មលើវិស័យកម្មសិទ្ធិបញ្ញាដែរ។

ការកើតឡើងកម្មសិទ្ធិបញ្ញាថ្នាក់តំបន់របស់សហភាពអឺរ៉ុប បានកើតឡើងអំឡុងសតវត្សទី១៨ និង១៩ ដោយសារការធ្វើបដិវត្តឧស្សាហកម្ម ប៉ុន្តែក្រោយមកមានឱកាសថ្មីក្នុងការផលិតឡើងវិញនូវបច្ចេកវិទ្យា ឬរូបភាព និងឯកសារផ្សេងទៀត ហើយអ្នកនិពន្ធ និងទស្សនវិទូ កើតឡើងកាន់តែច្រើនទៅៗ ដោយពួកគេបានទាមទារឱ្យមានការការពារទៅលើស្នាដៃរបស់ពួកគេទាំងនោះ។ ទាំងអស់នេះ បានបង្កើតឱ្យទៅជាគំនិតរក្សានូវកម្មសិទ្ធិបញ្ញា ដែលដំណាលគ្នានឹងការអភិវឌ្ឍកម្មសិទ្ធិបញ្ញាក្នុងសហរដ្ឋអាមេរិក និងអាមេរិកឡាទីន។ ម្យ៉ាងវិញទៀត ដោយសារតែមានបញ្ហាជាច្រើនបានកើតឡើងជុំវិញផ្នែកនេះ ទើបនាំឱ្យមានការរឹតបន្តឹងការនាំចេញនាំចូលផលិតផល ក៏ដូចជាការនាំស្នាដៃទៅកាន់ទឹកដីនៃប្រទេសនីមួយៗ ហើយមានការបង្កើតកាន់តែច្រើននូវកិច្ចការពារពាណិជ្ជកម្មជាអន្តរជាតិ។[77]

កម្មសិទ្ធិបញ្ញានៅក្នុងសហភាពអឺរ៉ុប បានកកើតក្រោយអនុសញ្ញាអន្តរជាតិរបស់អង្គការកម្ម-សិទ្ធិបញ្ញាពិភពលោក ត្រូវបានបង្កើតឡើង ដូចជាអនុសញ្ញាទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ឆ្នាំ១៨៨៣ អនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈឆ្នាំ១៨៨៦ ជាដើម។ ក្រោយមកឃើញមានបទដ្ឋានគតិយុត្តមួយចំនួនរបស់សហភាពអឺរ៉ុប ដែលត្រូវបានបង្កើតឡើង ដែលក្នុងនោះមាន អនុសញ្ញាស្តីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឆ្នាំ១៩៧៣ និងបទប្បញ្ញត្តិទាក់ទងនឹងម៉ាកក្នុងតំបន់ជាដើម។

### ២.១.២. ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកចុះបញ្ជី

#### ២.១.២.១. ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (European Union Intellectual Property Office, “EUIPO”)

##### ២.១.២.១.១. អំពីការិយាល័យ

ក្នុងឆ្នាំ១៩៩៤ ការិយាល័យសម្រាប់ការធ្វើសុខដុមនីយកម្មទីផ្សារផ្ទៃក្នុង (Office for

[77] Stefen Matin, “Introduction to International Intellectual Property” [សេចក្តីផ្តើមកម្មសិទ្ធិបញ្ញាអន្តរជាតិ], (១២ កញ្ញា ២០១៦), ទំព័រ ៤។

Harmonization in the Internal Market (OHIM)) ត្រូវបានបង្កើតឡើង ហើយចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ក៏បានប្រែក្លាយជា ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EUIPO) វិញ។ ការិយាល័យនេះ គឺជាភ្នាក់ងារវិមជ្ឈការ ដែលផ្តល់នូវសិទ្ធិការពារកម្មសិទ្ធិបញ្ញាក្នុងសហភាពអឺរ៉ុប សម្រាប់អ្នកជំនួញ និងអ្នកច្នៃប្រឌិតថ្មីៗនៅក្នុង និងក្រៅសហភាពអឺរ៉ុប។[78]

ការិយាល័យនេះមានទីតាំងនៅ ទីក្រុង អាលីខានតេ (Alicante) នៃប្រទេសអេស្ប៉ាញ ហើយ ការិយាល័យនេះផងដែរ ធ្វើការគ្រប់គ្រងទៅលើការចុះបញ្ជីម៉ាក និងគំនូរឧស្សាហកម្មសហគមន៍ (Community design)។[79]

### ២.១.២.១.២. ដំណើរការនៃការចុះបញ្ជីនៃប្រភេទកម្មសិទ្ធិបញ្ញានីមួយៗ

❖ **នីតិវិធីការចុះបញ្ជីម៉ាក**

គ្រប់រូបវន្តបុគ្គល ឬនីតិបុគ្គលរបស់ប្រទេសទាំងឡាយអាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុង សហភាពអឺរ៉ុបបាន។ សម្រាប់ការដាក់ពាក្យស្នើសុំ ត្រូវដាក់ពាក្យផ្ទាល់ទៅការិយាល័យកម្មសិទ្ធិ បញ្ញាសហភាពអឺរ៉ុប តាមរយៈការបំពេញពាក្យអនឡាញ ប្រៃសណីយ៍ ឬទូរសារ (ប៉ុន្តែតាមរយៈទូរ-សារមានភាពតឹងរ៉ឹង)។ ការចុះបញ្ជីម៉ាកក្នុងសហភាពអឺរ៉ុប អាចធ្វើទៅបានតាមរយៈ ពាក្យស្នើសុំអន ឡាញដោយប្រើប្រាស់កម្មវិធី Fast Track ឬបំពេញពាក្យស្នើសុំអនឡាញធម្មតា ដែលតម្លៃនៃការចុះ បញ្ជីមានតារាងបញ្ជាក់តម្លៃស្រាប់ ក្នុងគេហទំព័ររបស់ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប។ ភាសាដែលត្រូវបានប្រើក្នុងពាក្យស្នើសុំមានរហូតទៅដល់ ២៣ភាសា ប៉ុន្តែប្រសិនបើអ្នកស្នើសុំប្រើ ប្រាស់ភាសាទីពីរវិញ ត្រូវប្រើភាសា អង់គ្លេស បារាំង អាឡឺម៉ង់ អ៊ីតាលី ឬអេស្ប៉ាញ ហើយតម្លៃនៃ ពាក្យស្នើសុំនីមួយៗអាស្រ័យលើប្រភេទម៉ាក និងចំនួនម៉ាកដែលនឹងត្រូវចុះបញ្ជី។[80]

ការចុះបញ្ជីម៉ាកក្នុងសហភាពអឺរ៉ុប គឺជានីតិវិធី ដែលត្រូវពិនិត្យទៅលើចំណុចសំខាន់បួនគឺ ការពិនិត្យលើពាក្យស្នើសុំ ការត្រួតពិនិត្យបច្ចេកទេសលម្អិត ការបោះពុម្ពផ្សាយពាក្យស្នើសុំ និងនីតិ-វិធីបន្ទាប់រហូតដល់ការចុះបញ្ជី ដែលអាចមានការជំទាស់ពីតតិយជន។[81]

**-ការពិនិត្យពាក្យស្នើសុំ**

ការពិនិត្យពាក្យស្នើសុំ គឺជាការពិនិត្យថាតើ មានឬមិនមានកាលបរិច្ឆេទនៃការដាក់ពាក្យ ចំណាត់ថ្នាក់នៃទំនិញ ឬសេវាកម្មដែលបានបង្ហាញក្នុងពាក្យស្នើសុំ និងទម្រង់នៃពាក្យស្នើសុំនោះ បានបំពេញគ្រប់គ្រាន់ហើយឬនៅ។

---

[78] EUIPO, The Office [ការិយាល័យ], ចូលមើលចុងក្រោយ ២៨ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/the-office។

[79] ដដែល។

[80] EUIPO, Application Procedure [នីតិវិធីនៃការដាក់ពាក្យ], ចូលមើលចុងក្រោយ ២៨ មិថុនា ២០១៨ https://euipo.europa.eu/ohimportal/en/application-procedure #2.A.1។

[81] EUIPO, European Union trade mark registration procedure [នីតិវិធីនៃការចុះបញ្ជីម៉ាកពាណិជ្ជកម្មនៃសហភាពអឺរ៉ុប], ចូលមើលចុងក្រោយ ២៨ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/eutm-registration-procedure#5.1។

**- ការត្រួតពិនិត្យបច្ចេកទេសលម្អិត**

បន្ទាប់មកផ្ញើបញ្ជីទំនិញ និងសេវាកម្ម ទៅកាន់មជ្ឈមណ្ឌលបកប្រែរបស់ស្ថាប័នសហភាពអឺរ៉ុប (ប្រទេស លុចសំបួរ) ធ្វើរបាយការស្រាវជ្រាវ (ប្រសិនបើមាន) ដែលកន្លែងស្រាវជ្រាវថ្នាក់ជាតិបានស្នើឡើង ហើយផ្ញើពាក្យសុំទៅកាន់ការិយាល័យកម្មសិទ្ធិឧស្សាហកម្មកណ្ដាលនៃបណ្ដាប្រទេសជាសមាជិករបស់សហភាពអឺរ៉ុបសម្រាប់ការស្រាវជ្រាវ។ តទៅទៀត ការបញ្ជូនរបាយ-ការណ៍ទាំងអស់ត្រឡប់ទៅកាន់អ្នកស្នើសុំ ឬអ្នកតំណាងវិញ ហើយធ្វើការពិនិត្យមូលហេតុដាច់ខាតសម្រាប់ការបដិសេធ។[82]

**-ការបោះផ្សាយពាក្យស្នើសុំ**

ក្នុងដំណាក់កាលនេះ ប្រសិនបើម៉ាកដែលបានស្នើសុំចុះបញ្ជីត្រូវបានពិនិត្យឃើញថាត្រឹមត្រូវហើយ ពាក្យស្នើសុំនោះនឹងត្រូវបានធ្វើការបោះពុម្ពផ្សាយ។[83]

**-ការជំទាស់**

ការជំទាស់នេះអាចធ្វើទៅបាន ប្រសិនបើតតិយជនពុំសុខចិត្តនឹងការបោះពុម្ពផ្សាយពាក្យស្នើសុំ ហើយក្រោយពីការបោះពុម្ពផ្សាយក្នុងរយៈពេលបីខែ ប្រសិនបើពុំមានជំទាស់ ឬជំទាស់ត្រូវបានបញ្ចប់នោះ ម៉ាកនឹងត្រូវបានចុះបញ្ជី។[84]

❖ **ការចុះបញ្ជីគំនូរឧស្សាហកម្មសហគមន៍**

ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មសហគមន៍ គ្រប់រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយណាដែលមានបំណងចុះបញ្ជីនៅសហភាពអឺរ៉ុប អាចធ្វើការដាក់ពាក្យស្នើសុំបាន។[85] វិធី-សាស្ត្រ ដែលលឿនក្នុងការដាក់ពាក្យស្នើសុំគឺ ការចុះបញ្ជីតាមអនឡាញ ហើយអ្នកស្នើសុំមានជម្រើសនៃការប្រើប្រាស់ភាសា។[86]

គំនូរឧស្សាហកម្មសហគមន៍ដែលបានចុះបញ្ជី ផ្ដល់សិទ្ធិផ្ដាច់មុខទាំងសមាជិកបច្ចុប្បន្ន និងអនាគតសមាជិកភាពរបស់សហភាពអឺរ៉ុប នៅពេលដែលគេចុះបញ្ជី។ ការការពារគំនូរឧស្សាហកម្មសហគមន៍នៅអឺរ៉ុបមានសុពលភាព៥ឆ្នាំ ដែលអាចបន្តបានយ៉ាងច្រើន២៥ឆ្នាំ ប៉ុន្តែក្នុងការបន្តសុពលភាពម្ដងមានរយៈពេល៥ឆ្នាំដូចគ្នា។[87]

---

[82] ដដែល។

[83] ដដែល។

[84] ដដែល។

[85] EUIPO, Registered Community design applications [ពាក្យស្នើសុំចុះបញ្ជីគំនូរសហគមន៍], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimpo rtal/en/registered-community-design-applications ។

[86] EUIPO, E-filing [ការដាក់ពាក្យសុំតាមប្រព័ន្ធអេឡិចត្រូនិច], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/e-filing។

[87] EUIPO, Design, Apply now [ដាក់ពាក្យឥឡូវ], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/rcd-apply-now។

មិនខុសគ្នាពីការចុះបញ្ជីម៉ាកទេ ការចុះបញ្ជីគំនូរឧស្សាហកម្មសហគមន៍អាចប្រព្រឹត្តទៅបានតាមរយៈការដាក់ពាក្យស្នើសុំ ការពិនិត្យលើពាក្យស្នើសុំ ការត្រួតពិនិត្យបច្ចេកទេសលម្អិត និងការប្តឹងទាស់។

**-ការដាក់ពាក្យស្នើសុំ**

ការដាក់ពាក្យស្នើសុំចុះបញ្ជីគំនូរសហគមន៍ អាចធ្វើឡើងតាមវិធីអនឡាញ ដែលជាវិធីងាយស្រួលតាមរយៈកម្មវិធី Fast Track។ ប៉ុន្តែការដាក់ពាក្យសុំក៏អាចធ្វើទៅបានតាមទូរសារ ប្រៃសនីយ ឬការបំពេញពាក្យសុំដោយយកទៅកាន់ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប។[88] តម្លៃនៃការចុះបញ្ជីគំនូរឧស្សាហកម្ម អាស្រ័យលើចំនួននៃគំនូរឧស្សាហកម្មដែលស្នើសុំឱ្យមានការការពារនោះ។[89]

**-ការពិនិត្យលើពាក្យស្នើសុំ**

ក្រោយពេលដាក់ពាក្យស្នើសុំ ការិយាល័យនឹងធ្វើការពិនិត្យលើពាក្យស្នើសុំ ដែលផ្តោតលើពីរចំណុច។ ចំណុចទី១ គឺការពិនិត្យឯកសារ និងចំណុចទី ២ គឺការត្រួតពិនិត្យបច្ចេកទេសលម្អិត។[90]

ការពិនិត្យឯកសារ តម្រូវឱ្យមានការពិនិត្យត្រឹមត្រូវមួយ នៅពេលអ្នកពិនិត្យរកឃើញថាមានបញ្ហាណាមួយក្នុងពាក្យស្នើសុំ ការិយាល័យនឹងឆ្លើយតបឱ្យកែប្រែលើពាក្យស្នើសុំ ហើយអ្នកដាក់ពាក្យស្នើសុំអាចឆ្លើយតបត្រឡប់មកវិញក្នុងរយៈពេលពីរខែ និងអាចពន្យាពេលបានប្រសិនបើមានការអនុញ្ញាត។

**-ការត្រួតពិនិត្យបច្ចេកទេសលម្អិត**

ការត្រួតពិនិត្យបច្ចេកទេសលម្អិត ផ្តោតលើការពិនិត្យចំណុចសំខាន់ពីរ ថាតើគំនូរដែលបានដាក់ពាក្យមកនោះពិតជាត្រូវបានចាត់ទុកថាជាគំនូរឧស្សាហកម្មមែនយ៉ាងណា និងលក្ខខណ្ឌនៃគំនូរសហគមន៍នោះ ថាតើមានលក្ខណៈផ្ទុយនឹងគោលនយោបាយ ឬសីលធម៌សង្គមឬយ៉ាងណា។

**-ការប្តឹងទាស់**

ក្នុងការប្តឹងជំទាស់ តតិយជនអាចបំពេញទៅតាមទម្រង់ជំទាស់ដែលមានស្រាប់ ហើយអាចធ្វើការប្រឹក្សាយោបល់បានប្រសិនបើចាំបាច់។ ការប្តឹងទាស់នេះផងដែរ ទាមទារឱ្យមានការផ្តល់ហេតុផល ឬភស្តុតាង ហើយការប្តឹងទាស់នេះអាចធ្វើតាមប្រព័ន្ធអនឡាញបាន។[91]

---

[88] EUIPO, Application and Registration Procedure [ពាក្យស្នើសុំ និងនីតិវិធីនៃការចុះបញ្ជី], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/registered-community-design-applications ។

[89] EUIPO, Fee and Payment [កម្រៃ និងការបង់ប្រាក់], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/fees ។

[90] EUIPO, Registration Process [ដំណើរការចុះបញ្ជី], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/rcd-registration-process ។

[91] ដដែល, https://euipo.europa.eu/ohimportal/en/rcd-registration-process#examination06-4។

### **២.១.២.២. ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប** (European Patent Office, "EPO")

#### **២.១.២.២.១. អំពីការិយាល័យ**

ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវបានបង្កើតឡើងដោយអនុសញ្ញាប្រកាស-នីយបត្រតក្កកម្មអឺរ៉ុប (European Patent Convention (EPC)) ក្នុងថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៧៣ និងចាប់ផ្តើមដំណើរការក្នុងឆ្នាំ១៩៧៧។[92]

នៅក្នុងការិយាល័យនេះទៀតសោត អ្នកប្រើប្រាស់អាចស្វែងរកប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជីពីមុន ហើយធ្វើការដាក់ពាក្យស្នើសុំអនឡាញបានតាមគេហទំព័ររបស់ការិយា-ល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប «http://www.epo.org/»។

ការិយាល័យនេះ មានការិយាល័យកណ្តាលនៅទីក្រុងមុយនិច(Munich) ប្រទេសអាឡឺម៉ង់ និងមានសាខាមួយទៀតនៅប្រទេសហូឡង់។ ការិយាល័យនេះ ទទួលពាក្យស្នើសុំទាំងឡាយណាដែលយកគំរូតាម EPC និង PCT ប៉ុន្តែសម្រាប់ភាសាផ្លូវការនៃពាក្យស្នើសុំអាចប្រើប្រាស់ជាភាសាអង់គ្លេស អាឡឺម៉ង់ ឬបារាំង។

#### **២.១.២.២.២. ដំណើរការនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម**

ក្នុងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម អាចធ្វើទៅបានតាមវិធីអនឡាញ ដែលការចុះបញ្ជីនោះអាចជ្រើសរើសបានសម្រាប់អ្នកប្រើប្រាស់ ដើម្បីធ្វើការចុះបញ្ជីថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់អន្តរ-ជាតិ។[93]

ការស្នើសុំចុះបញ្ជីថ្នាក់ជាតិ អ្នកប្រើប្រាស់អាចជ្រើសរើសប្រទេសណាមួយដែលគេចង់ឱ្យមានការពារដល់តក្កកម្មរបស់ខ្លួន ហើយធ្វើការបំពេញពាក្យសុំទៅតាមបទប្បញ្ញត្តិនៃប្រទេសនោះ។

សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មថ្នាក់តំបន់ ក្នុងសហភាពអឺរ៉ុប មានបែបបទនៃការបំពេញពាក្យសុំរបស់ការិយាល័យប្រកាសនីយបត្រតក្កកម្ម ដែលមានទម្រង់លេខ១០០១ ហើយទម្រង់ពាក្យស្នើសុំអាចបំពេញអនឡាញ ឬ Case Management System (CMS)។[94]

ដោយឡែក ការដាក់ពាក្យស្នើសុំចុះបញ្ជីថ្នាក់អន្តរជាតិ ប្រព្រឹត្តទៅតាមបែបបទរបស់PCT។

នីតិវិធីនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មក្នុងសហភាពអឺរ៉ុប ជំហានដំបូងត្រូវពិនិត្យលើលក្ខខណ្ឌនៃតក្កកម្មថាតើតក្កកម្មនោះថ្មី មានជំហានរកឃើញថ្មី និងអាចអនុវត្តន៍បានក្នុង

---

[92] EPO, The history of the EPO [ប្រវត្តិនៃEPO], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www. epo.org/about-us/timeline.html#year20142017 ។

[93] EPO, European Patent Register [ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.epo.org/searching-for-patents/legal/register.html#tab-2។

[94] ដដែល។

ឧស្សាហកម្មដែរឬទេ បន្ទាប់មកធ្វើការពិនិត្យលើពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលតម្រូវឱ្យមានសំណុំលិខិតស្នើសុំ ពាក្យសុំ សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញប្រសិនបើមាន និងខ្លឹមសារសង្ខេប។[95]

មុននឹងផ្តល់នូវប្រកាសនីយបត្រតក្កកម្ម ការិយាល័យនឹងធ្វើការពិនិត្យលើពាក្យស្នើសុំ ការស្រាវជ្រាវ បោះផ្សាយនូវពាក្យស្នើសុំ ការត្រួតពិនិត្យបច្ចេកទេសលម្អិត ការផ្តល់នូវប្រកាសនីយ-បត្រតក្កកម្ម និងបណ្តឹងទាស់។[96]

## ២.២. ប្រៀបធៀបយុទ្ធសាស្រ្តនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប និងតំបន់អាស៊ាន

### ២.២.១. មូលហេតុនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួម

#### ២.២.១.១. ឆន្ទៈរបស់រដ្ឋសមាជិកក្នុងតំបន់

ឆន្ទៈរបស់រដ្ឋជាសមាជិកក្នុងតំបន់ សំដៅដល់ការប្តេជ្ញាទទួលយកបទដ្ឋានអន្តរជាតិ ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា។ នៅក្នុងសហភាពអឺរ៉ុប រដ្ឋជាសមាជិកបានផ្តល់សច្ចាប័ន និងទទួលយកបទដ្ឋានអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្ទើរតែទាំងអស់ ដែលការទទួលយកនូវបទដ្ឋានគតិយុត្តនេះ ស្តែងឱ្យឃើញពីលទ្ធភាពនៃប្រទេសនីមួយៗ ក្នុងការផ្តល់ការការពារកម្មសិទ្ធិបញ្ញា តួយ៉ាងដូចជា ប្រទេសបារាំងបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម កិច្ចព្រមព្រៀងទីក្រុងនីស កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត ជាអាទិ៍។[97]

ផ្ទុយស្រឡះពីសមាជិករបស់អាស៊ាន ដែលបានទទួលយកបទដ្ឋានអន្តរជាតិស្តីពីការការពារកម្មសិទ្ធិបញ្ញាមួយចំនួនតែប៉ុណ្ណោះ ដែលស្តែងឱ្យឃើញពីភាពមិនស្មើគ្នារវាងការទទួលយកបទដ្ឋានអន្តរជាតិពីបណ្តាប្រទេសសមាជិកអាស៊ាន ប៉ុន្តែទោះជាយ៉ាងណាក៏សមាជិកអាស៊ានភាគច្រើនបានទទួលយកបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាសំខាន់ៗរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកដែរ លើកលែងតែប្រទេសភូមាមួយទេ ដែលចូលត្រឹមជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហើយពុំទាន់ទទួលយកនូវបទដ្ឋានអន្តរជាតិរបស់អង្គការនេះទេ។[98]

---

[95] ដដែល។

[96] EPO, How to apply for a European patent [របៀបនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.epo.org/applying/basics.html។

[97] WIPO, WIPO-Administered treaties [សន្ធិសញ្ញាដែលគ្រប់គ្រងដោយអង្គការ WIPO], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.wipo.int/treaties/en/ ShowResults.jsp?country_id=60C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C។

[98] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=116C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

### ២.២.១.២. សេដ្ឋកិច្ចតំបន់

ក្នុងឆ្នាំ២០១៦ ផលិតផលក្នុងស្រុកសរុប(Gross Domestic Product (GDP)) សរុបក្នុងតំបន់អាស៊ានមានប្រមាណ ២.៥៧ពាន់ពាន់លានដុល្លាអាមេរិក[99] បើប្រៀបធៀបនឹងសហភាពអឺរ៉ុបប្រមាណ ១៧.៣៨ពាន់ពាន់លានដុល្លាអាមេរិក[100] ដែលនេះឆ្លុះបញ្ចាំងពីគម្លាតសេដ្ឋកិច្ចនៃសហគន៍ទាំងពីរ។

ការអភិវឌ្ឍរបស់ប្រទេសជាសមាជិកសហភាពអឺរ៉ុប មានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលជាកត្តាជំរុញឱ្យសហភាពអឺរ៉ុប កាន់តែមានភាពឆាប់រហ័ស ក្នុងការបង្កើតបាននូវសេចក្តីសម្រេចរួមមួយ មិនត្រឹមតែប៉ុណ្ណោះ រាល់សមាជិករបស់សហភាពអឺរ៉ុបសុទ្ធតែជាប្រទេសអភិវឌ្ឍន៍ ដែលមានភាពជឿនលឿនស្ទើគ្រប់វិស័យ ជាពិសេសការរីកចម្រើននៃវិស័យបច្ចេកវិទ្យា ដែលជាកត្តាធ្វើឱ្យ សហភាពអឺរ៉ុបពង្រឹងការការពារកម្មសិទ្ធិបញ្ញាឱ្យកាន់តែប្រសើរ។

ដោយឡែក ក្នុងតំបន់អាស៊ានវិញ សមាជិកសុទ្ធតែជាប្រទេសកំពុងអភិវឌ្ឍន៍ ពុំមានភាពរីកចម្រើនខ្លាំងចំពោះវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យានោះទេ បើប្រៀបនឹងសហភាពអឺរ៉ុប ប៉ុន្តែទោះជាយ៉ាងណា ក្នុងតំបន់អាស៊ានក៏ឃើញមានការរីកចម្រើននូវវិស័យកសិកម្ម សេវាកម្ម និងឧស្សាហកម្មមួយចំនួន ដែលជាកត្តាលីករនៃការអភិវឌ្ឍក្នុងតំបន់។ ការរំលោភបំពានកម្មសិទ្ធិបញ្ញាក៏ងាយស្រួលកើតឡើងផងដែរ។

ប៉ុន្តែទំនាក់ទំនងរវាងតំបន់ទាំងពីរចំពោះវិស័យសេដ្ឋកិច្ច សហភាពអឺរ៉ុប គឺជាដៃគូពាណិជ្ជកម្មធំទី២របស់អាស៊ានបន្ទាប់ពីប្រទេសចិន ហើយអាស៊ានជាដៃគូពាណិជ្ជកម្មធំទី៣របស់សហភាពអឺរ៉ុបលើផលិតផលទំនិញ និងសេវាកម្ម ដែលមានចំនួនទឹកប្រាក់លើសពី ៣២៣.៩៦ពាន់លានដុល្លាអាមេរិក។[101]

---

[99] The Statistics Portal, Gross domestic product (GDP) of the ASEAN countries from 2008 to 2018 (in billion U.S. dollars) [ផលិតផលក្នុងស្រុកសរុប (GDP) នៃប្រទេសជាសមាជិកអាស៊ាន ពីឆ្នាំ ២០០៨ ដល់ ២០១៨ (គិតជាពាន់លានដុល្លាអាមេរិក)], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.statista.com/statistics/796245/gdp-of-the-asean-countries/ ។

[100] The Statistics Portal, European Union: Gross domestic product (GDP) in current prices from 2006 to 2016 (in trillion euros) [សហភាពអឺរ៉ុប៖ ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងតម្លៃបច្ចុប្បន្ន ពីឆ្នាំ២០០៦ ដល់ ២០១៦ (គិតជាពាន់ពាន់លានអឺរ៉ូ)], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.statista.com/statistics/279447/gross-domestic-product-gdp-in-the-european-union-eu/ ។

[101] European Commission, Counties and regions, Association of South East Asian Nations (ASEAN) [សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN)], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://ec.europa.eu/trade/policy/countries-and-regions/regions/asean/ ។

### ២.២.២. ដំណាក់កាលនៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួម

#### ២.២.២.១. ការអនុម័តបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

ជាក់ស្តែង សហភាពអឺរ៉ុប ដែលមានប្រព័ន្ធកម្មសិទ្ធិបញ្ញានោះ សុទ្ធតែកើតបន្ទាប់ពីការកកើតនៃអនុសញ្ញាទីក្រុងប៉ារីសរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងបទដ្ឋានអន្តរជាតិផ្សេងទៀត។ មានន័យថា ក្រោយពីសមាជិករបស់សហភាពអឺរ៉ុបបានចូលជាសមាជិក ក៏ដូចជាផ្តល់សច្ចាប័នទៅលើបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា សហភាពអឺរ៉ុបក៏មានទិសដៅការពារកម្មសិទ្ធិបញ្ញាក្នុងតំបន់របស់ខ្លួន ដោយមានការបង្កើតនូវបទដ្ឋានគតិយុត្តក្នុងតំបន់របស់ខ្លួនសម្រាប់ការអនុវត្ត ដូចជា អនុសញ្ញាស្តីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងបទបញ្ញាស្តីពីម៉ាកពាណិជ្ជកម្មសហភាពអឺរ៉ុប (European Union Trade Mark Regulation) ជាដើម។ មុននឹងឈានដល់ការបង្កើតបាននូវបទប្បញ្ញត្តិទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជាពិសេសអនុសញ្ញាស្តីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប សហភាពអឺរ៉ុបបានពិភាក្សាជាច្រើនលើកច្រើនសារ និងប្រើរយៈពេលច្រើនជាង២០ឆ្នាំផងដែរ។[102]

ត្រង់ចំណុចនេះ អាស៊ានកំពុងតែធ្វើការខិតខំ ដើម្បីឱ្យសមាជិករបស់ខ្លួនទទួលយកបទដ្ឋានអន្តរជាតិផ្សេងៗរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីជាស្ពានក្នុងការបង្កើតនូវបទប្បញ្ញត្តិក្នុងតំបន់នាពេលអនាគត។ គួបញ្ជាក់ផងដែរថា អាស៊ានពុំទាន់មានបទប្បញ្ញត្តិរួមក្នុងតំបន់ ដើម្បីអនុវត្តន៍ការចុះបញ្ជីកម្មសិទ្ធិបញ្ញាថ្នាក់តំបន់នោះទេ អ្វីដែលអាស៊ានមានក្នុងពេលបច្ចុប្បន្ននោះ គឺមានតែកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ព្រមទាំងផែនការសកម្មភាពដែលមានការគាំទ្រដោយសហភាពអឺរ៉ុបផងដែរនោះ។

ភាពខុសគ្នាមួយទៀតរវាងសហភាពអឺរ៉ុប និងអាស៊ាន គឺឥទ្ធិពលរបស់សន្ធិសញ្ញា ឬបទដ្ឋានអន្តរជាតិក្រោយពេលដែលបានផ្តល់សច្ចាប័ន។ សហភាពអឺរ៉ុប នៅពេលដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា គ្រប់រដ្ឋជាសមាជិករបស់សហភាពអឺរ៉ុបនឹងត្រូវបានចងកាតព្វកិច្ចចំពោះសន្ធិសញ្ញានោះ ប៉ុន្តែខុសគ្នាពីអាស៊ានត្រង់ថា សន្ធិសញ្ញាដែលអាស៊ានបានផ្តល់សច្ចាប័នមានឥទ្ធិពលដល់បណ្តាសមាជិក លុះណាតែប្រទេសជាសមាជិកនោះ ធ្វើការផ្តល់សច្ចាប័នក្នុងការទទួលយកសន្ធិសញ្ញាមកអនុវត្តន៍ក្នុងប្រទេសរបស់ខ្លួន មិនដូច្នោះ វាគ្មានឥទ្ធិពលអ្វីដល់ប្រទេសជាសមាជិកអាស៊ានឡើយ ពីព្រោះ អាស៊ានគ្រាន់តែជាអង្គការអន្តររដ្ឋាភិបាលមួយដែលត្រូវបានផ្តល់បុគ្គលិកលក្ខណៈ ជាបុគ្គលភាពគតិយុត្តតែប៉ុណ្ណោះ។[103]

#### ២.២.២.២. ការបង្កើតស្ថាប័នទទួលបន្ទុកចុះបញ្ជី

សម្រាប់សហភាពអឺរ៉ុប ដែលបានប្រែក្លាយពីការចុះបញ្ជីកម្មសិទ្ធិបញ្ញាថ្នាក់ជាតិ ទៅជាការចុះបញ្ជីថ្នាក់តំបន់ ហើយសហភាពអឺរ៉ុបមានស្ថាប័នគ្រប់គ្រាន់ប្រកបដោយប្រសិទ្ធិភាពក្នុងការ

---

[102] ដូច ៩២។

[103] ធម្មនុញ្ញអាស៊ាន, ១៥ ធ្នូ ២០០៨, មាត្រា ៣។

ទទួលបន្ទុកនេះ។ ស្ថាប័នទទួលបន្ទុកចុះបញ្ជីកម្មសិទ្ធិបញ្ញានីមួយៗ មានសមត្ថកិច្ចទៅតាមប្រភេទនៃកម្ម-សិទ្ធិបញ្ញា ដូចជាការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប ទទួលបន្ទុកការចុះបញ្ជីម៉ាក និងគំនូរឧស្សាហកម្មជាដើម។ ក្នុងការបង្កើតស្ថាប័ននេះផងដែរ សហភាពអឺរ៉ុបមានការអនុម័តរួមគ្នាលើបទដ្ឋានគតិយុត្តនៃការបង្កើតស្ថាប័ននេះឡើង ដែលត្រូវឆ្លងកាត់ការសម្រេចចិត្តពី ក្រុមប្រឹក្សានៃសហភាពអឺរ៉ុប។ ក្រៅពីមានស្ថាប័នដែលទទួលបន្ទុកក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញា សហភាពអឺរ៉ុបបានជួយសម្រួលដល់អ្នកដាក់ពាក្យស្នើសុំ ដោយបានបង្កើតនូវការចុះបញ្ជីអនឡាញ និងការបង់ប្រាក់តាមកាតធនាគារ ដែលជាកត្តានាំឱ្យកម្មសិទ្ធិបញ្ញានៅក្នុងសហភាពអឺរ៉ុបកាន់តែរីកលូតលាស់ទៅបានយ៉ាងប្រសើរ។

ខុសពីអាស៊ាន ដែលពិបាកសូម្បីតែចេញសេចក្ដីសម្រេចរួមមួយក្នុងការដោះស្រាយបញ្ហាក្នុងតំបន់របស់ខ្លួន។ រហូតមកដល់ពេលបច្ចុប្បន្ន អាស៊ាននៅពុំទាន់មានស្ថាប័នទទួលបន្ទុកចុះបញ្ជីកម្មសិទ្ធិបញ្ញាសម្រាប់តំបន់អាស៊ានដូចទៅនឹងសហភាពអឺរ៉ុបឡើយទេ ប៉ុន្តែឃើញមានការបង្កើតការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិគ្រប់ប្រទេសទាំងអស់ សូម្បីតែប្រទេសភូមាដែលមិនបានទទួលយកបទដ្ឋានគតិយុត្តណាមួយឡើយ ក្រៅពីជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

ផ្ទុយទៅវិញ មិនថាសហភាពអឺរ៉ុបមានស្ថាប័នទទួលបន្ទុកចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងតំបន់ ហើយអាស៊ានគ្មានក៏ដោយ អាស៊ាននៅតែធ្វើការខិតខំឱ្យវិស័យកម្មសិទ្ធិបញ្ញារីកចម្រើនក្នុងតំបន់តាមរយៈការផ្ដល់នូវមធ្យោបាយក្នុងការស្រាវជ្រាវអំពីប្រភេទកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីការពាររួចរាល់ដល់អ្នកជំនួញ ឬម្ចាស់កម្មសិទ្ធិបញ្ញា ដូចជា ម៉ាក គំនូរឧស្សាហកម្ម និងប្រកាសនីយបត្រតក្កកម្មជាអាទិ៍។

គួរឱ្យកត់សម្គាល់ផងដែរថា អាស៊ានក៏មានគោលដៅបង្កើតឱ្យបាននូវការិយាល័យប្រកាស-នីយបត្រតក្កកម្ម និងការិយាល័យម៉ាកក្នុងតំបន់ផងដែរ ដោយយោងតាមកិច្ចព្រមព្រៀង ស្ដីពីកិច្ច-សហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ប៉ុន្តែកិច្ចព្រមព្រៀងនេះមិនទាន់ត្រូវបានអនុវត្តន៍នៅឡើយ ពីព្រោះប្រទេសជាសមាជិកអាស៊ានពុំបានផ្ដល់សច្ចាប័នគ្រប់ប្រទេសនៅឡើយនោះទេ។[104]

### **២.២.៣. លក្ខខណ្ឌតម្រូវនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា**

#### **២.២.៣.១. លក្ខខណ្ឌដែលអាចចុះបញ្ជីកម្មសិទ្ធិបញ្ញា**

ការចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងសហភាពអឺរ៉ុប ធ្វើឡើងទៅតាមបទដ្ឋានគតិយុត្តក្នុងតំបន់ ឬបទដ្ឋានអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក រីឯអាស៊ាននៅតែធ្វើការចុះបញ្ជីកម្មសិទ្ធិបញ្ញាតាមបទដ្ឋានថ្នាក់ជាតិ ប៉ុន្តែវាអាចនឹងល្អជាងនេះសម្រាប់ម្ចាស់កម្មសិទ្ធិបញ្ញា ដែលមានសមត្ថ-ភាព និងលទ្ធភាពក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញាតាមប្រព័ន្ធចុះបញ្ជីអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ប្រសិនបើកម្មសិទ្ធិបញ្ញារបស់ខ្លួនតម្រូវឱ្យមានការការពារច្រើនប្រទេស ប៉ុន្តែ

[104] កិច្ចព្រមព្រៀងស្ដីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន, ១៥ ធ្នូ ១៩៩៥, មាត្រា ១(៥) និង(៦)។

ប្រសិនបើម្ចាស់ស្លាកដែសម្លឹងរកមើលថាទីផ្សារនៃស្លាដែរបស់ខ្លួននោះ មិនមានសក្តានុពលនៃការធ្វើពាណិជ្ជកម្មនៅច្រើនប្រទេសនោះទេ គេអាចធ្វើការចុះបញ្ជីដើម្បីទទួលបាននូវការការពារតែនៅថ្នាក់ជាតិបានហើយ។

ក្នុងសហភាពអឺរ៉ុប កត្តាដែលអាចចុះបញ្ជីកម្មសិទ្ធិបញ្ញាបាន តម្រូវឱ្យប្រភេទនៃកម្មសិទ្ធិបញ្ញានោះ មានលក្ខខណ្ឌត្រឹមត្រូវទៅតាមបទដ្ឋានតំបន់ ឬអន្តរជាតិ ហើយរាល់ពាក្យស្នើសុំទាំងអស់ត្រូវអនុលោមតាមបទដ្ឋានថ្នាក់តំបន់ ឬអន្តរជាតិ។

ឧទាហរណ៍៖ ដើម្បីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន ត្រូវមានលក្ខខណ្ឌបីជាចាំបាច់ រួមមាន ថ្មី មានជំហានរកឃើញថ្មី និងអាចអនុវត្តបានក្នុងឧស្សាហកម្ម ហើយពាក្យស្នើសុំដែលដាក់មកនោះ អាចអនុលោមតាម អនុសញ្ញាស្តីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ លើសពីនេះទៅទៀត មុននឹងឈានដល់ការដាក់ពាក្យស្នើសុំចុះបញ្ជី គេអាចស្វែងរកបញ្ជីកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីរួចរាល់ កម្រៃដែលត្រូវបង់ មធ្យោបាយនៃការដាក់ពាក្យស្នើសុំ ជាអាទិ៍។

សម្រាប់ការចុះបញ្ជីក្នុងតំបន់អាស៊ានវិញ អាស្រ័យទៅតាមនីតិវិធីនៃការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃប្រទេសជាសមាជិកនីមួយៗ ដែលម្ចាស់កម្មសិទ្ធិបញ្ញាចង់ឱ្យមានការការពារកម្មសិទ្ធិបញ្ញារបស់ខ្លួន។

#### ២.២.៣.២. ម្ចាស់សិទ្ធិ ឬអ្នកតំណាង

ម្ចាស់សិទ្ធិនៃកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីរួច មានសិទ្ធិដូចគ្នាទៅនឹងម្ចាស់ស្លាដែដើមដែរ មិនថាម្ចាស់កម្មសិទ្ធិបញ្ញានៅក្នុងសហភាពអឺរ៉ុប ឬសហគមន៍អាស៊ាននោះទេ ជាពិសេសសិទ្ធិបេតិកភណ្ឌ។

### ២.២.៤. សក្តានុពលនៃស្ថាប័នទទួលបន្ទុកចុះបញ្ជី

#### ២.២.៤.១. ការទទួលពាក្យស្នើសុំ

ការិយាល័យទទួលបន្ទុកចុះបញ្ជីកម្មសិទ្ធិបញ្ញា ទទួលពាក្យស្នើសុំទាំងទម្រង់ជាក្រដាស និងអនឡាញទៅតាមជម្រើសអ្នកស្នើសុំ។

ក្នុងសហភាពអឺរ៉ុប ការទទួលពាក្យស្នើសុំចុះបញ្ជីអនឡាញមានភាពទូលំទូលាយ ហើយថែមទាំងមានភាពរហ័ស បើទោះបីជាមានបញ្ហាណាមួយកើតឡើងក្នុងអំឡុងពេលពិនិត្យពាក្យស្នើសុំក៏ដោយ។ ម៉្យាងវិញទៀត ការបង់ប្រាក់សម្រាប់ប្រភេទពាក្យស្នើសុំនីមួយៗ ធ្វើឡើងដំណាលគ្នានៃការដាក់ពាក្យស្នើសុំតាមរយៈការបង់ប្រាក់អេឡិចត្រូនិច ហើយការិយាល័យអាចធ្វើការពិនិត្យពាក្យស្នើដោយមិនរង់ចាំយូរ។

ក្នុងឆ្នាំ២០១៧ ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប ទទួលបានពាក្យស្នើសុំចុះបញ្ជីម៉ាកចំនួន ១៤៦,៤១៨ និងពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មចំនួន ៩៥,៨៣០។[105] ចំណែកការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុបវិញ ក្នុងឆ្នាំ២០១៧ បានទទួលពាក្យស្នើសុំបានប្រហែល ១៦៦,០០០ រៀងរាល់ឆ្នាំ ដែលក្នុងមួយថ្ងៃទទួលពាក្យស្នើសុំច្រើនជាង ៤៥០ពាក្យ។[106]

បើធ្វើការប្រៀបធៀបមកអាស៊ានវិញ ទិន្នន័យដែលបានបង្ហាញមានត្រឹមឆ្នាំ២០១៦ប៉ុណ្ណោះ ដែលទិន្នន័យទាំងអស់នេះជាការបូកសរុបរាល់ពាក្យស្នើសុំរបស់សមាជិកអាស៊ានទាំងអស់។ ក្នុងឆ្នាំដដែរ ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាក អាស៊ានទទួលបានចំនួន ២៥៨, ០៩០ ដែលក្នុងនោះពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម មានចំនួន ៨៣,២២១ ពាក្យស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម មានចំនួន ១៦,៧៦៩។[107]

#### ២.២.៤.២. សមិទ្ធិផលរបស់ស្ថាប័ន

សមិទ្ធិផលមួយចំនួនរបស់ការិយាល័យម៉ាកសហភាពអឺរ៉ុប បានប្រើប្រាស់ថវិកាសហប្រតិបត្តិការចំនួន៥០លានអឺរ៉ូ សម្រាប់ដំណើរការរយៈពេល៥ឆ្នាំ ក្នុងការផ្តល់មធ្យោបាយទូទៅដល់គ្រប់ការិយាល័យកម្មសិទ្ធិបញ្ញាក្នុងសហភាពអឺរ៉ុប ក្នុងឆ្នាំ២០១០។ ក្នុងឆ្នាំ២០១១ផងដែរ ស្ថាប័ននេះបានចុះកិច្ចព្រមព្រៀងជាមួយនឹងអាជ្ញាធរអេស្ប៉ាញ ដើម្បីផ្តល់នូវកន្លែងផ្សព្វផ្សាយចំណេះដឹង និង ព័ត៌មាន។ ទន្ទឹមគ្នានេះផងដែរ ក៏បានបង្កើតអង្គភាពឃ្លាំមើលការរំលោភបំពានកម្មសិទ្ធិបញ្ញា និង ភ្នាក់ងារសម្រាប់ការអនុវត្ត គម្រោងសហភាពអឺរ៉ុប-អាស៊ាន ស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញា(ECAP III Phase II) ចិន(IP Key) រុស្ស៊ី(P4M) និងឥណ្ឌា(IPC-EUI)។[108]

ក្រោយការជួបនូវឧបសគ្គជាច្រើន ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ក្នុងឆ្នាំ២០១០ ដល់ឆ្នាំ២០១៨ បាននឹងកំពុងកែប្រែស្ថានភាពឱ្យបានប្រសើរ។ ការិយាល័យនេះបានធ្វើកំណែទម្រង់កម្មវិធី និងគម្រោងជាច្រើន ដើម្បីអភិវឌ្ឍន៍ផ្នែកសេវាកម្ម និងធ្វើយ៉ាងណាឱ្យប្រាកដថា ការិយាល័យប្រកាសនីយបត្រតក្កកម្មមួយនេះ គឺជាស្ថាប័នដែលមានសក្តានុពល ការប្រកួតប្រជែង និងស្ថេរភាពហិរញ្ញវត្ថុ។

---

[105] EUIPO, The Office [ការិយាល័យ], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal/en/the-office ។

[106] EPO, European Patent Office [ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.epo.org/news-issues/press/background/epo.html។

[107] ASEAN Intellectual Property Portal,ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.aseanip.org/Statistics/IP-Filing-Statistics-in-ASEAN។

[108] EUIPO Strategic Plan 2020 [ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២០], (២៥ មករា ២០១៦), https://euipo.europa.eu/tunnel-web/secure/webdav/guest/document_library/contentPdfs/Strategic_plan_2020/strategicplan 2020_en.pdf (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

ចំណុចធំៗចំនួនបួន ដែលការិយាល័យបានធ្វើការកែទម្រង់នោះគឺ ចំណុចទី១ ការផ្តល់នូវសេវាកម្មដែលមានគុណភាពខ្ពស់ ក្នុងនោះមានការផ្តល់នូវមធ្យោបាយថ្មី និងការប្រើប្រាស់សេវាកម្មដោយឥតគិតថ្លៃពាក់ព័ន្ធនឹងការស្វែងរកព័ត៌មានអំពីប្រកាសនីយបត្រតក្កកម្ម តម្លៃសមរម្យនិងសេវាល្អ ព្រមទាំងការទទួលយកមតិរិះគន់ពីអ្នកប្រើប្រាស់។ ចំណុចទី២ ការក្លាយជាស្ថាប័នសាធារណៈដែលកាន់តែមានប្រសិទ្ធភាព និងការប្រកួតប្រជែង តួយ៉ាងការធ្វើឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ដំណើរការផ្តល់ជូនប្រកាសនីយបត្រតក្កកម្ម ការសាងសង់អគារថ្មីនៅប្រទេសហូឡង់។ ចំណុចទី៣ ពង្រឹងបណ្តាញប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលបានបង្កើតឡើងក្នុងឆ្នាំ២០១១ និងកិច្ចសហការបន្ថែមលើឆាកអន្តរជាតិ។ ចំណុចទី៤ ធ្វើឱ្យរីកចម្រើនលើការការពារកម្មសិទ្ធិបញ្ញាប្រកបដោយតម្លាភាព និងទំនួលខុសត្រូវក្នុងសង្គម។[109]

ដោយឡែកក្នុងតំបន់អាស៊ានវិញ អាស៊ានបានបង្កើតនូវសេចក្តីណែនាំដល់អ្នកច្នៃប្រឌិតថ្មីក្នុងការប្រើប្រាស់កម្មវិធីសហប្រតិបត្តិការត្រួតពិនិត្យបច្ចេកទេសលម្អិតប្រកាសនីយបត្រតក្កកម្ម អាស៊ាន (ASEAN Patent Examination Co-operation (ASPEC)) ក្នុងឆ្នាំ២០០៩ ដែលជាកម្មវិធីចែករំលែកការងារប្រកាសនីយបត្រតក្កកម្មថ្នាក់តំបន់លើកដំបូងសម្រាប់រដ្ឋជាសមាជិកទាំងអស់ លើកលែងប្រទេសភូមា ដែលមិនមែនជាសមាជិក។[110] តាមរយៈកម្មវិធីនេះទៀតសោត អាស៊ានបានផ្តួចផ្តើមបង្កើតនូវ គម្រោងមួយដែលមានឈ្មោះថា អាស៊ាន Patentscope ក្នុងឆ្នាំ២០១២ ដែលមានការគាំទ្រដោយក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ដើម្បីពង្រីកកិច្ចសហការសកម្មភាពថ្នាក់តំបន់លើការស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រមទាំងជំរុញឱ្យមានការអភិវឌ្ឍបច្ចេកវិទ្យារវាងរដ្ឋជាសមាជិកអាស៊ាន។[111] លើសពីនេះទៅទៀត អាស៊ានបានបង្កើតនូវ ASEAN IP Portal ដែលជាគេហទំព័រប្រមូលផ្តុំនូវព័ត៌មានអំពីប្រព័ន្ធកម្មសិទ្ធិបញ្ញាអាស៊ាន ទិន្នន័យពាក់ព័ន្ធ គេហទំព័រដែលភ្ជាប់ទៅនឹងការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិជាដើម។[112]

---

[109] EPO, Modernising the EPO for excellence and sustainability [ទំនើបកម្មរបស់ EPO សម្រាប់ឧត្តមភាព និងនិរន្តភាព], http://documents.epo.org/projects/babylon/eponet.nsf/0/dc766d4ee08d84a0c1258291002b5d6e/$FILE/Modernising_the_EPO_for_excellence_and_sustainability_en.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

[110] ASEAN IP Portal , Guideline launched to help innovators in using ASPEC [សេចក្តីណែនាំដែលត្រូវបានដាក់ឱ្យប្រើដើម្បីជួយអ្នកច្នៃប្រឌិតថ្មីក្នុងការប្រើប្រាស់កម្មវិធី ASPEC], ២២ ឧសភា ២០១៨, https://www.aseanip.org/News-Events/Latest-News-Events/ctl/Details/mid/1956/aid/58 ។

[111] ASEAN IP Portal, Public Rollout of ASEAN PATENTSCOPE Service [ភាពរីកសាយជាសាធារណៈនៃសេវាកម្មអាស៊ាន Patentscope], ២៧ សីហា ២០១៧, https://www.aseanip.org/News-Events/Latest-News-Events/ctl/Details/mid/1956/aid/52។

[112] ASEAN IP Portal, About [អំពី], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.aseanip.org/About ។

### ២.២.៥. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីកម្មសិទ្ធិបញ្ញា

#### ២.២.៥.១. សន្ធិសញ្ញាក្នុងតំបន់ស្ដីពីការចុះបញ្ជីកម្មសិទ្ធិបញ្ញា

ត្រង់ចំណុចនេះ សហភាពអឺរ៉ុបមានលទ្ធភាពក្នុងការបង្កើតបទដ្ឋានគតិយុត្តក្នុងតំបន់ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ហើយអាចធ្វើការអនុវត្តទៅបានប្រកបដោយប្រសិទ្ធិភាព។ ក្នុងការចុះបញ្ជីម៉ាក សហភាពអឺរ៉ុបអនុលោមតាមបទប្បញ្ញត្តិស្ដីពីម៉ាកសហភាពអឺរ៉ុប ដែលត្រូវបានអនុវត្តន៍ទូទាំងសហភាពអឺរ៉ុប សេចក្ដីបង្គាប់ និងបទបញ្ជាផ្សេងទៀត។[113] សម្រាប់គំនូរឧស្សាហកម្មវិញ សហភាពអឺរ៉ុប មានទាំងបទប្បញ្ញត្តិ បទបញ្ជា និងសេចក្ដីបង្គាប់ ដើម្បីជាកិច្ចការពារប្រភេទកម្មសិទ្ធិបញ្ញាមួយនេះ។[114] ប្រកាសនីយបត្រតក្កកម្មវិញ មានអនុសញ្ញាស្ដីពីប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានអនុវត្តន៍ទូទាំងសហភាពអឺរ៉ុប។ ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញវិញ សហភាពអឺរ៉ុប ពុំមានបទប្បញ្ញត្តិរួមក្នុងតំបន់ស្ដីពីការចុះបញ្ជីនៅឡើយ ប៉ុន្តែសហភាពអឺរ៉ុបបាននឹងកំពុងរៀបចំឱ្យមាននូវកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមិនមែនជាផលិតផលកសិកម្ម។ ដូច្នេះ ក្នុងការចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវចុះនៅតាមប្រទេសដែលចង់ឱ្យមានការការពារ។[115]

ចំពោះសហគមន៍អាស៊ានក្នុងពេលបច្ចុប្បន្ន នៅពឹងផ្អែកលើបទដ្ឋានអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅឡើយ មានន័យថាអាស៊ាននៅពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតនូវបទដ្ឋានគតិយុត្តរួមក្នុងតំបន់ដែលទាក់ទងនឹងការចុះបញ្ជីកម្មសិទ្ធិបញ្ញានោះទេ ពីព្រោះចំណុចសំខាន់ ដែលសហគមន៍អាស៊ានគួរតែធ្វើ មុននឹងបង្កើតសន្ធិសញ្ញា ឬអនុសញ្ញាថ្នាក់តំបន់ ឬស្ថាប័នទទួលបន្ទុកថ្នាក់តំបន់នោះ គឺត្រូវធ្វើឱ្យកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ានចូលជាធរមានសិន ហើយកិច្ចព្រមព្រៀងនេះចូលជាធរមានបាន លុះណាតែរាល់រដ្ឋជាសមាជិកអាស៊ានផ្ដល់បានសច្ចាប័ន។

ទោះជាយ៉ាងណា អាស៊ាននៅតែបន្តសកម្មភាពរបស់ខ្លួន តាមរយៈការអនុវត្តផែនការសកម្មភាព ដែលក្នុងពេលបច្ចុប្បន្នឈានដល់ផែនការសកម្មភាពលើកទី៣ ឆ្នាំ២០១៦-២០២៥ ដើម្បីឱ្យប្រព័ន្ធកម្មសិទ្ធិបញ្ញាមានការរីកចម្រើន តាមរយៈការពង្រឹងសមត្ថភាពធនធានមនុស្សនៅការិយាល័យកម្មសិទ្ធិបញ្ញា និងកសាងហេដ្ឋារចនាសម្ព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់។

---

113 European Commission, Trade mark protection in the EU [ការការពារម៉ាកពាណិជ្ជកម្មក្នុងសហភាពអឺរ៉ុប], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://ec.europa.eu/growth/industry/intellectual-property/trade-mark-protection_en ។

114 European Commission, Industrial Design Protection [កិច្ចការពារគំនូរឧស្សាហកម្ម], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://ec.europa.eu/growth/industry/intellectual-property/industrial-design/protection_en ។

115 European Commission, Geographical indications for non-agricultural products [ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ផលិតផលមិនមែនកសិកម្ម], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://ec.europa.eu/growth/industry/intellectual-property/geographical-indications/non-agricultural-products_en ។

### ២.២.៥.២. កិច្ចសហប្រតិបត្តិការផ្សេងៗ

ដើម្បីអភិវឌ្ឍន៍ និងអនុវត្តន៍លើគោលដៅយុទ្ធសាស្ត្រ នៃផែនការយុទ្ធសាស្ត្ររបស់អាស៊ាន ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ានបានបន្តពង្រឹងទំនាក់ទំនង និងសហប្រតិបត្តិការ ជាមួយនឹងស្ថាប័នកម្មសិទ្ធិបញ្ញា និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាវិស័យឯកជន តាមរយៈអនុស្សរណៈ យោគយល់មួយចំនួន។ ឧទាហរណ៍ដូចជា ស្ថាប័នកម្មសិទ្ធិបញ្ញាអូស្ត្រាលី ការិយាល័យ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប ការិយាល័យ ប្រកាសនីយបត្រតក្កកម្មជប៉ុន ការិយាល័យកម្មសិទ្ធិបញ្ញាសាធារណរដ្ឋកូរ៉េ[116] ការិយាល័យកម្មសិទ្ធិ បញ្ញាញូហ្សឺឡែន ការិយាល័យម៉ាក និងប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក អង្គការកម្មសិទ្ធិ បញ្ញាពិភពលោក សមាគម កម្មសិទ្ធិបញ្ញាអាស៊ាន ជាអាទិ៍។[117]

នៅក្នុងសហភាពអឺរ៉ុប មានកិច្ចសហប្រតិបត្តិការអន្តរជាតិ មានមិនតិចជាងនៅក្នុងតំបន់ អាស៊ានទេ ក៏ប៉ុន្តែសហភាពអឺរ៉ុបធ្វើការងារបន្ថែមជាមួយអង្គការ ស្ថាប័ន និងថ្នាក់អន្តរជាតិ ព្រម ទាំងកិច្ចសហប្រតិបត្តិការទាំងការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិ និងតំបន់នៅក្នុងសហភាពអឺរ៉ុប ក៏ដូចជាការបង្កើតភ្នាក់ងារផ្សេងៗ ដើម្បីជាជំនួយកិច្ចការផ្នែកច្បាប់ បច្ចេកទេស និង វិទ្យាសា ស្ត្រ។[118]

ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប មានដៃគូសហការជាមួយនឹង ក្រុមTM5 និងក្រុម ID5 របស់ការិយាល័យកម្មសិទ្ធិបញ្ញា ប្រទេសជប៉ុន ចិន កូរ៉េ និងសហរដ្ឋអាមេរិក។[119]

សហភាពអឺរ៉ុប បានចុះកិច្ចព្រមព្រៀងពហុភាគីជាមួយតំបន់អាហ្វ្រិកដែលមានប្រទេសចំនួន ១៧ និងប្រទេសដែលនៅតំបន់ការ៉ាបៀន និងប៉ាស៊ីហ្វិក លើផ្នែកពាណិជ្ជកម្មជាច្រើន ដែលក្នុងនោះ ក៏មានកម្មសិទ្ធិបញ្ញាមួយផងដែរ។[120]

---

[116] ASEAN, ASEAN and KIPO Sign Memorandum on Intellectual Property [អាស៊ាន និងKIPO ចុះអនុស្សរណៈយោគ យល់ស្តីពីកម្មសិទ្ធិបញ្ញា], (២៧ មីនា ២០១៨), ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.aseanip.org/News-Events/Latest-News-Events/ctl/Details/mid/1956/aid/54។

[117] ASEAN, Intellectual Property [កម្មសិទ្ធិបញ្ញា], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://asean.org/asean-economic-community/sectoral-bodies-under-the-purview-of-aem/intellectual-property/ ។

[118] EUIPO, Cooperation [សហប្រតិបត្តិការ], ចូលមើល ៣០ មិថុនា ២០១៨ https://euipo.europa.eu/ohimportal/en/what-we-do/cooperation ។

[119] EUIPO, Our Partners [ដៃគូរបស់យើង], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://euipo.europa.eu/ohimportal /en/our-partners ។

[120] Center for International environmental law, Publication [ការបោះផ្សាយ], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.ciel.org/reports/the-european-approach-to-intellectual-property-in-european-partnership-agreements-with-the-african-caribbean-and-pacific-group-of-countries-shabalala-april-2007-2/។

# ជំពូកទី៣

# ជំហាននៃការបង្កើត
# ប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិ
# បញ្ញាក្នុងតំបន់អាស៊ាន

# ជំពូកទី៣៖ ជំហាននៃបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន

## ៣.១. ប្រវត្តិ

ដោយសារ វិស័យកម្មសិទ្ធិបញ្ញាដើរតួយ៉ាងសំខាន់ ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community (AEC)) នោះនាំឱ្យបណ្តាសមាជិកអាស៊ានមានការចាប់អារម្មណ៍ខ្លាំងលើការការពារសិទ្ធិកម្មសិទ្ធិបញ្ញា ដើម្បីឈានដល់ភាពរីកចម្រើនខាងបច្ចេកវិទ្យា ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការបង្កើតឱ្យមាន ភាពច្នៃប្រឌិត និងការបង្កើតថ្មី។[121] ដូច្នេះអាស៊ានបានកំណត់យកវិស័យកម្មសិទ្ធិបញ្ញា ជាចំណុចមូលដ្ឋានមួយនៃផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint)[122] ឆ្នាំ២០២៥ ។

នៅក្នុងសហគមន៍អាស៊ាន ការការពារកម្មសិទ្ធិបញ្ញា ជាផ្នែកមួយនៃការប្រកួតប្រជែងការបង្កើតថ្មី និងប្រែប្រួលឥតឈប់ឈរ ដូច្នេះដើម្បីសម្រេចគោលដៅនេះបាន ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ជំរុញរាល់សមាជិកទាំងអស់បង្កើតឱ្យមានគោលនយោបាយ ទាំងឡាយណាដែលគាំទ្រដល់ការបង្កើតថ្មី ដូចទៅនឹងការអភិវឌ្ឍកំណើនផលិតកម្មក្នុងតំបន់ផងដែរ។[123]

សហប្រតិបត្តិការអាស៊ានទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា បានចាប់ផ្តើមឡើងដោយសារការកំណត់គោលដៅចំពោះការសហការយ៉ាងជិតស្និទ្ធិរវាងសមាជិកអាស៊ានពាក់ព័ន្ធវិស័យកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងការបញ្ច្រាបការយល់ដឹងយ៉ាងឆាប់រហ័សអំពីតំបន់ពាណិជ្ជកម្មសេរីអាស៊ានទៅកាន់រដ្ឋសមាជិកអាស៊ាន។ ក្នុងស្ថានភាពបែបនេះហើយ ដែលជាហេតុធ្វើឱ្យសមាជិកអាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន (ASEAN Framework Agreement on Intellectual Property Cooperation) ក្នុងខែធ្នូ ឆ្នាំ១៩៩៥។[124] ប៉ុន្តែទោះជាយ៉ាងណា សហគមន៍អាស៊ានពុំទាន់មានការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាថ្នាក់តំបន់នៅឡើយទេ បើទោះបីជាមានកិច្ចព្រមព្រៀងនេះយ៉ាងណាក៏ដោយ។

## ៣.២. បទដ្ឋានពាក់ព័ន្ធនឹងការឈានដល់ការបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់

### ៣.២.១. កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន

កិច្ចព្រមព្រៀងដែលទាក់ទងនឹង កម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ានដែលបញ្ញត្តិអំពីវិស័យកម្មសិទ្ធិបញ្ញាច្រើនជាងគេនោះ គឺកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ដែល

---

[121] ASEAN, Intellectual Property [កម្មសិទ្ធិបញ្ញា], ចូលមើលចុងក្រោយ ១៦ មិថុនា ២០១៨, http://asean.org/asean-economic-community/sectoral-bodies-under-the-purview-of-aem/intellectual-property/។

[122] ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ដើរតួជាផែនការមេក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន និងជាវិធានការសមាហរណកម្មសេដ្ឋកិច្ចដែលប្រទេសជាសមាជិកធ្វើការអនុវត្ត។

[123] ដដែល។

[124] ដដែល។

ត្រូវបានចុះហត្ថលេខាដំបូងដោយប្រទេសចំនួនប្រាំពីររួមមាន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ ព្រុយនេ សិង្ហបុរី និងវៀតណាម នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងបាងកក នៃប្រទេសថៃ ប៉ុន្តែក្នុងពេលបច្ចុប្បន្ន រាល់សមាជិកអាស៊ានទាំងអស់សុទ្ធតែជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។

កិច្ចព្រមព្រៀងនេះផងដែរ មាន៨មាត្រា ដែលបានចែងអំពី គោលបំណង គោលការណ៍ទំហំនៃកិច្ចសហប្រតិបត្តិការ កិច្ចរំលឹកសកម្មភាពសហប្រតិបត្តិការ ការពិគ្រោះយោបល់ បទប្បញ្ញត្តិទូទៅ ថវិកា និងអវសានបញ្ញត្តិ។[125] កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះបានផ្តោតលើ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ការអនុវត្តច្បាប់ ដែលទាក់ទងនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម ម៉ាក ព័ត៌មានសម្ងាត់ និងកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបង្រួម។[126] លើសពីនេះទៀត កិច្ចព្រមព្រៀងនេះ ជំរុញឱ្យមានការអនុវត្ត និងការការពារកម្មសិទ្ធិបញ្ញា ពង្រឹងរដ្ឋបាលកម្មសិទ្ធិបញ្ញា (រៀបចំទិន្នន័យ) ពង្រឹងបទដ្ឋានគតិយុត្ត ដូចជាការអនុវត្តកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ការអភិវឌ្ឍ និងការកសាងធនធានមនុស្ស ការបង្កើតនូវសមាគមកម្មសិទ្ធិបញ្ញាអាស៊ាន និងការបង្កើតមជ្ឈត្តកម្ម និងអង្គភាពដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។[127]

កិច្ចព្រមព្រៀងនេះ មានគោលបំណងឱ្យសមាជិកធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការរបស់ពួកគេក្នុងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ និងអភិវឌ្ឍន៍វិស័យកម្មសិទ្ធបញ្ញាក្នុងតំបន់ ព្រមទាំងសេរីភាវូបនីយកម្មពាណិជ្ជកម្មពិភពលោក។ បន្ថែមពីនេះ គឺតម្រូវឱ្យប្រទេសជាសមាជិកធ្វើការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីឱ្យវិស័យកម្មសិទ្ធិបញ្ញាមានទំនាក់ទំនងគ្នារវាងភ្នាក់ងាររដ្ឋ វិស័យឯកជន និងស្ថាប័នជំនាញអាស៊ាន ហើយស្វែងយល់ពីការរៀបចំកិច្ចសហប្រតិបត្តិការអន្តរប្រទេសឱ្យបានសមស្រប សម្រាប់ភាពរីកចម្រើននៃការច្នៃប្រឌិត ការផ្ទេរ និងការផ្សព្វផ្សាយបច្ចេកវិទ្យា។[128]

គោលបំណងសំខាន់ផ្សេងទៀតនោះគឺ ការបង្កើតឱ្យមាននូវប្រព័ន្ធចុះបញ្ជីប្រកាសនីយបត្រតក្កកម្មអាស៊ាន និងការបង្កើតប្រព័ន្ធចុះបញ្ជីម៉ាកអាស៊ាន តាមរយៈការបង្កើតឱ្យបាននូវការិយាល័យ ប្រកាសនីយបត្រតក្កកម្មអាស៊ាន និងការិយាល័យម៉ាកអាស៊ាន។ ប៉ុន្តែទោះជាយ៉ាងណា រដ្ឋជាសមាជិកនៅតែត្រូវធ្វើការស្វែងយល់ពីលទ្ធភាពនៃការបង្កើត ថាតើសហគមន៍អាស៊ាន

---

[125] ASEAN Framework Agreement on Intellectual Property Cooperation [កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន], ១៥ ធ្នូ ១៩៩៥ ។

[126] ECAP III, ASEAN Regional Treaties [សន្ធិសញ្ញាតំបន់អាស៊ាន], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.ecap3.org/resources/asean-regional-treaties ។

[127] Audier & Partners Law Firm, Intellectual Property Rights: the convergence of laws in ASEAN [សិទ្ធិកម្មសិទ្ធិបញ្ញា៖ ការរួមបញ្ចូលច្បាប់ក្នុងអាស៊ាន], http://www.henricapitant-cambodia.org/wp-content/uploads/2017/12/3.1.5.-Colin-Picard-de-Gennes-Intellectual-Property-Rights-The-Convergence-of-Laws-in-ASEAN.pdf (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

[128] ដូច ១២២, មាត្រា ១។

អាចបង្កើតឡើងបានត្រឹមកម្រិតណា ដើម្បីជាចំណែកជួយដល់ការការពារប្រកាសនីយបត្រតក្កកម្ម និងម៉ាកក្នុងតំបន់។ រដ្ឋជាសមាជិក ក៏ត្រូវពិគ្រោះយោបល់លើការអភិវឌ្ឍវិស័យកម្មសិទ្ធិបញ្ញាដើម្បីបង្កើតបាននូវស្តង់ដារ និងការអនុវត្តក្នុងតំបន់អាស៊ានឱ្យស្របតាមបទដ្ឋានអន្តរជាតិ។[129]

### ៣.២.២. សេចក្តីថ្លែងការណ៍

តាមរយៈសេចក្តីថ្លែងការណ៍របស់អាស៊ានក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៃទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន អាស៊ាននៅតែទទួលស្គាល់ពីសារសំខាន់ចំពោះការការពារកម្មសិទ្ធិបញ្ញា ហើយបានចូលរួមសាទរចំពោះរដ្ឋជាសមាជិកដែលបានចូលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីតទាក់ទងនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ។ ក្រៅពីនេះអាស៊ានបើកចំហរាល់មធ្យោបាយដែលជួយដល់ការរីកចម្រើននៃការផ្លាស់ប្តូរសេវាកម្ម ដូចជា កម្មវិធី ASEAN Patentscope ដែលអនុញ្ញាតឱ្យមានការស្វែងរកឯកសារពាក់ព័ន្ធនឹងប្រកាសនីយបត្រតក្កកម្មអាស៊ាន ដោយមិនគិតថ្លៃ និងគាំទ្រដល់ការបង្កើតថ្មីព្រមទាំងការអភិវឌ្ឍបច្ចេកវិទ្យា។[130]

### ៣.២.៣. កិច្ចប្រជុំអំពីកម្មសិទ្ធិបញ្ញា

ការប្រជុំរបស់ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន(ASEAN Working Group on Intellectual Property Cooperation (AWGIPC)) លើកទី៥៥ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ នៅប្រទេសព្រុយនេ។ ការប្រជុំត្រូវបានរៀបចំឡើយដោយអគ្គនាយកដ្ឋានថាមពល និងឧស្សាហកម្ម ដែលមានការចូលរួមពីរដ្ឋជាសមាជិកអាស៊ាន និងអ្នកតំណាងនៃការិយាល័យកម្មសិទ្ធិបញ្ញា។[131]

កិច្ចប្រជុំរបស់ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ានមានគោលបំណងពិភាក្សា និងឆ្លើយបតនឹងបញ្ហាទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងធ្វើការផ្លាស់ប្តូរទស្សនៈ ព្រមទាំងធ្វើបច្ចុប្បន្នភាពលើវិស័យកម្មសិទ្ធិបញ្ញាសម្រាប់ឆ្នាំ២០១៨។ ការប្រជុំនេះផងដែរ មានការពិភាក្សាអំពីការធ្វើអន្តរាគមន៍លើផែនការសកម្មភាព ដែលពាក់ព័ន្ធនឹងសិទ្ធិលើកម្មសិទ្ធិបញ្ញា។[132]

[129] ដដែល។

[130] 2017 Chairman's Statement of the 31st ASEAN Summit [សេចក្តីថ្លែងការណ៍លើកទី៣១នៃកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០១៧], (១៣ វិច្ឆិកា ២០១៧), ១៣។

[131] Ministry of Energy and Industry, 55th Meeting of the ASEAN Working Group on Intellectual Property Cooperation (AWGIPC) and Related Meetings in Brunei Darussalam [កិច្ចប្រជុំលើកទី៥៥នៃក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនានាក្នុងប្រទេសព្រុយនេ], (២៦ មីនា ២០១៨), ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.ei.gov.bn/Lists/EDPMO%20Updates/NewDispForm.aspx?ID=179 ។

[132] ដដែល។

### ៣.២.៤. ការចូលជាសមាជិកនៃបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញារបស់សមាជិកអាស៊ាន

ការទទួលយកបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ជាផ្នែកមួយដ៏សំខាន់ដែលអាចនាំឱ្យវិស័យកម្មសិទ្ធិបញ្ញាមានភាពកាន់រីកចម្រើន ហើយអាចទាញយកផលប្រយោជន៍ពីបទដ្ឋានអន្តរជាតិទាំងនោះបាន។ រដ្ឋជាសមាជិកអាស៊ានទាំងអស់សុទ្ធតែជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងទទួលយកបណ្តាបទដ្ឋានអន្តរជាតិផ្សេងទៀត ដែលជាកត្តាអាចឱ្យអាស៊ានបង្កើតបាននូវការការពារកម្មសិទ្ធិបញ្ញា ដែលមានលក្ខណៈតែមួយក្នុងតំបន់អាស៊ាន។

- **ប្រទេសកម្ពុជា**

ប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក តាមរយៈការទទួលយកអនុសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ និងបានទទួលយកបទដ្ឋានអន្តរជាតិមួយចំនួនទៀតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក រួមមានអនុសញ្ញាទីក្រុងប៉ារីស បានទទួលយកនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៨ ពិធីសារទីក្រុងម៉ាឌ្រីត ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ និងច្បាប់ហ្សឺណែវ ស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយក៏ជាប្រទេសហត្ថលេខីលើសន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ និងអនុសញ្ញាទីក្រុងរ៉ូម ស្តីពីកិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រម និងអង្គភាពទូរផ្សាយ (អនុសញ្ញាទីក្រុងរ៉ូម) នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៦១។[133]

- **ប្រទេសព្រុយនេ**

ប្រទេសព្រុយនេ បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៤។ ក្រោយមកទៀត ប្រទេសព្រុយនេ បានទទួលយកអនុសញ្ញាទីក្រុងប៊ែន ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែស ស្តីពីការទទួលស្គាល់ជាអន្តរជាតិការតម្កល់មីក្រូសរីរាង្គ សម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម (សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែស) ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ សន្ធិសញ្ញាទីក្រុងប៉ារីស ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១២ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ កិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម (កិច្ចព្រមព្រៀងទីក្រុងឡាអេ) ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ សន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO Copyright Treaty) ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ និង សន្ធិសញ្ញា ស្តីពីសិទ្ធិអ្នកសម្តែង និងផលិករហ្វូណូក្រាម

[133] WIPO, WIPO-Administered Treaties [សន្ធិសញ្ញាគ្រប់គ្រងដោយអង្គការ WIPO], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.wipo.int/treaties/en/ShowResults.jsp?country_id=90C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO Performance and Phonograms Treaty) នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧។[134]

- **ប្រទេសឥណ្ឌូនេស៊ី**

ប្រទេសឥណ្ឌូនេស៊ី បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩។ បន្ទាប់មកទៀត បានទទួលយកអនុសញ្ញាទីក្រុងប៉ារីស នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៥០ អនុសញ្ញាទីក្រុងប៊ែន ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៩៧ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ស្របពេលជាមួយនឹងសន្ធិសញ្ញាច្បាប់ស្តីពីម៉ាក (Trademark Law Treaty) នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៩៧។ បន្ទាប់មកទៀត ប្រទេសឥណ្ឌូនេស៊ី បានទទួលយកសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០២ សន្ធិសញ្ញាស្តីពីសិទ្ធិអ្នកសម្តែង និងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ និងពិធីសារទីក្រុងម៉ាឌ្រីត ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨។ បន្ថែមពីនេះ ប្រទេសឥណ្ឌូនេស៊ីបានចុះហត្ថលេខា លើសន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ សន្ធិសញ្ញាណៃរ៉ូប៊ី ស្តីពីកិច្ចការពារនិមិត្តសញ្ញាអូឡាំពិច (សន្ធិសញ្ញាណៃរ៉ូប៊ី) ថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨១ ក៏ដូចជាសន្ធិសញ្ញា ទីក្រុងប៉េកាំង ស្តីពីការសម្តែងសោតទស្សន៍ (សន្ធិសញ្ញាទីក្រុងប៉េកាំង) ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២។[135]

- **ប្រទេសឡាវ**

ប្រទេសឡាវបានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥។ លើសពីនេះ ក៏បានទទួលយកអនុសញ្ញាទីក្រុងប៉ារីស នៅថ្ងៃទី ០៨ ខែតុលា ឆ្នាំ១៩៩៨ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦ អនុសញ្ញាទីក្រុងប៊ែន នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ និងពិធីសារទីក្រុងម៉ាឌ្រីត ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦។[136]

- **ប្រទេសម៉ាឡេស៊ី**

ប្រទេសម៉ាឡេស៊ី បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨៩ និងជាប្រទេសហត្ថលេខីនៃអនុសញ្ញាទីក្រុងប៉ារីស នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨៩។ បន្ទាប់មក បានទទួលយកអនុសញ្ញាទីក្រុងប៊ែន នៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩០ សន្ធិ-សញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦ កិច្ចព្រមព្រៀងទីក្រុងនីស ស្តីពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវា សម្រាប់គោលបំណងចុះបញ្ជីម៉ាក (កិច្ច

---

[134] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=21C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

[135] ដដែល, \ ។

[136] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=98C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

ព្រមព្រៀងទីក្រុងនីស) និងកិច្ចព្រមព្រៀងទីក្រុងវីយែនស្តីពីការបង្កើតចំណាត់ថ្នាក់អន្តរជាតិនៃធាតុជា រូបភាពនៃម៉ាក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ។ ចុងក្រោយ ប្រទេសម៉ាឡេស៊ី បានទទួលយកសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកសម្តែង និងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។[137]

- **ប្រទេសភូមា**

ប្រទេសភូមា បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ហើយមិនបានទទួលយកអនុសញ្ញាផ្សេងៗរបស់អង្គការនេះទេ។[138]

- **ប្រទេសហ្វីលីពីន**

ប្រទេសហ្វីលីពីន បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៨០ ហើយប្រទេសនេះ បន្តទទួលយកអនុសញ្ញាទីក្រុងប៊ែន នៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៥១ អនុសញ្ញាទីក្រុងប៉ារីស ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៥ សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែស នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨១ អនុសញ្ញាទីក្រុងរ៉ូម នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៨៤ សន្ធិសញ្ញាសហ-ប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១។ រយៈពេលមួយឆ្នាំក្រោយមកទៀត ប្រទេសហ្វីលីពីន បានទទួលយកសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកសម្តែង និងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២។ បទដ្ឋានអន្តរជាតិចុងក្រោយ ដែលប្រទេសនេះទទួលយកគឺ ពិធីសារទីក្រុងម៉ាឌ្រីត នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ប៉ុន្តែ សម្រាប់អនុសញ្ញាស្តីពីហ្វូណូក្រាមវិញ ប្រទេសហ្វីលីពីនគ្រាន់តែបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧២ តែប៉ុណ្ណោះ។[139]

- **ប្រទេសសិង្ហបុរី**

ប្រទេសសិង្ហបុរី បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩០ ហើយបានទទួលយកអនុសញ្ញាទីក្រុងប៉ារីស ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៥ អនុសញ្ញាទីក្រុងប៊ែន ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៨។ ក្នុងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៥ ប្រទេសសិង្ហបុរីបានបន្តទទួលយកសន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែស និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម កិច្ច-ព្រមព្រៀងទីក្រុងនីស នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ពិធីសារទីក្រុងម៉ាឌ្រីត ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០ អនុសញ្ញាសហភាពអន្តរជាតិសម្រាប់ការការពារពូជថ្មីនៃដំណាំ (International

---

[137] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=124C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

[138] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=116C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

[139] ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=139C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C។

Union for the Protection of New Varieties of Plants Convention) នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ អនុសញ្ញាទីក្រុងព្រុចសែល ស្តីពីការចែកចាយសញ្ញាដែលមានកម្មវិធីបញ្ជូនតាមផ្កាយរណប (អនុសញ្ញាទីក្រុងព្រុចសែល) នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ កិច្ចព្រមព្រៀងទីក្រុងឡាអេ ស្របពេលនឹងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកសម្តែង និងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ សន្ធិសញ្ញាសិង្ហបុរី ស្តីពីច្បាប់ម៉ាក នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ និង សន្ធិសញ្ញាទីក្រុង ម៉ារ៉ាកេស នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦។[140]

- **ប្រទេសថៃ**

ប្រទេសថៃ បានក្លាយជាសមាជិករបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៨៩ និងទទួលយកអនុសញ្ញាទីក្រុងប៊ែន នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៣១ អនុសញ្ញាទីក្រុងប៉ារីស នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៨ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ និងពិធីសារទីក្រុងម៉ាឌ្រីត ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧។[141]

- **ប្រទេសវៀតណាម**

ប្រទេសវៀតណាម បានក្លាយជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងថ្ងៃទី ០២ ខែកក្កដា ឆ្នាំ១៩៧៦ ហើយបានទទួលយកកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៣៩ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៣ អនុសញ្ញាទីក្រុងប៉ារីស ថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៤៩ អនុសញ្ញាទីក្រុងប៊ែន ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ អនុសញ្ញាស្តីពីហ្វូណូក្រាម ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ អនុសញ្ញាទីក្រុងព្រុចសែល ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ ពិធីសារទីក្រុងម៉ាឌ្រីត នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦ និងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៦ បានទទួលយកអនុសញ្ញាសហភាពអន្តរជាតិសម្រាប់ការការពារពូជថ្មីនៃដំណាំ និងអនុសញ្ញាទីក្រុងរ៉ូម នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧។[142]

## ៣.៣. មធ្យោបាយស្វែងរកប្រភេទកម្មសិទ្ធិបញ្ញា

### ៣.៣.១. ម៉ាក

---

140 ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=154C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

141 ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=168C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

142 ដដែល, http://www.wipo.int/treaties/en/ShowResults.jsp?country_id=185C&start_year=ANY&end_year=ANY&treaty_all=ALL&search_what=C ។

ដោយសារក្នុងតំបន់អាស៊ានពុំទាន់មាននីតិវិធីនៃការចុះបញ្ជីថ្នាក់តំបន់នៅឡើយ ហេតុដូច្នេះ អាស៊ានបានផ្តល់នូវមធ្យោបាយមួយចំនួនដល់ម្ចាស់កម្មសិទ្ធិបញ្ញា ដើម្បីសម្រួលដល់ពួកគេមុននឹងឈានដល់ការចុះបញ្ជីថ្នាក់ជាតិនៃបណ្តាប្រទេសជាសមាជិកអាស៊ាន។

អាស៊ានបានបង្កើត អាស៊ាន TMclass និងអាស៊ាន TMview ដើម្បីធ្វើការស្រាវជ្រាវអនឡាញនូវម៉ាក ដែលបានចុះបញ្ជីរួចរាល់នៅក្នុងរដ្ឋជាសមាជិករបស់ខ្លួន ដែលជាផ្នែកមួយសម្រួលដល់អ្នកដាក់ពាក្យស្នើសុំក្នុងការស្វែងរកម៉ាកដែលបានចុះបញ្ជីពីមុន មុនការដាក់ពាក្យស្នើសុំរបស់ខ្លួន។

អាស៊ាន TMclass ជាកម្មវិធីពិគ្រោះយោបល់ពហុភាសាតាមអនឡាញ ដែលផ្តល់ជូននូវទិន្នន័យអំពីពាក្យពេចន៍ដោយឥតគិតថ្លៃ ហើយដែលទទួលស្គាល់ដោយអង្គភាពកម្មសិទ្ធិបញ្ញារបស់អាស៊ាន មានលក្ខណៈសមស្របក្នុងការកំណត់អត្តសញ្ញាណទំនិញ និងសេវាសម្រាប់គោលបំណងចុះបញ្ជីម៉ាក។ ក្នុងនោះ អាស៊ាន TMclass ផ្តល់នូវពាក្យពេចន៍គន្លឹះចំនួនជាង ១៣,៨០០ពាក្យ ដែលទទួលស្គាល់ដោយការិយាល័យកម្មសិទ្ធិបញ្ញានានា ហើយបានរៀបចំឡើងទៅតាមអក្ខក្រម។ ចំណាត់ថ្នាក់នៃទិន្នន័យរួមមាន៖[143]

- កំណែចុងក្រោយនៃតារាងលំដាប់អក្សរក្រមចំណាត់ថ្នាក់នីស (បច្ចុប្បន្ន NCL ១០-២០១៨)
- «បញ្ជីឈ្មោះទំនិញអាស៊ាន» រៀបចំឡើងក្រោម «គម្រោងថ្មីទី៣» (Initiative 3) នៃផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១១-២០១៥
- បញ្ជីពាក្យប្រមាណ ៩,៥០០ពាក្យ ដូចទៅនឹងពាក្យដែលមាននៅទិន្នន័យសុដុមនីយកម្មសហភាពអឺរ៉ុបសម្រាប់ទំនិញ និងសេវាកម្ម និងWIPO Madrid Goods and Service Manager (MGS) ។

អាស៊ាន TMclass អាចឱ្យអ្នកប្រើប្រាស់ស្វែងរកពាក្យពាក់ព័ន្ធ ដែលអាចមានការបកប្រែ ជាភាសារបស់ប្រទេសសមាជិកអាស៊ាន។ អាស៊ាន TMclass រៀបចំឈ្មោះទំនិញ និងសេវាកម្មតាមអក្ខរក្រម ដោយយកលំនាំទៅតាមការរៀបចំចំណាត់ថ្នាក់នីស។[144]

អាស៊ាន TMview គឺជាវេទិកាព័ត៌មានពាណិជ្ជសញ្ញាតាមអនឡាញរួមរបស់រដ្ឋជាសមាជិកអាស៊ានមានគោលបំណងផ្សព្វផ្សាយទិន្នន័យពាណិជ្ជសញ្ញាអាស៊ានទូលំទូលាយ និងមានភាពងាយស្រួល។[145]

អាស៊ាន TMview ផ្តល់លទ្ធភាពក្នុងការពិនិត្យរកមើលម៉ាកនៅក្នុងតំបន់អាស៊ាន តាមមធ្យោបាយដ៏មានប្រសិទ្ធភាព និងសមស្របសម្រាប់អ្នកប្រើប្រាស់។ អាស៊ាន TMview មាន

[143] Asean TMclass, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://support.itawiki.org/km/asean-tmclass/about។

[144] ដដែល។

[145] ASEAN TMview, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.asean-tmview.org/tmview/welcome.html?lang=km។

ព័ត៌មានស្តីអំពីការដាក់ពាក្យស្នើសុំចុះបញ្ជី និងការចុះបញ្ជីម៉ាកច្រើនជាងពីរលាន ដែលមានអានុភាពនៅក្នុងបណ្តាប្រទេសអាស៊ាន ដែលក្នុងនោះ រួមមានទិន្នន័យស្តីពីការិយាល័យម៉ាក លេខយោង ឈ្មោះពាណិជ្ជសញ្ញា ឈ្មោះអ្នកដាក់ពាក្យចុះបញ្ជី កាលបរិច្ឆេទដាក់ពាក្យចុះបញ្ជី ប្រភេទម៉ាក គំរូក្រាហ្វិច ស្ថានភាពផ្លូវច្បាប់ បញ្ជីឈ្មោះទំនិញនិងសេវា កូដថ្នាក់ ជាអាទិ៍។[146]

អាស៊ាន TMview ផ្តល់ជូនការពិនិត្យម៉ាករយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ ទិន្នន័យទាំងនោះ បានផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងចំនួនម៉ាកសម្រាប់ប្រទេសនីមួយៗ ទំហំនៃការប្រមូលទិន្នន័យ (ការដាក់ពាក្យស្នើសុំចុះបញ្ជីថ្នាក់ជាតិ ការចុះបញ្ជីអន្តរជាតិ (ប្រព័ន្ធម៉ា-ឌ្រីត) ដែលបានជ្រើសរើសប្រទេសពាក់ព័ន្ធតាមលក្ខណៈសមស្រប) ភាពញឹកញាប់នៃការធ្វើបច្ចុប្បន្នភាពទិន្នន័យ និងកាលបរិច្ឆេទនៃការធ្វើបច្ចុប្បន្នភាពចុងក្រោយ។[147]

ម្យ៉ាងវិញទៀត អាស៊ានបង្កើតនូវសេចក្តីណែនាំទូទៅសម្រាប់ការត្រួតពិនិត្យបច្ចេកទេសលម្អិតនៃម៉ាកជាឯកសារ ដែលត្រូវបានរៀបចំដោយការិយាល័យកម្មសិទ្ធិបញ្ញានៃរដ្ឋសមាជិកដើម្បីពង្រឹកគុណភាព និងតម្លាភាពក្នុងការពិនិត្យលើពាក្យស្នើសុំចុះបញ្ជីម៉ាក ហើយក៏បានបញ្ញត្តិអំពីគោលការណ៍ និងស្តង់ដារ ដែលអាចឆ្លើយតបទៅដំណើរការនៃការពិនត្យរបស់រដ្ឋជាសមាជិកនីមួយៗដោយផ្អែកលើច្បាប់ជាតិ។ ការប្រើប្រាស់សេចក្តីណែនាំនេះ ក្នុងគោលបំណងផ្តោតសំខាន់ទៅលើការអនុវត្តរបស់ការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិ ដើម្បីជួយដល់ការសម្រេចចិត្តរបស់អ្នកត្រួតពិនិត្យ កាត់បន្ថយការចំណាយពេលវេលា សម្រាប់ការចុះបញ្ជីម៉ាក និងការពិនិត្យលើពាក្យស្នើសុំបានឆាប់រហ័ស។[148]

---

146 ASEAN TMview, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.asean-tmview.org/tmview/welcome.html?lang=km# ។

147 ដដែល។

148 Intellectual Property Rights (IPRs) [សិទ្ធិកម្មសិទ្ធិបញ្ញា (IPRs)], http://www.asean.org/storage/images/2015/August/outreach_document/batch-2/Edited%20IPR_1.pdf (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

### ៣.៣.២. ប្រកាសនីយបត្រតក្កកម្ម

សម្រាប់ប្រកាសនីយបត្រតក្កកម្ម អាស៊ានបង្កើត អាស៊ាន Patentscope ដែលអាចឱ្យអ្នកប្រើប្រាស់ស្វែងរកនូវតក្កកម្ម ដែលបានចុះបញ្ជីក្នុងតំបន់អាស៊ាន និងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យបច្ចេកទេសលម្អិតប្រកាសនីយបត្រតក្កកម្មអាស៊ាន (ASEAN Patent Examination Co-operation (ASPEC))[149]។[150]

គម្រោង អាស៊ាន Patentscope ត្រូវបានផ្តួចផ្តើមដោយ ASPEC Task Force ក្នុងឆ្នាំ២០១២ ហើយគាំទ្រដោយក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ក្នុងឆ្នាំ២០១៥។ ប្រទេសឥណ្ឌូនេស៊ី បានរួមចំណែកយ៉ាងច្រើនឆ្ពោះទៅរកការដឹកនាំនៃគម្រោងនេះ និងធ្វើជាអ្នករៀបចំទិន្នន័យប្រកាសនីយបត្រតក្កកម្ម។[151]

អាស៊ាន Patentscope ផ្តល់នូវទម្រង់អនឡាញក្នុងតំបន់ សម្រាប់ផ្សព្វផ្សាយពីព័ត៌មានប្រកាសនីយបត្រតក្កកម្មរបស់ប្រទេសជាសមាជិកអាស៊ានទាំងដប់ ហើយសម្រួលដល់ការិយាល័យប្រកាសនីយបត្រតក្កកម្មអាស៊ានក្នុងការចែកចាយទិន្នន័យប្រកាសនីយបត្រតក្កកម្ម ដោយប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាជាសកល ដូចជាប្រព័ន្ធ WIPO Case ប្រើប្រាស់ដោយអ្នកត្រួតពិនិត្យប្រកាសនីយបត្រតក្កកម្ម ប្រព័ន្ធ WIPO PatentScope និង ប្រព័ន្ធIP5 Global Dossier សម្រាប់អ្នកប្រើជាសាធារណៈ។ អ្នកប្រើប្រាស់កម្មវិធីនេះ អាចប្រមូលបាននូវទិន្នន័យប្រកាសនីយបត្រតក្កម្ម និងព័ត៌មានបច្ចេកវិទ្យាផ្សេងៗទៀតពីរដ្ឋជាសមាជិកអាស៊ាន។[152]

អាស៊ាន Patentscope Portal មានលក្ខណៈពិសេសគួរឱ្យកត់សម្គាល់ជាច្រើនក្នុងការជួយដល់អ្នកប្រើប្រាស់ ដូចជាការស្វែងរកទិន្នន័យគន្ថនិទ្ទេស ការមើលលើព័ត៌មានប្រកាសនីយបត្រតក្កកម្មដែលបានបោះពុម្ពផ្សាយ របាយការណ៍ស្រាវជ្រាវ និងការបកប្រែទៅជាភាសាជាតិជាច្រើន។[153]

ប្រព័ន្ធនេះមានលក្ខណៈទំនើប មានប្រសិទ្ធភាព និងរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនចំនួនអ្នកចូលទៅស្វែងរកព័ត៌មានអំពីប្រកាសនីយបត្រតក្កកម្មក្នុងតំបន់អាស៊ាន ដោយសារការប្រើ

---

[149] ASEAN Intellectual Property Portal, What is ASPEC [អ្វីទៅជា ASPEC], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://www.aseanip.org/Services/ASEAN-Patent-Examination-Co-operation-ASPEC/What-is-ASPEC។ ASPEC គឺជាកម្មវិធីចែករំលែកការងារអំពីប្រកាសនីយបត្រតក្កកម្មក្នុងតំបន់ជាលើកដំបូងរវាងការិយាល័យកម្មសិទ្ធិបញ្ញា របស់បណ្តារដ្ឋជាសមាជិកអាស៊ានទាំង៩ លើកលែងប្រទេសមីយ៉ានម៉ា។ កម្មវិធីនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩។ គោលបំណងនៃកម្មវិធីនេះ គឺចែករំលែកការស្វែងរក និងពិនិត្យលទ្ធផលរវាងការិយាល័យកម្មសិទ្ធិបញ្ញាដែលបានចូលរួម ដើម្បីទទួលពាក្យស្នើសុំនៃប្រទេសសមាជិក ការឆ្លើយតបឆាប់រហ័ស និងមានប្រសិទ្ធិ។ កម្មវិធីនេះផងដែរ នឹងជួយកាត់បន្ថយការស្រាវជ្រាវ និងកិច្ចការពិនិត្យស្ទួន ដែលអាចសន្សំពេលវេលាបានច្រើន។

[150] ASEAN PATENTSCOPE, About ASEAN Patentscope [អំពីអាស៊ាន Patentscope], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://ipsearch.aseanip.org/wopublish-search/public/about ។

[151] ដដែល។

[152] ដដែល។

[153] ដដែល។

ប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាអាស៊ាន និង សហគមន៍កម្មសិទ្ធិបញ្ញាអន្តរជាតិ។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក តាមរយៈជំនួយបច្ចេកទេសដល់ការិយាល័យកម្មសិទ្ធិឧស្សាហកម្មថ្នាក់ជាតិ និងថ្នាក់តំបន់។ ផ្នែកអភិវឌ្ឍន៍របស់ប្រព័ន្ធនេះ ត្រូវបានជួយឧបត្ថម្ភដោយជំនួយរបស់ប្រទេសជប៉ុន សម្រាប់កម្មសិទ្ធិឧស្សាហកម្ម។[154]

### ៣.៣.៣. គំនូរឧស្សាហកម្ម

មិនខុសគ្នាពីមធ្យោបាយនៃការស្រាវជ្រាវម៉ាកដែលបានចុះបញ្ជី តាមរយៈ អាស៊ាន TMclass និងអាស៊ាន TMview អាស៊ានបានបង្កើត អាស៊ាន Designview មួយ ដែលជាកម្មវិធីអនឡាញមួយរបស់រដ្ឋជាសមាជិកអាស៊ាន ដែលមានគោលបំណងធ្វើឱ្យទិន្នន័យគំនូរឧស្សាហកម្មរបស់អាស៊ានកាន់តែមានភាពទូលំទូលាយ និងមានភាពងាយស្រួលដល់ភាគីដែលពាក់ព័ន្ធ។[155]

អាស៊ាន Designview ផ្តល់ព័ត៌មានក្នុងការស្វែងរកគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីអនឡាញក្នុងបណ្តារដ្ឋជាសមាជិកអាស៊ានដោយឥតគិតថ្លៃ។ អាស៊ាន Designview ត្រូវបានធ្វើការអភិវឌ្ឍដោយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសជាសមាជិកអាស៊ាននីមួយៗ ក្រោមការឧបត្ថម្ភដោយគម្រោងរបស់សហភាពអឺរ៉ុបគឺ គម្រោងសហភាពអឺរ៉ុប-អាស៊ានស្តីពីកិច្ចការពារសិទ្ធិកម្មសិទ្ធិបញ្ញា (ECAP III Phase II) ដែលគ្រប់គ្រងដោយការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EUIPO)។[156]

### ៣.៣.៤. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

អាស៊ាន GI Database គឺកម្មវិធីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអនឡាញមួយរបស់ប្រទេសជាសមាជិកអាស៊ាន ក្នុងគោលបំណងធ្វើឱ្យមានភាពកាន់តែងាយស្រួល និងជាប្រយោជន៍ដល់ភាគីពាក់ព័ន្ធនានា ក្នុងការស្វែងរកព័ត៌មាន ដែលបានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងតំបន់អាស៊ាន។ វាជាមធ្យោយងាយស្រួល និងមានប្រសិទ្ធិភាព ក្នុងការប្រើប្រាស់នូវកម្មវិធីនេះ ពីព្រោះ វាផ្ទុកដោយព័ត៌មានម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ប្រទេសជាសមាជិកអាស៊ាន ក៏ដូចជាព័ត៌មានពេញលេញដែលពាក់ព័ន្ធផ្សេងៗ។[157]

អាស៊ាន GI Database ត្រូវបានអភិវឌ្ឍន៍ដោយការិយាល័យកម្មសិទ្ធិបញ្ញារបស់ប្រទេសជាសមាជិកអាស៊ាន ដែលមានការគាំទ្រដោយគម្រោងសហភាពអឺរ៉ុប-អាស៊ានស្តីពីកិច្ចការពារសិទ្ធិកម្ម

---

[154] ដដែល។

[155] ASEAN DesignView, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.asean-designview.org/designview/welcome.html?lang=en។

[156] ASEAN DesignView, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.aseandesignview.org/designview/welcome.html?lang=en ។

[157] ASEAN GI Database, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://asean-gidatabase.org/gidatabase/ ។

សិទ្ធិបញ្ញា (ECAP III Phase II) ដែលគ្រប់គ្រងដោយការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EUIPO)។[158]

## ៣.៤. យន្តការអភិវឌ្ឍន៍ និងការពង្រឹងបន្ថែម

### ៣.៤.១. ផែនការសកម្មភាព

ក្នុងការធ្វើឱ្យវិស័យកម្មសិទ្ធិបញ្ញាមានការអភិវឌ្ឍ អាស៊ានបានបង្កើតផែនការសកម្មភាពដល់ទៅបីដងរួចទៅហើយ គឺផែនការសកម្មភាពឆ្នាំ២០០៤-២០១០ ឆ្នាំ២០១១-២០១៥ និងឆ្នាំ២០១៦-២០២៥។ ផែនការសកម្មភាពទាំងអស់នេះ កើតចេញឡើងដោយសារការយកគោលគំនិតនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន និងសេដ្ឋកិច្ចតំបន់។

- **ផែនការសកម្មភាព ឆ្នាំ២០០៤-២០១០**

គោលបំណងនៃផែនការសកម្មភាពនេះ ដើម្បីជួយពន្លឿនដំហាន និងវិសាលភាពនៃការលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញា ពន្លឿនដល់ការធ្វើពាណិជ្ជកម្មក្នុង និងក្រៅតំបន់អាស៊ាន ព្រមទាំងបង្កើតទំនាក់ទំនងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា សកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍។ ម្យ៉ាងវិញទៀតផែនការសកម្មភាពនេះនឹងជួយអភិវឌ្ឍន៍ និងភាពសុខដុមនៃការចុះបញ្ជីការពារសិទ្ធិកម្មសិទ្ធិបញ្ញា ព្រមទាំងការពារ និងការអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្តក្នុងតំបន់។ លើសពីនេះ លើកកម្ពស់ ការយល់ដឹងសាធារណៈ កសាងធនធានមនុស្ស និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ាន ហើយផ្តល់សិទ្ធិអំណាចដល់ការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិ ប្រកប ដោយកិច្ចសហការលើសេវាកម្មអភិវឌ្ឍន៍ជំនួញ (Business Development Services (BDS)) ដើម្បីឆ្លើយតបនឹងគោលបំណងផែនការសកម្មភាព។[159]

- **ផែនការសកម្មភាព ឆ្នាំ២០១១-២០១៥**

ការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់ ចាំបាច់ឱ្យប្រទេសជាសមាជិក និងការិយាល័យ-កម្មសិទ្ធិបញ្ញាថ្នាក់ជាតិមានសមត្ថភាព ក្នុងការកសាងទំនុកចិត្ត សុចរិតភាព និងតម្លាភាពនៃដំណើរការរបស់ពួកគេ។[160]

ប្រៀបធៀបផែនការសកម្មភាពឆ្នាំ២០០៤-២០១០ ផែនការសកម្មភាពនេះផ្តោតសំខាន់លើការកសាងនូវប្រព័ន្ធកម្មសិទ្ធិបញ្ញា ដែលរំលេចឱ្យឃើញពីភាពខុសគ្នានូវកម្រិតនៃការអភិវឌ្ឍ និង

---

[158] ដដែល។

[159] ASEAN Intellectual Property Right Action Plan 2004-2010 [ផែនការសកម្មភាពសិទ្ធិកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០០៤-២០១០], (២៨ កញ្ញា ២០១២), ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://asean.org/?static_post=asean-intellectual-property-right-action-plan-2004-2010។

[160] ASEAN Intellectual Property Right Action Plan 2010-2015 [ផែនការសកម្មភាពសិទ្ធិកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១០-២០១៥], http://www.ecap3.org/sites/default/files/IP resources/ASEAN%20IPR%20Action %20 Plan% 202011-2015.pdf (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

សមត្ថភាពនៃសេវាកម្មកម្មសិទ្ធិបញ្ញាក្នុងរដ្ឋជាសមាជិកនីមួយៗ។ នៅក្នុងផែនការសកម្មភាពនេះ បានលើកឡើងពីគោលដៅយុទ្ធសាស្ត្រចំនួន៥ ក្នុងគោលបំណងកែប្រែសហគមន៍អាស៊ាន ឱ្យទៅជាតំបន់ប្រកួតប្រជែង និងច្នៃប្រឌិត តាមរយៈការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់សមាជិក និងធានាឱ្យបានថា វាជាតំបន់ដែលដើរតួយ៉ាងសកម្មនៅក្នុងសហគមន៍កម្មសិទ្ធិបញ្ញាអន្តរជាតិ។[161] ក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ានជាអ្នកអនុវត្តន៍ និងតាមដានទៅលើផែនការសកម្មភាពទាំងនេះ។[162]

គោលដៅយុទ្ធសាស្ត្រទី១៖ ធ្វើយ៉ាងណាឱ្យមានតុល្យភាពក្នុងការអភិវឌ្ឍ និងសមត្ថភាពការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិនៃបណ្តាប្រទេសជាសមាជិក ដើម្បីមានពេលវេលាសមរម្យ គុណភាព និងការប្រើប្រាស់សេវាកម្មសិទ្ធិបញ្ញា ក្នុងការលើកកម្ពស់នូវតម្រូវការសម្រាប់អ្នកប្រើប្រាស់ និងអ្នកបង្កើតស្នាដៃដែលជាកម្មសិទ្ធិបញ្ញានានានៅក្នុងតំបន់។[163]

គោលដៅយុទ្ធសាស្ត្រទី២៖ អភិវឌ្ឍន៍គោលនយោបាយ និងច្បាប់នៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលឆ្លើយតបទៅនឹងតម្រូវការនៃបរិបទកម្មសិទ្ធិបញ្ញា និងការចូលរួមរបស់រដ្ឋសមាជិកក្នុងប្រព័ន្ធកម្មសិទ្ធិបញ្ញាលើពិភពលោកនៅក្នុងពេលវេលាដ៏សមរម្យ។[164]

គោលដៅយុទ្ធសាស្ត្រទី៣៖ ធ្វើឱ្យផលប្រយោជន៍នៅក្នុងតំបន់មានភាពប្រសើរឡើងតាម-រយៈការលើកកម្ពស់ជាប្រព័ន្ធ សម្រាប់ការបង្កើតថ្មី ការយល់ដឹង និងការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីធានាថាកម្មសិទ្ធិបញ្ញានឹងក្លាយជាមធ្យោបាយថ្មី សម្រាប់ការបង្កើតថ្មី និងការអភិវឌ្ឍ ហើយជាមធ្យោបាយគាំទ្រដល់ការផ្លាស់ប្តូរបច្ចេកវិទ្យា និងស្នាដៃរបស់អ្នកច្នៃប្រឌិតនៅក្នុងតំបន់ជាដើម។[165]

គោលដៅយុទ្ធសាស្ត្រទី៤៖ ធ្វើឱ្យមានភាពសកម្មរបស់ថ្នាក់តំបន់ ទៅក្នុងសហគមន៍កម្មសិទ្ធិបញ្ញាអន្តរជាតិ ទំនាក់ទំនងជិតស្និទ្ធិជាមួយដៃគូសន្ទនានានា និងស្ថាប័ននានា ដើម្បីអភិវឌ្ឍន៍សមត្ថភាពរដ្ឋជាសមាជិក និងឆ្លើយតបនឹងតម្រូវការរបស់ដៃគូពាក់ព័ន្ធនៅក្នុងតំបន់។[166]

គោលដៅយុទ្ធសាស្ត្រទី៥៖ ធ្វើឱ្យកិច្ចសហប្រតិបត្តិការមានភាពរឹងមាំ និងបង្កើតកិច្ចសហ-ការរវាងរដ្ឋជាសមាជិក ដើម្បីលើកកម្ពស់ធនធានមនុស្ស និងសមត្ថភាពការិយាល័យកម្មសិទ្ធិបញ្ញាក្នុងតំបន់។[167]

---

[161] SEA-EU-Net, Intellectual Property Rights in Southeast Asia [សិទ្ធិកម្មសិទ្ធិបញ្ញានៅអាស៊ីអាគ្នេយ៍], (១៩ មីនា ២០១៤), https://sea-eu.net/object/document/130/attach/IPR final24032014.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

[162] ដូច ១៦០។

[163] ដដែល។

[164] ដដែល។

[165] ដដែល។

[166] ដដែល។

[167] ដដែល។

- **ផែនការសកម្មភាព ឆ្នាំ២០១៦-២០២៥**

តាមរយៈការជំរុញឱ្យបណ្តាប្រទេសជាសមាជិកមានការបង្កើតច្បាប់ ឬគោលនយោបាយផ្សេងៗ ដែលស្របនឹងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងផែនការសកម្មភាពជំហានទីបីនេះ អាស៊ានរំពឹងថា សហគមន៍សេដ្ឋកិច្ចអាស៊ាននឹងនាំមកនូវការប្រកួតប្រជែង និងផលិតភាពក្នុងតំបន់ តាមរយៈការធ្វើពាណិជ្ជកម្មលើកម្មសិទ្ធិបញ្ញា ព្រមទាំងការបង្កើតថ្មី និងជំណាក់កាលមួយចំនួនទៀតដែលអាចក្លាយជាកត្តាលីករបង្កើតលទ្ធភាពនៃការនាំចេញ និងទាក់ទាញអ្នកវិនិយោគក្នុង និងក្រៅស្រុក ហើយថែមទាំងអាចទទួលបានចំណាត់ថ្នាក់ល្អប្រសើរក្នុងសៀវភៅប្រចាំឆ្នាំនៃការប្រកួតប្រជែងពិភពលោក (World Competitiveness Yearbook)[168]។[169]

ដើម្បីឈានដល់ការរំពឹងទុកនោះ ផែនការសកម្មភាពនេះបានកំណត់គោលដៅយុទ្ធសាស្ត្រចំនួនបួនដូចខាងក្រោម[170]៖

គោលដៅយុទ្ធសាស្ត្រទី១៖ ធ្វើការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ាន ដោយពង្រឹងទៅលើការិយាល័យកម្មសិទ្ធិបញ្ញា និងកសាងហេដ្ឋារចនាសម្ព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់។

គោលដៅយុទ្ធសាស្ត្រទី២៖ ធ្វើការអភិវឌ្ឍកម្មវិធីកម្មសិទ្ធិបញ្ញាថ្នាក់តំបន់ និងហេដ្ឋារចនាសម្ព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់ ដើម្បីរួមចំណែកពង្រីកបន្ថែមសហគមន៍សេដ្ឋកិច្ចអាស៊ាន។

គោលដៅយុទ្ធសាស្ត្រទី៣៖ ធ្វើការអភិវឌ្ឍចំពោះការពង្រីកសក្តានុពល និងប្រព័ន្ធអេកូកម្មសិទ្ធិបញ្ញាអាស៊ាន (ASEAN IP Ecosystem)។

គោលដៅយុទ្ធសាស្ត្រទី៤៖ បង្កើតឱ្យមានយន្តការថ្នាក់តំបន់ ដើម្បីលើកកម្ពស់ការបង្កើតថ្មី និងសកម្មភាពពាណិជ្ជកម្ម ជាក់ស្តែងត្រូវធ្វើឱ្យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងចំណេះដឹងពីមុនមានភាពរីកចម្រើន។

### ៣.៤.២. ទស្សនៈបណ្ដាលអំពីកម្មសិទ្ធិបញ្ញា

ដើម្បីធ្វើឱ្យវិស័យកម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ានកាន់តែប្រសើរឡើង បណ្តាប្រទេសជាសមាជិកបានកំពុងតែខិតខំពង្រឹងនូវវិស័យមួយនេះ តាមរយៈការបង្កើតច្បាប់ដែលពាក់ព័ន្ធនានា

---

[168] សៀវភៅប្រចាំឆ្នាំនៃការប្រកួតប្រជែងពិភពលោក គឺជាកំណត់ត្រាដែលបានបង្កើតឡើងដោយវិទ្យាស្ថានអន្តរជាតិអភិវឌ្ឍន៍ការគ្រប់គ្រង (IMD) នៅប្រទេសស្វីស ក្នុងការឱ្យចំណាត់ថ្នាក់ជាអន្តរជាតិលើ៦៣ប្រទេសលើការប្រកួតប្រជែងផ្នែកជំនួញ ហើយទិន្នន័យនៃប្រទេសនីមួយៗត្រូវបានប្រើប្រាស់ដោយអ្នកជំនួញ និងរដ្ឋាភិបាលដើម្បីទាក់ទាញវិនិយោគ, អាចរកបាននៅ https://www.ceda.com.au/Research-and-policy/All-CEDA-research/World-Competitiveness-Yearbook ។

[169] ASEAN Intellectual Property Right Action Plan 2016-2025 [ផែនការសកម្មភាពសិទ្ធិកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១៦-២០២៥], https://www.aseanip.org/Portals/0/ASEAN%20IPR%20ACTION%20PLAN%202016-2025%20(for%20public%20use).pdf?ver=2017-12-05-095916-273 (ថតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

[170] ដដែល។

ហើយជាពិសេសអាស៊ាន បានបង្កើតនូវគេហទំព័រដែលអាចឱ្យសហគ្រាសធុនតូច និងមធ្យមធ្វើការសិក្សាអនឡាញ ដើម្បីស្វែងយល់អំពីវិស័យកម្មសិទ្ធិបញ្ញាជុំវិញសហគមន៍អាស៊ាន។

គេហទំព័រ «ការបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញាអាស៊ាន» (ASEAN IP Training)[171] ត្រូវបានបង្កើតឡើងសម្រាប់ការិយាល័យកម្មសិទ្ធិបញ្ញារបស់សមាជិកអាស៊ានទាំងអស់ ដើម្បីជាមធ្យោបាយមួយក្នុងការផ្តល់ភាពងាយស្រួល សម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងតំបន់ធ្វើការសិក្សាស្វែងយល់បន្ថែមអំពីកម្មសិទ្ធិបញ្ញា តាមរយៈកម្មវិធីសិក្សាអនឡាញ។ កម្មវិធីសិក្សាអនឡាញ មានគោលបំណងប្រែក្លាយខ្លួនឱ្យទៅជាវិធីសាស្ត្រសិក្សាថ្មី និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាតែមួយគត់ ដើម្បីអភិវឌ្ឍន៍សមត្ថភាពអ្នកសិក្សា ជាពិសេសសហគ្រាសធុនតូច និងមធ្យមលើវិស័យផលិត-កម្ម ក៏ដូចជាការបង្កើត ការការពារ ការគ្រប់គ្រងនូវផលិតផល សេវាកម្ម និងការបង្កើតថ្មីៗ ដែលជាមធ្យោបាយក្នុងការអភិវឌ្ឍតំបន់អាស៊ាន។[172]

អ្នកសិក្សាអាចស្វែងយល់ពីវគ្គសិក្សាមួយចំនួនដូចជា តើកម្មសិទ្ធិបញ្ញាមានការពាក់ព័ន្ធនឹងសហគ្រាសភាពខ្នាតតូច និងមធ្យមយ៉ាងដូចម្តេច? តើអ្វីទៅជាកម្មសិទ្ធិបញ្ញា? តើសិទ្ធិលើកម្មសិទ្ធិបញ្ញាមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច? តើអ្នកអាចធ្វើអាជីវកម្ម ឬអនុវត្តសិទ្ធកម្មសិទ្ធិបញ្ញារបស់អ្នកដោយវិធីណា? និងតើអ្នកមានសិទ្ធិអាចការពារកម្មសិទ្ធិបញ្ញារបស់អ្នកដោយរបៀបណា?[173]

## ៣.៥. ការអនុវត្តកម្មសិទ្ធិបញ្ញាក្នុងតំបន់

### ៣.៥.១. ការអនុវត្តផែនការសកម្មភាព

ការអនុវត្តផែនការសកម្មភាពរបស់អាស៊ានអំពីកម្មសិទ្ធិបញ្ញា គឺជាការបន្តសកម្មភាពលើគោលការណ៍ដែលបានបញ្ញត្តិក្នុង AEC Blueprint និងពន្លឿនការផ្លាស់ប្តូរព័ត៌មាន ក៏ដូចជាការអនុ-វត្តឱ្យបានល្អជាមួយនឹងសមាជិកអាស៊ានដូចគ្នា។[174]

ក្នុងការអនុវត្តផែនការសកម្មភាព គេពិចារណាទៅលើបួនផ្នែកគឺ អតិថិជន ម្ចាស់កម្មសិទ្ធ-បញ្ញា អាជ្ញាធរសាធារណៈ និងតំបន់អាស៊ានទាំងមូល។ ការអនុវត្តផែនការសកម្មភាពនោះរួមមានការបង្កើតសកម្មភាព និងយុទ្ធនាការដើម្បីឱ្យមានការយល់ដឹងបន្ថែមពីការអនុវត្តកម្មសិទ្ធិបញ្ញាក្នុងតំបន់ និងវិស័យឯកជនដែលពាក់ព័ន្ធនឹងការប្រឆាំងអំពើលួចចម្លង។ ឧទាហរណ៍ ការរៀបចំសិក្ខាសាលអំពីវិស័យកម្មសិទ្ធិបញ្ញាសម្រាប់ភាគីពាក់ព័ន្ធ។

ម៉្យាងវិញទៀត សាធារណៈជនអាចស្វែងរកទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តកម្មសិទ្ធិបញ្ញាដូចជារឿងក្តីពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាជាដើម ដែលអាចរកបានក្នុងគេហទំព័រ «អាស៊ាន IP Portal»

---

[171] ASEAN IP Training, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://itawiki.org/lms/ ។

[172] ដដែល។

[173] ដដែល។

[174] ASEAN Intellectual Property Rights (IPR) Enforcement Action Plan, https://www.aseanip.org/Portals/0/ASEAN%20IPR%20Enforcement%20Action%20Plan.pdf?ver=2018-01-04-150134-093 ។

របស់អាស៊ាន។ កាត់បន្ថយសកម្មភាពលួចចម្លង និងក្លែងបន្លំទំនិញរវាងសមាជិកអាស៊ាន តាមរយៈការរៀបចំសិក្ខាសាលាថ្នាក់តំបន់សម្រាប់ ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តន៍ច្បាប់ផ្សេងៗ។ សេចក្តីណែនាំអំពីការអនុវត្តមានចែងពាក់ព័ន្ធនឹង រឿងរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរចនាសម្ព័ន្ធរដ្ឋបាលរាល់សមាជិកអាស៊ានដែលផ្អែកលើសកម្មភាពនៃការអនុវត្តជាក់ស្តែងចំពោះការអនុវត្តកម្មសិទ្ធិបញ្ញា។ លើសពីនេះទៅទៀត នឹងមានការអភិវឌ្ឍយន្តការសហប្រតិបត្តិការលើការអនុវត្តកម្មសិទ្ធិបញ្ញារវាងរដ្ឋសមាជិក។[175]

### ៣.៥.២. ការអនុវត្តកន្លងមក (ករណីសិក្សា)

ក្នុងការដោះស្រាយទំនាស់កម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ាន មានប្រទេសពីរដែលបានដោះស្រាយកន្លងមកគឺ ប្រទេសសិង្ហបុរី និងប្រទេសថៃ។ ទំនាស់នៃកម្មសិទ្ធិបញ្ញាភាគច្រើនគឺម៉ាក ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធ ហើយករណីគំនូរឧស្សាហកម្មមានតែមួយប៉ុណ្ណោះ ដែលត្រូវបានបង្ហាញក្នុងទិន្នន័យនៃរឿងក្តីរបស់អាស៊ាន។[176]

ករណីរឿងក្តីរវាង Société v., Limited Partnership ពាក់ព័ន្ធនឹង ពាណិជ្ជសញ្ញា និង សិទ្ធិអ្នកនិពន្ធ ដែល Société ជាដើមបណ្តឹង និង Big Trading ជាចុងចម្លើយ។ Société បានប្តឹងទៅតុលាការរបស់ប្រទេសថៃ ហើយសេចក្តីសម្រេចបានចេញនៅថ្ងៃទី២០ ខែកក្កដា ២០១១ ដោយផ្អែកទៅលើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ (Copy Right Act. B.E. 2537) និង ច្បាប់ស្តីពីម៉ាក (Trademark Act. B.E. 2534) របស់ប្រទេសថៃ។[177]

ដើមបណ្តឹង គឺជានីតិបុគ្គលដែលស្ថិតនៅក្រោមច្បាប់របស់សាធារណៈរដ្ឋបារាំង អះអាងថាខ្លួនជាអ្នកបង្កើតស្នាដៃសិល្បៈទៅលើឡូហ្គោ «ក្មេងក្បាលធំ» ដែលស្នាដៃនេះត្រូវបានផ្សព្វផ្សាយលើកដំបូងនៅប្រទេសបារាំង។ ក្រោយមកក៏ត្រូវបានចុះបញ្ជីម៉ាក (ពាណិជ្ជសញ្ញា) ដោយភ្ជាប់ជាមួយពាក្យ BIC។ ពាណិជ្ជសញ្ញានេះ ត្រូវបានប្រើលើផលិតផល៨ប្រភេទ និងឡាម។ ពាណិជ្ជសញ្ញានេះផងដែរ ត្រូវបានដាក់លើផលិតផលជាច្រើនទៀត ដូចជាសម្ភារសិក្សាជាដើម។ ចុងចម្លើយពីររូប បានបំពានលើពាណិជ្ជសញ្ញាដោយការបង្កើតនូវពាណិជ្ជសញ្ញានៃ «ក្មេងក្បាលធំ» ប្រើលើផលិតផលកាំបិតកោរ និងឡាម ដែលមានលក្ខណៈស្រដៀងទៅនឹងស្នាដៃរបស់ដើមចោទ។ ដើមចោទបានទាមទារឱ្យចុងចម្លើយបញ្ឈប់សកម្មភាពរបស់ខ្លួនដោយសារប៉ះពាល់ផលប្រយោជន៍របស់ខ្លួន។

---

[175] ដដែល ។

[176] ASEAN Intellectual Property Portal, ចូលមើលចុងក្រោយ ២៦ មិថុនា ២០១៨, https://www.aseanip.org/Resources/ASEAN-Case-Law-Database ។

[177] Société v., Limited Partnership, ២០ កក្កដា ២០១១, https://www.aseanip.org/LinkClick.aspx?fileticket=mIkQ_gb31Z4%3d&portalid=0 ។

ចុងចម្លើយទាំងពីរបានផ្តល់សក្ខីកម្មថា ចុងចម្លើយទី១ គឺជានីតិបុគ្គល ដែលត្រូវបានគេស្គាល់ថា «Big Trading» ហើយឈ្មោះនេះត្រូវបានចុះបញ្ជីម៉ាកពាណិជ្ជកម្មរួចរាល់ និងពុំធ្វើឱ្យមានការភ័ន្តច្រឡំដល់សាធារណជនឡើយ។ ពាណិជ្ជសញ្ញារបស់ចុងចម្លើយទី១ គឺជារូបភាពបុរសដែលមានកាំបិតកោរក្រោយខ្នង ហើយភ្ជាប់ជាមួយពាក្យ «RAZOR KING»។ សញ្ញានេះមិនដូច ឬស្រដៀងទៅនឹងសញ្ញារបស់ដើមចោទនោះទេ។ វាមិនមានការលួចចម្លងពាណិជ្ជសញ្ញារបស់ដើមចោទឡើយ ដូច្នេះចុងចម្លើយបានប្តឹងទាមទារឱ្យតុលាការច្រានចោលបណ្តឹងរបស់ដើមចោទ។

ចំណោទគតិយុត្តក្នុងរឿងក្តីនេះគឺ តើចុងចម្លើយទាំងពីរបានបំពានសិទ្ធិអ្នកនិពន្ធលើស្នាដៃសិល្បៈរបស់ដើមចោទដែលជាពាណិជ្ជសញ្ញាឬទេ? ហើយតើចុងចម្លើយទាំងពីរ បានរំលោភបំពានលើសិទ្ធិអ្នកនិពន្ធនៃពាណិជ្ជសញ្ញា «ក្មេងក្បាលធំ» របស់ដើមចោទទេ?

តុលាការ បានផ្អែកលើច្បាប់ទាំងពីរខាងលើដោយផ្តល់នូវហេតុផលថា ការការពារសិទ្ធិអ្នកនិពន្ធ និងពាណិជ្ជសញ្ញាខុសគ្នាស្រឡះ។ ដើមចោទបានជួលលោក រាយម៉ុន (Raymon) ដែលជាវិចិត្រករគូររូបភាព «ក្មេងក្បាលធំ» ហើយគាត់គូរទៅតាមដើមចោទចង់បានដើម្បីបង្កើតពាណិជ្ជសញ្ញានេះ។ ដូច្នេះវាមិនមែនជាស្នាដៃសិល្បៈសម្រាប់គោលបំណងច្នៃប្រឌិតទេ។ ដើមចោទមិនអាចអះអាងថាខ្លួនមានសិទ្ធិអ្នកនិពន្ធលើរូបភាព «ក្មេងក្បាលធំ» ដែលអាចត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធឡើយ។ ដូច្នេះ ចុងចម្លើយទាំងពីរមិនមានទោសចំពោះគំនូរ«ក្មេងក្បាលធំ» ទេ។

ម្យ៉ាងវិញទៀត ដើមចោទបានចុះបញ្ជីម៉ាកនៅប្រទេសថៃលើគំនូរ «ក្មេងក្បាលធំ» ហើយភ្ជាប់ជាមួយពាក្យ «BIC» ដាក់លើសម្ភារសិក្សា ឡាម និងដែកកេះ។ ដោយក្រឡេកមកពាណិជ្ជសញ្ញារបស់ចុងចម្លើយ គឺជារូបភាពបុរសដែលមានកាំបិតកោរក្រោយខ្នង ហើយភ្ជាប់ជាមួយពាក្យ «RAZOR KING» និងមានរូបម្កុដនៅលើអក្សរZផងដែរ។ នេះជាភស្តុតាងមួយថា ភាពស្រដៀងគ្នារវាងពាណិជ្ជសញ្ញានេះគឺរូបមនុស្ស ដែលត្រូវបានគេប្រើទូទាំងពិភពលោក ហើយក្រៅពីនេះមិនដូចគ្នាទេ។ លក្ខខណ្ឌតែមួយនោះគឺថា អ្នកដែលប្រើប្រាស់រូបភាពពីមុនត្រូវធ្វើឱ្យមានលក្ខណៈខុសគ្នាពីផលិតផលដែលមានពីមុន។ ជារួម ពាណិជ្ជសញ្ញាទាំងពីរនេះ មានលក្ខណៈខុសគ្នាច្រើន ដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការបែងចែកពីភាពខុសគ្នា ដោយមិនមានលក្ខណៈច្រឡំឡើយ។

ដូច្នេះ តុលាការសម្រេចឱ្យចុងចម្លើយទាំងពីរមិនជាប់ទោសតាមបណ្តឹងរបស់ដើមចោទទេ។

## ៣.៦. ផលវិជ្ជមាន និងបញ្ហាប្រឈមរបស់ប្រទេសកម្ពុជា ទៅនឹងប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន

### ៣.៦.១. ផលវិជ្ជមាន

ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា អត្ថប្រយោជន៍ដែលប្រទេសកម្ពុជាទទួលបាននៅពេលមានប្រព័ន្ធចុះបញ្ជីថ្នាក់តំបន់ វាជាលក្ខខណ្ឌដំបូង ដែលជួយសម្រួលដល់ម្ចាស់កម្មសិទ្ធិបញ្ញាមានបំណងចង់ឱ្យកម្មសិទ្ធិរបស់ខ្លួនត្រូវបានការពារក្នុងប្រទេសកម្ពុជា ទៅលើនីតិវិធីនៃការចុះបញ្ជីមាន

លក្ខណៈខ្ពីជាងមុន។ ការសម្រួលនីតិវិធីបែបនេះ នឹងនាំឱ្យកម្ពុជាកាន់តែទទួលបានពាក្យស្នើសុំកាន់តែច្រើនឡើងៗ ដែលជាពិសេសនោះគឺ ម៉ាក គំនូរឧស្សាហកម្ម និងប្រកាសនីយបត្រតក្កកម្មជាដើម។ រាល់ការទទួលពាក្យស្នើសុំចុះបញ្ជី និងបន្តសុពលភាពកម្មសិទ្ធិបញ្ញា សុទ្ធសឹងតែជាចំណែកនៃការទាញយកផលប្រយោជន៍សេដ្ឋកិច្ច ដែលនាំឱ្យមានចំណូលចូលរដ្ឋ។

ម្យ៉ាងវិញទៀត ធ្វើឱ្យច្បាប់បានរឹងមាំជាងមុន ដោយសារកំណើននៃការអនុវត្តច្បាប់កាន់តែប្រសើរ ដែលជាហេតុធ្វើឱ្យវិស័យកម្មសិទ្ធិបញ្ញាកាន់តែមានចំណាប់អារម្មណ៍ និងកាន់តែមានធនធានមនុស្សច្រើនធ្វើការលើវិស័យនេះ។ លើសពីនេះទៅទៀត ប្រទេសកម្ពុជានឹងត្រូវបានគេស្គាល់ច្រើនជាងមុន តាមរយៈអ្នកដែលមានបំណងចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងតំបន់អាស៊ាន ហើយវិស័យកម្មសិទ្ធិបញ្ញាប្រទេសកម្ពុជាកាន់តែមានភាពរឹងមាំ និងរីកចម្រើន។

### ៣.៦.២. បញ្ហាប្រឈម

ទោះបីជាប្រទេសកម្ពុជាទទួលអត្ថប្រយោជន៍ច្រើន ពីប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាថ្នាក់តំបន់ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែអាចជួបប្រទះបញ្ហាប្រឈមមួយចំនួនទាក់ទងទៅនឹងលទ្ធភាព និងសមត្ថភាពរបស់ខ្លួន។

បញ្ហាប្រឈមដែលសំខាន់នោះ គឺការយល់ដឹងអំពីកម្មសិទ្ធិបញ្ញារបស់ស្ថាប័នអនុវត្តន៍ ដូច្នេះបញ្ហាមិនប្រក្រតីណាមួយទាក់ទងនឹងដំណើរការចុះបញ្ជី ឬពិនិត្យពាក្យស្នើសុំ ឬដំណាក់កាលផ្សេងៗអាចកើតឡើងបាន ហើយចំណេះដឹងរបស់សាធារណជនអំពីកម្មសិទ្ធិបញ្ញានេះក៏នៅមានកម្រិត ដែលជាហេតុបង្កឱ្យមានការរំលោភបំពានកម្មសិទ្ធិបញ្ញាច្រើនឡើងផងដែរ។ ក្រៅពីនេះប្រទេសកម្ពុជាក៏ជួបប្រទះនឹងកង្វះខាតបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងការអនុវត្តកម្មសិទ្ធិបញ្ញាមួយចំនួនផងដែរ។ រីឯការចែករំលែកព័ត៌មាន និងការសម្របសម្រួល ជាពិសេសភ្នាក់ងារអនុវត្តកម្ម-សិទ្ធិបញ្ញាក៏នៅមានកង្វះខាត និងសមត្ថភាពរបស់មន្ត្រីដែលធ្វើការក្នុងវិស័យកម្មសិទ្ធិមួយចំនួននៅមានកម្រិត។ បន្ថែមពីនេះទៀត ប្រទេសកម្ពុជា អាចត្រូវបានគេមើលរំលងក្នុងការដាក់ពាក្យស្នើសុំការពារកម្មសិទ្ធិបញ្ញា ពីព្រោះអ្នកដាក់ពាក្យអាចសម្លឹងមើលទៅប្រទេសដែលមានសក្តានុពលជាងប្រទេសកម្ពុជា។

## ៣.៧. ផលវិជ្ជមាន និងបញ្ហាប្រឈម នៃការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន

### ៣.៧.១. ផលវិជ្ជមាន

ការបង្កើតឱ្យបាននូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងតំបន់ សម្រាប់អាស៊ានក្នុងពេលបច្ចុប្បន្នមិនមែនជារឿងងាយស្រួលទេ។ វាអាចស្តែងឡើងឱ្យឃើញតាមរយៈការលេចចេញរូបរាងនៃការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់តំបន់ពីរ គឺការិយាល័យប្រកាសនីយបត្រតក្កកម្មអាស៊ាន និងការិយាល័យម៉ាកអាស៊ាន។

ក្នុងករណីដែលការិយាល័យប្រកាសនីយបត្រតក្កកម្មអាស៊ាន អាចនឹងត្រូវបានបង្កើតឡើង ដោយផ្អែកលើការសិក្សាអំពីការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងអង្គការកម្មសិទ្ធិបញ្ញាតំបន់អាហ្វ្រិក អាស៊ានអាចនឹងទទួលបានការរីកចម្រើនសមត្ថភាពនៃការគ្រប់គ្រងការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ព្រមទាំងលើកកម្ពស់គោលនយោបាយ និងគោលដៅរបស់អាស៊ានចំពោះការពន្លឿនភាពរីកលូតលាស់បច្ចេកវិទ្យាក្នុងតំបន់។ រីឯសមាជិកអាស៊ានក៏ត្រូវមានទំនួលខុសត្រូវ និងអនុវត្តន៍សកម្មភាព ដើម្បីជួយឱ្យសហគមន៍កាន់តែទទួលបានផលប្រយោជន៍ និងជំនះលើបញ្ហាប្រឈម។[178]

ម៉្យាងវិញទៀត នីតិវិធីនៃការចុះបញ្ជី និងការត្រួតពិនិត្យអាចមានលក្ខណៈសាមញ្ញ ងាយស្រួល និងជាទម្រង់តែមួយក្នុងការប្រើប្រាស់នៅក្នុងតំបន់។ លើសពីនេះទៅទៀត ជាការរួមចំណែកក្នុងការកាត់បន្ថយការចំណាយវេលា និងថវិកាលើនីតិវិធី។

ផលប្រយោជន៍ដែលទទួលធំធេងជាងគេ គឺការសម្រេចបំណងរបស់អាស៊ានដែលអាចប្រែក្លាយអាស៊ានឱ្យទៅជាសហគមន៍ទីផ្សារសេដ្ឋកិច្ចតែមួយ និងអនុវត្តន៍បាននូវផែនការសកម្មភាពដែលបានតាក់តែងឡើង។

### ៣.៧.២. បញ្ហាប្រឈម

ទោះជាយ៉ាងណា នៅពេលដែលបង្កើតការិយាល័យកម្មសិទ្ធិបញ្ញាបានរួចរាល់នោះ អាស៊ាននៅតែត្រូវធ្វើបែបណាដើម្បីឱ្យដំណើរការប្រព្រឹត្តទៅបានដោយរលូនក្នុងតំបន់អាស៊ាន។ ហេតុនេះ អាស៊ានអាចនឹងពុំទាន់មានបទពិសោធន៍ពេញលេញ សម្រាប់នីតិវិធីទាំងឡាយដែលនឹងបង្កើតឡើងប្រសិនបើយកគំរូតាមសហភាពអឺរ៉ុបទៀតនោះ។ អាស៊ានពុំទាន់មានបច្ចេកវិទ្យា ធនធានមនុស្សគ្រប់គ្រាន់ក្នុងការបំពេញតួនាទី ដូចជាការត្រួតពិនិត្យលើប្រព័ន្ធនៃការត្រួតពិនិត្យឱ្យបានត្រឹមត្រូវឆ្លើយតបទៅកាន់អ្នកដាក់ពាក្យស្នើសុំ ប្រសិនបើរកឃើញបញ្ហា ដែលមានក្នុងពាក្យស្នើសុំ និងការដោះស្រាយជម្លោះដែលអាចកើតមានក្នុងវិស័យកម្មសិទ្ធិបញ្ញាជាអាទិ៍។

ក្រៅពីមានការិយាល័យកម្មសិទ្ធិបញ្ញា អាស៊ានត្រូវរៀបចំយន្តការយ៉ាងណាក្នុងការការពារកម្មសិទ្ធិបញ្ញា ដូច្នេះអាស៊ានត្រូវធានាឱ្យបានថានៅពេលដែលចុះបញ្ជីកម្មសិទ្ធិបញ្ញារួច រដ្ឋសមាជិកត្រូវផ្ដល់ការការពារកម្មសិទ្ធិបញ្ញានោះយ៉ាងហ្មត់ចត់។ ទាំងនេះ អាចជំរុញឱ្យអាស៊ានត្រូវបង្កើតការគ្រប់គ្រង ការប្រើប្រាស់ឧបករណ៍ដើម្បីការពារការរំលោភបំពានផ្សេងៗទៅលើសិទ្ធិនៃកម្មសិទ្ធិបញ្ញា។

ការយល់ដឹងអំពីវិស័យកម្មសិទ្ធិបញ្ញាក្នុងតំបន់នៅតែចោទជាបញ្ហាដដែរ ដោយសារការយល់ដឹងរបស់សាធារណជននៅមានកម្រិតនៅឡើយ ហេតុនេះរូបភាពនៃការរំលោភបំពានកម្ម

[178] Research Works Archive, The ASEAN Patent System: The Adoption of Regional Patent Office in ASEAN [ប្រព័ន្ធប្រកាសនីយបត្រតក្កកម្មអាស៊ានៈ ការអនុម័តការិយាល័យប្រកាសនីយបត្រតក្កកម្មនៅអាស៊ាន], ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, https://digital.lib.washington.edu/researchworks/handle/1773/40222។

សិទ្ធិបញ្ញា ក៏នៅតែជាកត្តាដែលអាស៊ានត្រូវមានវិធានការច្បាស់លាស់ក្នុងការទប់ស្កាត់ និងបញ្ឈប់នូវការរំលោភបំពាន។

ម៉្យាងវិញទៀត អាស៊ាននៅប្រឈមនឹងការពង្រឹងសមត្ថភាព និងលទ្ធភាពចំពោះការបង្កើតតុលាការកម្មសិទ្ធិបញ្ញាក្នុងតំបន់ ដែលស្ថាប័ននេះទាមទារឱ្យមានចៅក្រមដែលពោរពេញដោយចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញា និងអ្នកអនុវត្តន៍សេចក្តីសម្រេចរបស់តុលាការមានជំនាញ និងសមត្ថ-ភាពគ្រប់គ្រាន់។

លើសពីនេះ ការធ្វើពង្រាងពាក្យស្នើសុំត្រូវឱ្យមានលក្ខណៈស្តង់ដារក្នុងការប្រើប្រាស់នៅថ្នាក់តំបន់ ដូចនេះអាស៊ានត្រូវតែមានសមត្ថភាពក្នុងការតាក់តែងទម្រង់ពាក្យស្នើសុំចុះបញ្ជីកម្មសិទ្ធិបញ្ញាហើយត្រូវមានការសម្របសម្រួលជាមួយរដ្ឋជាសមាជិកចំពោះការអនុម័ត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី «ដំណើរឈានទៅរកការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន» រួចមកឃើញថាគោលដៅ ដែលអាស៊ានចង់ឱ្យមានប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងថ្នាក់តំបន់នេះ ត្រូវប្រើរយៈពេលយូរទៀត ដោយសារតែអាស៊ាននៅមានបញ្ហាប្រឈមជាច្រើន ហើយបើទោះបីមានការជួយជ្រោមជ្រែងពីសហភាពអឺរ៉ុបតាមរយៈគម្រោងសហភាពអឺរ៉ុប-អាស៊ាន ស្តីពីកិច្ចការពារកម្មសិទ្ធិបញ្ញាក៏ដោយនោះ អាស៊ាននៅតែពិបាកក្នុងការសម្រេចគោលដៅដ៏ធំមួយនេះ។ អាស៊ានមានកិច្ចព្រមព្រៀងក្នុងការបង្កើតការិយាល័យប្រកាសនីយបត្រតក្កកម្ម និងការិយាល័យម៉ាក ដែលបានបញ្ញត្តិក្នុងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន ផ្ទុយទៅវិញកិច្ចព្រមព្រៀងនេះនៅមិនទាន់ត្រូវបានអនុវត្តន៍បាននោះទេ ដែលជាបញ្ហាមួយសម្រាប់អាស៊ានទាំងមូល ពីព្រោះរដ្ឋដែលជាសមាជិកមួយចំនួនមិនទាន់បានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះឡើយ។

មធ្យោបាយមួយទៀតដែលអាស៊ានបាននឹងកំពុងប្រើប្រាស់ សម្រាប់ឱ្យការអនុវត្តលើវិស័យកម្មសិទ្ធិបញ្ញាមានដំណើរការបានល្អ អាស៊ានមានផែនការសកម្មភាពដែលឈានដល់ដំណាក់កាលទី៣ និងការបង្កើតមធ្យោយបាយអនឡាញសម្រាប់ស្វែងរកស្នាដៃដែលជាកម្មសិទ្ធិបញ្ញា ដែលបានចុះបញ្ជីក្នុងប្រទេសជាសមាជិកអាស៊ាន។ នេះជាវិធីងាយស្រួលមួយសម្រាប់អ្នកដែលមានបំណងចង់ដាក់ពាក្យស្នើសុំចុះបញ្ជីឱ្យការពារកម្មសិទ្ធិបញ្ញារបស់គេ ដោយគ្រាន់តែធ្វើការស្វែងរកនៅក្នុងគេហទំព័រកម្មសិទ្ធិបញ្ញាអាស៊ាន ហើយបន្ទាប់មកអាចសម្រេចចិត្តបានចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជី។ ទាំងអស់នេះ ជាជំហានឈានទៅដល់ការបង្កើតឱ្យបាននូវប្រព័ន្ធកម្មសិទ្ធិបញ្ញារួមក្នុងតំបន់អាស៊ាន និងអាចជួយដល់ប្រទេសដែលជាសមាជិកឱ្យមានការអភិវឌ្ឍលើវិស័យកម្មសិទ្ធិបញ្ញាផងដែរ។

ប្រសិនបើក្រឡេកទៅមើលការបង្កើតនូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមរបស់សហភាពអឺរ៉ុប ដែលបានបង្កើតឱ្យមានការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប បានប្រើរយៈពេលជាងម្ភៃឆ្នាំក្នុងការពិភាក្សាទម្រាំអាចបង្កើតការិយាល័យទាំងនេះបាន។ ហេតុនេះ អាស៊ាននៅតែមានសង្ឃឹមក្នុងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាថ្នាក់តំបន់របស់ខ្លួន មិនថាត្រូវប្រើរយៈពេលយូរប៉ុណ្ណានោះទេ ដើម្បីធានាបានថា នៅពេលបង្កើតការិយាល័យទទួលបន្ទុកចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់នោះ នឹងដំណើរការប្រកបទៅដោយរលូន។

ភាពរាំងស្ទះរបស់អាស៊ាន ដែលនឹងត្រូវប្រើរយៈពេលយូរក្នុងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់មានកត្តាជាច្រើន ដែលអាស៊ានត្រូវដោះស្រាយបញ្ហា ដូចជាភាពមិនទាន់ចុះសម្រុងនឹងគ្នារវាងរដ្ឋជាសមាជិកក្នុងការទទួលយកបទដ្ឋានគតិយុត្តដែលបង្កើតឡើងមក ការអភិវឌ្ឍរបស់ប្រទេសនីមួយៗក៏មានលក្ខណៈមិនស្មើគ្នា ហើយការរីកចម្រើនលើវិស័យកម្មសិទ្ធិបញ្ញារបស់ប្រទេសសមាជិករឹតតែខុសគ្នាទៅទៀត។ សម្រាប់ប្រទេសកម្ពុជា ការទទួលចុះបញ្ជីម៉ាកឃើញមានភាពសកម្មជាងគេ បើប្រៀបធៀបទៅនឹងប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្ម ទន្ទឹមនឹងនេះ មានតែប្រទេសភូមាទេ ដែលវិស័យកម្មសិទ្ធិបញ្ញានៅទន់ខ្សោយជាងគេក្នុងតំបន់អាស៊ាន។

ផលប្រយោជន៍សម្រាប់អាស៊ាននាពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹងប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញាមិនទាន់លេចចេញជាផ្លែផ្កាដល់រដ្ឋជាសមាជិក ឬសហគមន៍អាស៊ានទាំងមូលនៅឡើយនោះទេ ប៉ុន្តែអាស៊ានបានចាប់ផ្តើមធ្វើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ជាមួយការិយាល័យកម្មសិទ្ធិបញ្ញាធំៗ ដែលនាពេលអនាគត អាស៊ានអាចនឹងពឹងពាក់រកជំនួយ ឬកិច្ចសហការក្នុងគោលដៅអភិវឌ្ឍន៍វិស័យកម្មសិទ្ធិបញ្ញាក្នុងតំបន់។ ដៃគូសំខាន់មួយ ដែលអាស៊ានគួរសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទាក់ទងនឹងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមថ្នាក់តំបន់នោះគឺ សហភាពអឺរ៉ុប ដោយផ្អែកលើការជួយជ្រោមជ្រែងអាស៊ាន និងទំនាក់ទំនងដែលមានស្រាប់ ដូចនេះអាស៊ាននៅតែអាចទាញប្រយោជន៍ពីសហភាពអឺរ៉ុបបាន។

សរុបសេចក្តីមក ប្រធានបទមួយនេះ ទាមទារឱ្យមានការតាមដានរាល់សកម្មភាពរបស់អាស៊ានជុំវិញការពិភាក្សាលើវិស័យកម្មសិទ្ធិបញ្ញា និងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមរបស់ខ្លួន ដើម្បីជាចំណេះដឹងក្នុងការបង្កើតទស្សនវិស័យនាពេលអនាគតរបស់សហគមន៍នេះ។ រាល់ខ្លឹមសារដែលបានបង្ហាញនៅក្នុងសារណានេះ អាចធ្វើការសន្និដ្ឋានបានថា សហគមន៍អាស៊ាននៅពុំទាន់មានលទ្ធភាព ក៏ដូចជាសមត្ថភាពគ្រប់គ្រាន់ នៅក្នុងការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងថ្នាក់តំបន់នោះទេ។ អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ដែលមានចំណាប់អារម្មណ៍លើកម្មសិទ្ធិបញ្ញាសម្រាប់សហគមន៍អាស៊ាននេះ អាចបន្តស្វែងយល់បន្ថែមពីតម្រូវការសំខាន់ផ្សេងៗ ដែលជាប្រយោជន៍ដល់អាស៊ានក្នុងការបង្កើតឱ្យបាននូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់ និងផ្នែកផ្សេងៗទៀត ដែលអាចជំរុញឱ្យសហគមន៍អាស៊ានទាំងមូលមានការរីកចម្រើនលើវិស័យកម្មសិទ្ធិបញ្ញា ហើយមានលក្ខណៈរួមតែមួយក្នុងតំបន់។

# អនុសាសន៍

# អនុសាសន៍

ដើម្បីឱ្យការបង្កើតប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញារួមក្នុងតំបន់ ប្រកបដោយជោគជ័យ អាស៊ាន ត្រូវបំពេញចំណុចខ្វះខាតរបស់ខ្លួនជាច្រើនផ្សេងទៀត ក្នុងការសម្រេចឱ្យបាននូវសមិទ្ធផលដែលសំខាន់សម្រាប់តំបន់របស់ខ្លួន។ តាមរយៈការស្រាវជ្រាវលើប្រធានបទនេះ ឃើញថាអាស៊ាននៅមានចំណុចដែលត្រូវបំពេញបន្ថែមច្រើន។ ខាងក្រោមនេះជា គំនិតមួយចំនួនដែលជាការយល់ឃើញ និងជាចំណែកនៃការយល់ដឹង ដែលបានមកពីការស្រាវជ្រាវប្រធានបទនេះ ហើយបំពេញបន្ថែមលើសកម្មភាពរបស់អាស៊ានដែលកំពុងធ្វើនាពេលបច្ចុប្បន្ន។

ដើម្បីបង្កើតឱ្យបាននូវការិយាល័យប្រកាសនីយបត្រតក្កកម្ម និងការិយាល័យម៉ាកក្នុងតំបន់អាស៊ាន រដ្ឋជាសមាជិកគួរតែផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន។ កាលដែលឱ្យប្រទេសសមាជិកផ្តល់សច្ចាប័ននេះ មិនមែនជារឿងងាយស្រួលទេ ពីព្រោះសមាជិកនីមួយៗ ក៏គិតគូពីផលប្រយោជន៍ជាតិរបស់គេដែរ ហេតុដូចនេះ អាស៊ានត្រូវមានគោលការណ៍ធានាឱ្យបានថា រដ្ឋជាសមាជិកនឹងទទួលបានផលប្រយោជន៍ ពីប្រព័ន្ធស្តីពីការចុះបញ្ជីកម្មសិទ្ធិបញ្ញារួមនេះទាំងអស់គ្នា។ លើសពីនេះ អាស៊ានក៏ត្រូវមានអនុសញ្ញាដែលចែងអំពីនីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា ពីព្រោះការផ្តល់សច្ចាប័នទៅលើ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន តែមួយមុខមិនគ្រប់គ្រាន់សម្រាប់ដំណើរការចុះបញ្ជីទាំងមូលឡើយ។

ម្យ៉ាងវិញទៀត អាស៊ានគួរលើកទឹកចិត្ត ពង្រឹងយន្តការនៃការការពារ និងធ្វើយ៉ាងណាពង្រឹងការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិឱ្យបានរឹងមាំ ដើម្បីអាចការពារកម្មសិទ្ធិបញ្ញាបានល្អប្រសើរទៅតាមការដាក់ពាក្យស្នើសុំ ហើយចៀសវាងការរំលោភបំពានសិទ្ធិលើកម្មសិទ្ធិបញ្ញា។ ប្រទេសដែលជាសមាជិក ក៏គួរតែអភិវឌ្ឍន៍ និងកសាងសមត្ថភាពធនធានមនុស្សដែលធ្វើការពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាឱ្យមានចំណេះដឹងកាន់តែទូលំទូលាយ។

បន្តកិច្ចសហប្រតិបត្តិការជាសកលឱ្យកាន់តែរឹងមាំក្នុងគោលបំណង ដើម្បីចុះកិច្ចព្រមព្រៀងនានា ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា ដូចជាការផ្លាស់ប្តូរកម្មវិធីសិក្សា ឬការស្នើសុំជំនួយបច្ចេកទេសជាដើម។

ចុងក្រោយ រដ្ឋជាសមាជិកទាំងអស់គួរតែអនុវត្តន៍ផែនការសកម្មភាពរបស់អាស៊ានឱ្យមានប្រសិទ្ធភាព ដើម្បីជំរុញឱ្យដំណើរការអាស៊ានប្រព្រឹត្តទៅបានល្អលើវិស័យកម្មសិទ្ធិបញ្ញា។

សរុបមកវិញ ដើម្បីឱ្យការអនុវត្តទៅបានប្រកបដោយចីរភាព អាស៊ានត្រូវខំប្រឹងប្រែងសម្រេចផែនការសកម្មភាព ពង្រឹងទំនាក់ទំនងទាំងក្នុង និងក្រៅតំបន់ និងធ្វើឱ្យអាស៊ានក្លាយជាតំបន់ដែលមានការអភិវឌ្ឍ។

# ឯកសារយោង

# ឯកសារយោង


## ច្បាប់ជាតិ

ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣។

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២។

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម, លេខ នស/រកម/០១០៣/០០៥, ២២ មករា ២០០៣។

ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, លេខ នស/រកម/០១១៤/០០៦, ២០ មករា ២០១៤។

ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, លេខ នស/រកម/០៥០៨/០១៥, ១៣ ឧសភា ២០០៨។

## លិខិតបទដ្ឋានអន្តរជាតិ

ធម្មនុញ្ញអាស៊ាន. ១៥ ធ្នូ ២០០៨។

ASEAN Framework Agreement on Intellectual Property Cooperation [កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន]. ១៥ ធ្នូ ១៩៩៥។

Chairman's Statement of the 31st ASEAN Summit [សេចក្តីថ្លែងការណ៍លើកទី៣១នៃកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០១៧]. ១៣ វិច្ឆិកា ២០១៧។

## សាលដីកា

Société v., Limited Partnership. ២០១១. https://www.aseanip.org/LinkClick.aspx?fileticket=mIkQ_gb31Z4%3d&portalid=0។

## សៀវភៅ

កាន់ សុទ្ធប៉ូលីន.២០១៤. *នីតិកម្មសិទ្ធិបញ្ញា*។

នី វិចិត្រ.២០១៣. *នីតិកម្មសិទ្ធិបញ្ញាកម្ពុជា*។

ASEAN Intellectual Property Right Action Plan 2011-2015 [ផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១១-២០១៥]. http://www.ecap3.org/sites/default/files/IP_resources/ASEAN%20IPR%20Action%20Plan%202011-2015.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

ASEAN Intellectual Property Right Action Plan 2016-2025 [ផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១៦-២០២៥]. https://www.aseanip.org/Portals/0/ASEAN%20IPR%20ACTION%20PLAN%202016-2025%20(for%20public%20use).pdf?ver=2017-12-05-095916-273 (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

Audier & Partners Law Firm, Intellectual Property Rights: the convergence of laws in ASEAN [សិទ្ធិ-កម្មសិទ្ធិបញ្ញា៖ ការរួមបញ្ចូលច្បាប់ក្នុងអាស៊ាន]. http://www.henricapitant-cambodia.org/wp-content/uploads/2017/12/3.1.5.-Colin-Picard-de-Gennes-Intellectual-Property-Rights-The-Convergence-of-Laws-in-ASEAN.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

Darwin Hem និង Long Keopichchenda. “IP Protection in Cambodia (update 2017)” [ការការពារកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា (បច្ចុប្បន្នភាពឆ្នាំ២០១៧)].២០១៧. BNG Legal. http://bnglegal.com/cn/wp-content/uploads/2017/04/170403-IP-Protection-in-Cambodia-Update-2017.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

EPO. Modernising the EPO for excellence and sustainability [ទំនើបកម្មរបស់ EPO សម្រាប់ឧត្តមភាព និងនិរន្តភាព]. http://documents.epo.org/projects/babylon/eponet.nsf/0/dc766d4ee08d84a0c1258291002b5d6e/$FILE/Modernising_the_EPO_for_excellence_and_sustainability_en.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

EUIPO Strategic Plan 2020 [ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២០]. ២០១៦. https://euipo.europa.eu/tunnel-web/secure/webdav/guest/document_library/contentPdfs/about_euipo/strategic_plan/strategic_plan_2020_en.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

Intellectual Property Rights (IPRs) [សិទ្ធិកម្មសិទ្ធិបញ្ញា (IPRs)]. http://www.asean.org/storage/images/2015/August/outreach_document/batch-2/Edited%20IPR_1.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)

SEA-EU-Net, Intellectual Property Rights in Southeast Asia [សិទ្ធិកម្មសិទ្ធិបញ្ញានៅអាស៊ីអាគ្នេយ៍], (១៩ មីនា ២០១៩). https://sea-eu.net/object/document/130/attach/IPR final24032014.pdf (ចតចម្លងថ្ងៃទី ៣០ មិថុនា ២០១៨)។

Stefen Matin. ២០១៦. Introduction to International Intellectual Property [សេចក្តីផ្តើមកម្មសិទ្ធិបញ្ញាអន្តរជាតិ], ១២ កញ្ញា។

WIPO. Understanding Copyright and Related Rights [ការស្វែងយល់អំពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល], ២០១៦. http://www.wipo.int/edocs/pubdocs/en/wipo_pub_909_2016.pdf (ថតចម្លងថ្ងៃទី ០១ មិថុនា ២០១៨)។

## គេហទំព័រ

ASEAN. Intellectual Property [កម្មសិទ្ធិបញ្ញា]. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. http://asean.org/asean-economic-community/sectoral-bodies-under-the-purview-of-aem/intellectual-property/ ។

ASEAN Intellectual Property Portal. About [អំពី]. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. https://www.aseanip.org/About។

ASEAN Intellectual Property Portal. ASEAN and KIPO Sign Memorandum on Intellectual Property [អាស៊ាន និងKIPO ចុះអនុស្សរណៈស្តីពីកម្មសិទ្ធិបញ្ញា]. ២០១៨. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. https://www.aseanip.org/News-Events/Latest-News-Events/ctl/Details /mid / 1956/aid/54 ។

ASEAN Intellectual Property Portal. Guideline launched to help innovators in using ASPEC [សេចក្តីណែនាំដែលត្រូវបានដាក់ឱ្យប្រើដើម្បីជួយអ្នកច្នៃប្រឌិតថ្មីក្នុងការប្រើប្រាស់កម្មវិធី ASPEC]. ២០១៨. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. https://www.aseanip.org/News-Events/Latest-News-Events/ctl/Details/mid/1956/aid/58។

ASEAN Intellectual Property Portal. What is ASPEC [អ្វីទៅជា ASPEC]. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. https://www.aseanip.org/Services/ASEAN-Patent-Examination-Co-operation-ASPEC/What-is-ASPEC។

ASEAN Intellectual Property Portal. ចូលមើលចុងក្រោយ ២៦ មិថុនា ២០១៨. https://www.aseanip.org/Resources /ASEAN-Case-Law-Database។

ASEAN Intellectual Property Portal. ចូលមើលចុងក្រោយ ២៦ មិថុនា ២០១៨. https://www. aseanip.org/Statistics/IP-Filing-Statistics-in-ASEAN ។

Asean TMclass. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. http://support.itawiki.org /km/asean-tmclass/about ។

ASEAN TMview, ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨, http://www.asean-tmview.org/tmview/welcome.html?lang=km#។

ASEAN PATENTSCOPE. About ASEAN Patentscope [អំពីអាស៊ាន Patentscope]. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. http://ipsearch.aseanip.org/wopublish-search/public/about។

ASEAN DesignView. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. http://www.aseandesignview.org /designview/ welcome.html?lang=en ។

ASEAN GI Database. ចូលមើលចុងក្រោយ ៣០ មិថុនា ២០១៨. http://asean- gidatabase.org /gidatabase/ ។

